ISSN 1560-7615

លេខពិសេស
ស្តីអំពីបញ្ហាវិមជ្ឈការ

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៨ លេខ ២ | មេសា - មិថុនា ឆ្នាំ២០០៤ | តម្លៃ ១.៥០០៛

## បញ្ហាប្រឈមនៃការតាក់តែងរចនាវិមជ្ឈការ

កម្មវិធីស្រាវជ្រាវផ្តោតលើគោលនយោបាយស្តីពីវិមជ្ឈការ នៃ វបសអ បានពិនិត្យពីបញ្ហាប្រឈមនៃការតាក់តែងរចនាកំណែទំរង់វិមជ្ឈការនៅកម្ពុជា សំដៅកាត់បន្ថយភាពក្រីក្រ និងកែលំអរបបប្រជាធិបតេយ្យ ។Dr. Caroline Rusten អ្នកគ្រប់គ្រងកម្មវិធី បានបូកសរុបពីលទ្ធផលស្រាវជ្រាវដូចតទៅ ។*

កំណែទំរង់វិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) មានគោលដៅជួយកាត់បន្ថយភាពក្រីក្រ និងកែលំអរបបប្រជាធិបតេយ្យនៅកម្ពុជា ។ នេះជាការងារមួយមានបញ្ហាប្រឈមច្រើន និងមានរយៈពេលវែង ហើយចំណងទាក់ទងរវាងគោលដៅទាំងពីរ មិនងាយសំគាល់ឃើញទេ ។ ក្នុងនេះ កម្ពុជាធ្វើដំណើរបានឆ្ងាយ ហើយក្នុងកិច្ចប្រឹងប្រែងកសាងស្ថាប័ន និងប្រព័ន្ធនានាដែលចាំបាច់ដើម្បីសំរេចគោលដៅនៃកំណែទំរង់ ។ ប៉ុន្តែនៅមានបញ្ហាប្រឈមបន្ទាន់ៗជាច្រើនទៀតដែលត្រូវដោះស្រាយ ។ អត្ថបទនេះនឹងចាប់ផ្តើមពិនិត្យពីសមិទ្ធិផលចំបងៗ ហើយបន្ទាប់មកគឺ បញ្ហាបន្ទាន់ៗដែល RGC ត្រូវប្រឈមមុខនៅក្នុងកំណែទំរង់វិមជ្ឈការ ។



*វបសអ/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ក្រសួងមហាផ្ទៃ ជួបក្រុមប្រឹក្សាឃុំនៅខេត្តសៀមរាប ថ្ងៃ ៣ មីនា ២០០៤ ។*

### ផលសំរេចនៃកំណែទំរង់វិមជ្ឈការ

តាមមើលទៅ ទិដ្ឋភាពដ៏សំខាន់បំផុតមួយនៃកំណែទំរង់វិមជ្ឈការនៅកម្ពុជា គឺការសង្កត់ធ្ងន់លើ *ការរៀនសូត្រដោយការអនុវត្តន៍តាមរយៈដំណើរការមានការចូលរួមដែលរាប់បញ្ចូលអ្នកជាប់ពាក់ព័ន្ធទាំងអស់* ។ ក្នុងប្រទេសឯទៀតជាច្រើន ហេតុផលចំបងរបស់ស្ថាប័នរដ្ឋមួយចំនួនដើម្បីប្រឆាំងនឹងវិមជ្ឈការគឺ កង្វះសមត្ថភាពនៅកំរិតមូលដ្ឋាន ។ នៅកម្ពុជា រឿងនេះពុំឃើញមានប្រើជាហេតុផលដើម្បីប្រឆាំងនឹងដំណើរការធ្វើវិមជ្ឈការទេ ថ្វីបើតាមពិត ធនធានមនុស្ស និងលំហូរមូលនិធិទៅកំរិតមូលដ្ឋាននៅមានកង្វះខាតច្រើនក៏ដោយ ។ ផ្ទុយទៅវិញ ដើម្បីធានាឱ្យមានការកសាងសមត្ថភាពក្នុងចំណោមអ្នកពាក់ព័ន្ធនានានៅកំរិតមជ្ឈិម ខេត្ត និងមូលដ្ឋាន ព្រមទាំងភាពជាម្ចាស់លើកំណែទំរង់ផង ទិដ្ឋភាពធំៗនៃដំណើរការវិមជ្ឈការត្រូវបានអនុវត្តក្នុងលក្ខណៈជាដំណើរការមានការចូលរួម ។

ថ្វីបើវិធីនេះ វាបង្កើតបញ្ហាប្រឈមខ្លះៗ (សូមមើលខាងក្រោម) ប៉ុន្តែវាបានញាំងឱ្យមានការប្រែប្រួលយ៉ាងធំធេងនៅក្នុងអភិបាលកិច្ច ដែលកាលពីពីរ-បីឆ្នាំមុននេះ មានតិចនាក់ណាស់ដែលគិតថា អាចធ្វើទៅកើត ។ ម្យ៉ាងទៀត ដំណើរការនេះបានត្រៀមរៀបចំការងារសំរាប់កំណែទំរង់មួយដែលមានឱកាសល្អច្រើនដើម្បីបន្តវិវត្តចំទិសដៅ ។

ផលសំរេចចំបងៗផ្សេងទៀតនៃកំណែទំរង់គឺមានៈ (១) ការបង្កើតភាពជាម្ចាស់, (២) ការកសាងរចនាសម្ព័ន្ធគាំទ្រ, និង (៣) ការកសាងក្របខ័ណ្ឌ

* អត្ថបទនេះផ្អែកលើបទបង្ហាញរបស់អ្នកនិពន្ធ នៅក្នុងសិក្ខាសាលាស្តីពីបញ្ហាប្រឈមនៃការតាក់តែងរចនាវិមជ្ឈការដែល វបសអ រៀបចំធ្វើនៅសណ្ឋាគារសាន់វេ កាលពីថ្ងៃ ២៩ មករា ២០០៤ ។ របាយការណ៍ពេញលេញនៃការសិក្សានេះ ដែលផ្តល់ទុនដោយអង្គការ SIDA របស់រដ្ឋាភិបាលស៊ុយអែត និង DFID របស់រដ្ឋាភិបាលអង់គ្លេស នឹងបោះពុម្ពផ្សាយដោយ វបសអ នៅខែឧសភា ២០០៤ (អ្នកនិពន្ធៈ Caroline Rusten, គីម សេតារា, អេង នេត្រា, និង ប៉ក់ គីមជឿន) ។

### មាតិកា

បញ្ហាប្រឈមនៃការតាក់តែងរចនាវិមជ្ឈការ ........ ១
បញ្ហាប្រឈមនៃកំណែទំរង់វិមជ្ឈការសារពើពន្ធនៅកម្ពុជា ........ ៦
សុខដុមនីយកម្មច្បាប់ជាប់ទាក់ទងនឹងវិមជ្ឈការ ........ ៩
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១២
— ស្ថានភាពក្នុងប្រទេស ........ ១៥
— សន្ទស្សន៍សេដ្ឋកិច្ច ........ ១៧
សទ្ទានុក្រម ........ ១៩
ព័ត៌មានថ្មីៗពី វបសអ ........ ២០

ច្បាប់, ដែលយើងនឹងពិនិត្យម្តងមួយៗ ។ ទី១ RGC បានដោះស្រាយតាមរយៈកម្មវិធីសិលានូវការងារដ៏ពិបាកមួយនៃ *ការបង្កើតភាពជាម្ចាស់* លើដំណើរការធ្វើវិមជ្ឈការ ជាពិសេសនៅកំរិតឃុំ/សង្កាត់ និងជាបន្ទាប់បន្សំនៅកំរិតខេត្ត ។ ភាពជាម្ចាស់នេះ នឹងតំរូវការផ្លាស់ប្តូរនៅកំរិតមជ្ឈិមផងដែរ សព្វថ្ងៃមានកំលាំងខ្លាំងណាស់ ដូច្នេះហើយកំណែទំរង់វិមជ្ឈការគឺ ជាកត្តាអូសទាញកំណែទំរង់ក្នុងវិស័យសាធារណៈមិនមែនអ្វីផ្សេងទេ ។ ភាពជាម្ចាស់នេះបានកើតឡើងតាមរយៈសកម្មភាពដ៏ជាក់លាក់មួយចំនួនៈ

- ដំណើរការធំទូលាយថ្នាក់ជាតិមួយដែលមានរួមបញ្ចូលអ្នកពាក់ព័ន្ធទាំងអស់ក្នុងការតាក់តែងរចនាកំណែទំរង់ និងដែលធ្វើឡើងតាមរយៈគំរោងវិមជ្ឈការសាកល្បងមួយចំនួនអនុវត្តដោយក្រសួងផ្សេងៗ ។
- ការអនុវត្តន៍ជាក់ស្តែងនៅនឹងកន្លែង ដែលប្រជាជនអាចមើលឃើញលទ្ធផលពិតៗនៃការចូលរួមរបស់ខ្លួន ក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និងការផ្តល់វិភាគទានហិរញ្ញវត្ថុដល់គំរោងអភិវឌ្ឍន៍នៅមូលដ្ឋានដែលទទួលថវិកាពីមូលនិធិឃុំ/សង្កាត់ (CSF)[1] ។
- ការប្រើប្រាស់ CSF ដោយមានតំលាភាពនិងគណនេយ្យភាពសមរម្យបានរាំងដល់ការក្តោបក្តាប់របស់ពួកវណ្ណៈខ្ពស់នៅក្នុងមូលដ្ឋាន និងជួយឱ្យសំរេចបាននូវ គំរោងដែលផ្តល់អត្ថប្រយោជន៍ភាគច្រើនដល់ប្រជាជនទាំងអស់គ្នា ។

ផលសំរេចទី២នៃកំណែទំរង់គឺ RGC អាចកសាងបាននូវ*រចនាសម្ព័ន្ធគាំទ្រឃុំ/សង្កាត់*ដែលជាក់ស្តែងបានកសាងសមត្ថភាពទាំងនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ទោះបីក្នុងកំរិតតូច ជាងក្តី ។ រចនាសម្ព័ន្ធគាំទ្រទាំងនេះ បានផ្តល់លទ្ធភាពឱ្យអភិបាលខេត្តបំពេញតួនាទីគាំទ្ររបស់ខ្លួនក្នុងការងារសំរបសំរួល រវាងវិស័យមួយចំនួនដែលកាលពី ២-៣ឆ្នាំមុន គឺមិនអាចធ្វើដូច្នេះបានទេ ។ រចនាសម្ព័ន្ធគាំទ្រ ក៏បានជួយដល់ឃុំ/សង្កាត់ឱ្យមានការយល់ដឹងកាន់តែច្បាស់ពីតួនាទី និងមុខងាររបស់ខ្លួន ។ ដូច្នេះត្រូវគូសបញ្ជាក់ផងដែរថា ការកសាងសមត្ថភាពនៃរចនាសម្ព័ន្ធគាំទ្រចំពោះអាជ្ញាធរមូលដ្ឋានក៏ចាំបាច់បំផុតដែរ ហើយប្រទេសជាច្រើនទៀតមានការខ្វះខាតនៅក្នុងរឿងនេះ ប៉ុន្តែប្រទេសកម្ពុជាអាចដោះស្រាយបានល្អគួរសម ។

ផលសំរេចទី៣ គឺក្នុងរយៈពេលមួយដ៏ខ្លី គណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC) អាចកសាងច្បាប់ធំៗបានពីរ[2] និងអនុក្រឹត្យមួយចំនួនសំរាប់គ្រប់គ្រងកំណែទំរង់ ។ រឿងនេះបានអនុញ្ញាតឱ្យកំណែទំរង់អាចឈានទៅមុខ ថ្វីបើនៅមានការខ្វះចន្លោះជាច្រើនក្តី[3] ។ ផលសំរេចឯទៀតដែលគួរគូសបញ្ជាក់ដែរមានដូចជា ការណែនាំពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះបញ្ជីបោះឆ្នោតនៅកំរិតឃុំ/សង្កាត់ ។

ផលសំរេចជាច្រើនក៏បានចង្អុលបង្ហាញផងដែរពីបញ្ហាផ្សេងៗ ដែលកំណែទំរង់ត្រូវប្រឈមមុខក្នុងការកាត់បន្ថយភាពក្រីក្រ និងការកែលំអរបបប្រជាធិបតេយ្យនៅកម្ពុជា ។

## បញ្ហាប្រឈមចំបងៗចំពោះកំណែទំរង់វិមជ្ឈការ

មានបញ្ហាប្រឈម ៤ធំៗក្នុងកំណែទំរង់វិមជ្ឈការគឺ (១) ក្របខ័ណ្ឌច្បាប់, (២) ការតាក់តែងរចនាខាងស្ថាប័ន, (៣) យន្តការនានាសំរាប់សំរេចគោលដៅកំណែទំរង់, និង (៤) ឌីណាមិកនៅមូលដ្ឋាន ។ រដ្ឋាភិបាលមានជំរើសគោលនយោបាយជាច្រើន សំរាប់ដោះស្រាយបញ្ហាប្រឈមទាំងនេះ ។

*ក្របខ័ណ្ឌច្បាប់*

ច្បាប់បោះឆ្នោត (២០០១) បានលើកទឹកចិត្តដល់គណនេយ្យភាពពីក្រោមទៅលើពីសំណាក់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ចំពោះគណបក្សនយោបាយរបស់ពួកគេ (មិនមែនចំពោះមជ្ឈដ្ឋានអ្នកបោះឆ្នោតទេ) ពីព្រោះបើសិនគណបក្សនយោបាយណាមួយសំរេចបណ្តេញចេញសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ណាម្នាក់ អ្នកនោះក៏ត្រូវបាត់បង់តួនាទីក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ដែរ ។ មកទល់សព្វថ្ងៃ មិនទាន់មានសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ណាម្នាក់ត្រូវបណ្តេញចេញតាមរយៈរចនាសម្ព័ន្ធគណបក្សទេ ប៉ុន្តែចំណុចគ្រោះថ្នាក់គឺ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់នឹង ដើរតាមមាគ៌ាគណបក្ស ជាជាងមានអារម្មណ៍ទទួលខុសត្រូវចំពោះមជ្ឈដ្ឋានអ្នកបោះឆ្នោត ។ ក្នុងអនាគតដ៏ខ្លី ដោយសារមានកំណើនសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ឬក៏ប្រហែលមានទាំងកំណើនលំហូរធនធានទៅឃុំ/សង្កាត់ផង ពួកគេអាចមានលទ្ធភាពកាន់តែច្រើនដើម្បីដោះស្រាយតំរូវការនៅកំរិតមូលដ្ឋានខ្សែ រយៈគណនេយ្យភាពពីលើចុះក្រោម គឺមានសារៈសំខាន់ ដើម្បីលើកកំពស់ដំណើរការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន ។

> ***ជំរើសគោលនយោបាយមួយដើម្បីលើកកំពស់គណនេយ្យភាពពីលើចុះ ក្រោមរបស់អ្នកដឹកនាំដែលជាប់ឆ្នោតនៅមូលដ្ឋាន ចំពោះមជ្ឈដ្ឋានអ្នកបោះឆ្នោត គឺការផ្លាស់ប្តូរទិដ្ឋភាពដូចខាងលើនៃច្បាប់បោះឆ្នោត ។***

*ជំរើសគោលនយោបាយមួយដើម្បីលើកកំពស់គណនេយ្យភាពពីលើចុះក្រោមរបស់អ្នកដឹកនាំដែលជាប់ឆ្នោតនៅមូលដ្ឋាន ចំពោះមជ្ឈដ្ឋានអ្នកបោះឆ្នោត គឺការផ្លាស់ប្តូរទិដ្ឋភាពដូចខាងលើនៃច្បាប់បោះឆ្នោត ។*

ទិដ្ឋភាពមួយទៀតនៃគណនេយ្យ ភាពគឺ ការងាររបស់ប្រធានភូមិ និងស្មៀន ឃុំ/សង្កាត់ ។ បច្ចុប្បន្ននៅកំរិតឃុំ/សង្កាត់ គឺមានបុគ្គលិកតែពីរប្រភេទនេះទេ ដែលជាមន្ត្រីនៃក្រសួងមហាផ្ទៃ(MOI) ។ ក្នុងអន្តរកាលទៅកាន់អាជ្ញាធរមូលដ្ឋាន ដែលជ្រើសតាំងតាមការបោះឆ្នោតការរៀបចំ ដូច្នេះប្រហែលមានសារៈសំខាន់ ដើម្បីធានានិរន្តរភាពនៅកំរិតមូលដ្ឋាន ប៉ុន្តែវារាំងស្ទះដល់គណនេយ្យភាពនៃអ្វីដែលគេហៅថា "ការិយាធិបតេយ្យ" នៅឃុំ/សង្កាត់ ចំពោះសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដែលជាប់ឆ្នោត ។ បទពិសោធន៍ក្នុងប្រទេសឯទៀតៗ[4] បង្ហាញថា កង្វះគណនេយ្យភាពនៃការិយាធិបតេយ្យចំពោះថ្នាក់ដឹកនាំដែលជាប់ឆ្នោតនៅមូលដ្ឋាន គឺជាឧទាហរណ៍នៃវិមជ្ឈការមួយដែលដំណើរការ "មិនសូវល្អ" ។

*ជំរើសគោលនយោបាយមួយដើម្បីលើកកំពស់គណនេយ្យភាពនៃការិយាធិបតេយ្យ ចំពោះថ្នាក់ដឹកនាំដែលជាប់ឆ្នោត គឺអាចពិនិត្យពីលទ្ធភាពបោះឆ្នោតជ្រើសប្រធានភូមិ (ស្របតាម LAMC) និងធានាឱ្យមានខ្សែរយៈគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ/សង្កាត់ មិនមែនចំពោះរដ្ឋាភិបាលមជ្ឈិមទេ ។ ជំរើសមួយទៀតគឺ រដ្ឋាភិបាលមជ្ឈិមអាចធ្វើការតែងតាំងប្រធានភូមិឡើងវិញ ដោយកំណត់ឱ្យគាត់ក្លាយជានិយោជិតរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ។ រឿងនេះ អាចធ្វើបានយ៉ាងឆាប់ ពីព្រោះចាប់ពីឆ្នាំ ២០០៤ តទៅ ប្រាក់បៀវត្សរ៍របស់ប្រធានភូមិនឹងត្រូវយកពីក្នុង CSF ។ ស្មៀនឃុំ/សង្កាត់ក៏ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ/សង្កាត់ដូចគ្នា ។ ប៉ុន្តែពេលនេះអាចឆាប់ហួសពេក បើសិនអនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ជួលប្រើស្មៀនឃុំ/សង្កាត់ ដោយសារមានបញ្ហាដ៏សំខាន់នៃនិរន្តរភាពនៅកំរិតឃុំ/សង្កាត់ និងកង្វះសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដើម្បីធ្វើការពិចារណាលើសមត្ថភាពរបស់ស្មៀនឃុំ/សង្កាត់ ។ តាមការគួបឃុំ/សង្កាត់បញ្ចូលគ្នា ដែលមានតំរូវការខ្លាំង និងដែលគេកំពុងទន្ទឹងចាំឃុំ/*

*សង្កាត់ថ្មីធំៗជាងមុននឹងផុសឡើង ហើយសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ក៏នឹងមានសមត្ថភាពច្រើនជាងមុនដែរ ដូច្នេះក្រុមប្រឹក្សាឃុំ/សង្កាត់ប្រហែលអាចជ្រើសតាំង និងជួលប្រើស្មៀនឃុំ/សង្កាត់បាន។ ប៉ុន្តែរឿងនេះមិនអាចធ្វើបានក្នុងអនាគតដ៏ខ្លីទេ ។ ក្នុងពេលកំពុងរង់ចាំនេះត្រូវតែពិចារណាពីជំរើសផ្សេងៗទៀត ដើម្បីធានាឱ្យស្មៀនឃុំ/សង្កាត់មានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ/សង្កាត់ ។*

បញ្ហាប្រឈមចំបងមួយទៀតដែលជាប់ទាក់ទងនឹងក្របខ័ណ្ឌច្បាប់គឺ *កង្វះគោលនយោបាយជារួមមួយសំរាប់ចង្អុលទិសដល់កំណែទំរង់* ។ ជារឿយៗគោលនយោបាយកកើតមុនច្បាប់ និងបានចង្អុលទិសដល់ការកសាងក្របខ័ណ្ឌច្បាប់ ។ ទោះយ៉ាងនេះក្តី គោលនយោបាយមិនមែនសុទ្ធតែត្រូវកើតមុនច្បាប់រាល់ៗលើកនោះទេ ។ គេអាចដំណើរការបានដោយគ្មានគោលនយោបាយនាំមុខ ប៉ុន្តែវាអាចពិបាកជាង ។

កម្ពុជាបានធ្វើសេចក្តីប្រកាសពីគោលនយោបាយមួយ[៥] (ព្រមទាំងច្បាប់និងអនុក្រឹត្យ) បញ្ជាក់ពីគោលដៅ ៣ ធំៗ សំរាប់តំរង់ទិសកំណែទំរង់វិមជ្ឈការ ។ គោលដៅទាំង៣ លើកពីចំណុចចំបងមួយគឺ របបប្រជាធិបតេយ្យមានការចូលរួមពហុបក្ស ដែលនឹងនាំឱ្យមានការកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនការផ្តល់សេវា និងវិនិយោគនៅមូលដ្ឋាន ។ តើសេចក្តីប្រកាសពីគោលនយោបាយ វាខុសគ្នាយ៉ាងណាអំពីគោលនយោបាយ។ សេចក្តីប្រកាសពីគោលនយោបាយគឺ ជាការបញ្ជាក់ពីគោលបំណង ។ វាប្រាប់យើងពីអ្វីដែលរដ្ឋាភិបាលចង់សំរេចឱ្យបានតាមរយៈកំណែទំរង់ ប៉ុន្តែវាប្រាប់តិចតួចណាស់ថា តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីសំរេចរឿងនេះបាន ។ គោលនយោបាយកំណត់ចេញនូវរបៀបវារៈ ។ គោលនយោបាយវិមជ្ឈការអនុញ្ញាតឱ្យអ្នកកសាងគោលនយោបាយ ចូលពាក់ព័ន្ធយ៉ាងពេញលេញក្នុងកំណែទំរង់វិមជ្ឈការ និងផ្តល់ការណែនាំដ៏ចាំបាច់ផ្សេងៗដូចជា តើកំណែទំរង់ត្រូវចាប់ដំណើរការយ៉ាងណា, តើស្ថាប័នណាខ្លះត្រូវនាំមុខគេ, និងតើមានខ្សែរយៈអ្វីខ្លះសំរាប់តភ្ជាប់ស្ថាប័ននានា ។ តាមរយៈនេះគោលនយោបាយវិមជ្ឈការអាចផ្តល់ការណែនាំច្បាស់លាស់ជាងពីតួនាទីរបស់ស្ថាប័ននានា, សហប្រតិបត្តិការរវាងឃុំ/សង្កាត់ផ្សេងៗ, ចក្ខុវិស័យសំរាប់ឃុំ/សង្កាត់ ស្រុក និងខេត្ត, កិច្ចសហការតាមវិស័យ ។ល។

បច្ចុប្បន្ន សេចក្តីសំរេចបែបនេះភាគច្រើនគឺទុកអោយខាងការិយាធិបតេយ្យជាអ្នកធ្វើ ហើយបើសិនគ្មានគោលនយោបាយទេ សេចក្តីសំរេចខ្លះប្រហែលធ្វើមិនកើតឡើយ ។ ជាការត្រឹមត្រូវហើយដែលអ្នកកសាងគោលនយោបាយអង្គុយនៅក្នុង NCSC ហើយចងក្រងច្បាប់ផ្សេងៗ ប៉ុន្តែពួកគេមិនបានចូលរួមវែងឆ្ងាយទៀតទេ ក្នុងការកសាងចក្ខុវិស័យដ៏ចាំបាច់នានាសំរាប់តំរង់ទិសកំណែទំរង់ ។ គោលនយោបាយអាចអនុញ្ញាតឱ្យរដ្ឋាភិបាលធ្វើការដឹកនាំកាន់តែរឹងប៉ឹងក្នុងកំណែទំរង់វិមជ្ឈការ ។ ក្នុងពេលនេះ ពួកការិយាធិបតេយ្យត្រូវដោះស្រាយជាមួយនឹងការផ្តល់សញ្ញាប្រទាំងប្រទើសនិងខុសៗគ្នារបស់អ្នកផល់ជំនួយដែលមិនសូវច្បាស់លាស់ខ្លួនឯងដែរទេថា តើរដ្ឋាភិបាលចង់ធ្វើកំណែទំរង់ទៅខាងណា ។

*ក្នុងស្ថានភាពកម្ពុជា កន្លងមកគេចាំបាច់ត្រូវធ្វើឱ្យកំណែទំរង់មានដំណើរការ ហើយប្រហែលមិនត្រូវរង់ចាំនូវដំណើរការកំណត់គោលនយោបាយដ៏វែងនោះទេ។ ប៉ុន្តែសព្វថ្ងៃ ប្រហែលដល់ពេលដែលរដ្ឋាភិបាលត្រូវចាប់ផ្តើមពិចារណាពីតំរូវការកសាងថែមទៀតនូវសេចក្តីប្រកាសពីគោលនយោបាយតាមរយៈដំណើរការកំណត់គោលនយោបាយឱ្យបានកាន់តែគ្រប់ជ្រុងជ្រោយថែមទៀត ។ រឿងនេះអនុញ្ញាតឱ្យរដ្ឋាភិបាលធ្វើសេចក្តីសំរេចជាទូទៅមួយចំនួនទៀត ដូចជា តើគួរគួបឃុំ/សង្កាត់ចូលគ្នាឬទេ, តើមានគោលការណ៍អ្វីសំរាប់តំរង់ទិសដំណើរការនេះ, និងតើកំណែទំរង់វិមជ្ឈការនិង វិសហមជ្ឈការគួរចាត់ទុកជាដំណើរការតែមួយជាជាងដំណើរការពីរដាច់គ្នាឬយ៉ាងណា ។*

***ការតាក់តែងរចនាខាងស្ថាប័ន***

បញ្ហាប្រឈមក្រុមចំបងទី២ អាចឱ្យឈ្មោះជា ការតាក់តែងរចនាខាងស្ថាប័ន ។ នៅកម្ពុជា *ការកំណត់ថា វិមជ្ឈការនិងវិសហមជ្ឈការ គឺជាដំនើរការពីរដាច់ពីគ្នា និងមិនមែនជាដំណើរការជាប់ទាក់ទងគ្នាចុះឡើងទេ* បាននាំឱ្យមានការបែងចែកតួនាទីរវាងគណៈកម្មាធិការអន្តរក្រសួងដាច់ដោយឡែកពីគ្នា (ឧ. គណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC) និងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR) ហើយអ្នកផ្តល់ជំនួយច្រើនគាំទ្រតែមួយមិនមែនទាំងពីរទេ ។ រឿងនេះនាំឱ្យមានការលំបាកនៅក្នុងរដ្ឋាភិបាលនិងក្នុងចំណោមអ្នកផ្តល់ជំនួយជាដៃគូ ក្នុងការសំរបសំរួលគំនិតផ្តួចផ្តើមនានា ។ ឥទ្ធិពលដែលគួរឱ្យស្តាយជាងគេ អាចជាដំណើរការដាច់ពីគ្នា សព្វថ្ងៃនៅកំរិតឃុំ/សង្កាត់ និងកំរិតស្រុក ដើម្បីស្វែងរកប្រភពចំណូល ។ គំរោងមួយហៅថា ការផ្តល់សេវាតាមច្រកចេញចូលតែមួយ (OWSD) ដែលជាប់ទាក់ទងនឹង Konrad Adenauer Foundation និង CAR, មានគោលដៅកែលំអ សេវានៅកំរិតស្រុក ដោយបានធ្វើការសាកល្បងក្នុងតំបន់ទីក្រុងពីរ ។ ថវិកា សំរាប់សេវាទាំងនេះគ្រោងយកចេញពីប្រភពចំណូលថ្មីៗ ។ ក្នុងពេលជាមួយ គ្នាដោយអនុវត្តបន្តតាម LAMC ដែលផ្តល់អំណាចឱ្យឃុំ/សង្កាត់អាចប្រមូល ចំណូលសំរាប់អាជ្ញាធរមូលដ្ឋានខ្លួនឯងបាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងអនុវត្តដំណើរការស្វែងរកប្រភពចំណូលជាសក្តានុពលសំរាប់អាជ្ញាធរមូលដ្ឋានផ្ទាល់ ដើម្បីបង្កើតអនុក្រឹត្យផ្តល់អាណត្តិជាក់ស្តែងឱ្យឃុំ/សង្កាត់ធ្វើការប្រមូល និងគ្រប់គ្រងពន្ធអាករមួយចំនួន ។ គោលគំនិត គឺត្រូវស្វែងរកពន្ធមួយចំនួនដែលអាចចែករំលែកគ្នារវាងខេត្ត និងឃុំ/សង្កាត់និងពន្ធមួយចំនួនទៀតដែលអាចផ្ទេរពីខេត្តទៅឱ្យឃុំ/សង្កាត់ ។ ឯគ្រោះថ្នាក់គឺអន្តរាគន៏ទាំងពីរនឹងស្ទុះស្វែងរកចំណូលក្នុងទីផ្សារតែមួយ ។ ដោយ LAMC បានកំណត់ពីអាទិភាពនៃការប្រមូលពន្ធដោយឃុំ/សង្កាត់ ដូច្នេះអ្នកពាក់ព័ន្ធជាច្រើនគេរំពឹងថា ចំណុចផ្តោតគឺ ប្រភពចំណូលសំរាប់ឃុំ/សង្កាត់មិនមែនសំរាប់ស្រុកទេ ។ ក្នុងនេះការតាក់តែងរចនាខាងស្ថាប័នដែលកាន់តែរលូនល្អថែមទៀតប្រហែលអាចជួយបញ្ចៀសដំណើរការស្របគ្នាបែបនេះបាន ។

*ដើម្បីធានាឱ្យមានដំណើរការធ្វើកំណែទំរង់កាន់តែរលូនគ្នាល្អឡើង ជំរើសមួយគឺ រដ្ឋាភិបាលអាចពិចារណាពីការកំនត់ឡើងវិញនូវទស្សនៈនៃកំណែទំរង់ឱ្យទៅជាកំណែទំរង់តែមួយនៃអាជ្ញាធរមូលដ្ឋាន ដែលមានរួមបញ្ចូលទាំងកំណែទំរង់វិមជ្ឈការ និងកំណែទំរង់វិសហមជ្ឈការដែលកំពុងធ្វើសព្វថ្ងៃ ។ ស្របគ្នានេះដែរ អាចពិចារណាដាក់កំណែទំរង់ឱ្យស្ថិតនៅក្រោមស្ថាប័នតែមួយ រីឯបញ្ហាថាតើស្ថាប័ននេះត្រូវមានប្រភេទបែបណា គឺអាចទុកឱ្យដំណើរការកសាងគោលនយោបាយវិមជ្ឈការជួយធ្វើការដោះស្រាយ ។*

សកម្មភាព និងរចនាសម្ព័ន្ធសិលា ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលហើយ ។ ប៉ុន្តែនៅមានបញ្ហាប្រឈមមួយគឺ ការធ្វើសមាហរណកម្មរចនាសម្ព័ន្ធសិលាថែមទៀត ទៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលដែលមានស្រាប់ ។ យើងប្រមើលឃើញថា សំរាប់ប៉ុន្មានឆ្នាំខាងមុខ កំណែទំរង់នឹងនៅតែត្រូវការជំនួយទ្រទ្រង់ពីក្រុមការងារកម្មវិធីសិលា (STF) និងលេខាធិការដ្ឋានរបស់ពួកគេ ពីព្រោះជំនួយទ្រទ្រង់នេះសមស្របល្អណាស់សំរាប់កំរិតជាច្រើននៃរដ្ឋាភិបាល។ នៅកំរិតមជ្ឈិម STF បានសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការអន្តរក្រសួងក្រសួងពាក់ព័ន្ធ និងអ្នកផ្តល់ជំនួយជាដៃគូនានា ។ បញ្ហាជាប់ទាក់ទិននឹងពេលអនាគតមួយអាចជាការ

ធ្វើសមាហរណកម្មរចនាសម្ព័ន្ធសិលាថែមទៀត ទៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលមជ្ឈិម ។ នៅកំរិតខេត្ត គេអាចប្រមើលឃើញថា មុខងារជួយទ្រទ្រង់ដល់ខេត្ត និងឃុំ/សង្កាត់ តាមរយៈគណៈកម្មការប្រតិបត្តិ (ExCom) នឹងមានបន្ធើ្វយ៉ាងច្រើន ប៉ុន្តែ ទៅអនាគតគេអាចដាក់បញ្ចូលវាកាន់តែច្រើនទៅក្នុងមុខងារសាលាខេត្ត ។

*ជំរើសគោលនយោបាយមួយ សំរាប់ការធ្វើសមាហរណកម្មកម្មវិធីសិលាថែមទៀត ត្រូវបានប្រមើលឃើញថា អាចធ្វើបានក្នុងរយៈពេលខ្លីនៅកំរិតខេត្ត តាមរយៈការបង្កើនតួនាទីរបស់អភិបាលខេត្តក្នុងកិច្ចសហការតាមវិស័យ ។ ការអនុវត្តន៏គំរោងសាកល្បងក្នុងវិស័យច្រើនទៀតអាចមានលក្ខណៈជាប់ទាក់ទិនល្អនៅពេលនេះ ហើយការប្រើរចនាសម្ព័ន្ធសិលាក៏អាចមានប្រយោជន៏សំរាប់រឿងនេះដែរ ។ម្យ៉ាងទៀត ការផ្លាស់ប្តូរក្នុងទូទាំងប្រទេសនូវមុខងារ និងតួនាទីរបស់អភិបាលខេត្តស្តីពីការធ្វើសមាហរណកម្ម និងការសំរួលសំរួលតាមវិស័យ ត្រូវរង់ចាំច្បាប់រៀបចំអង្គការស្តីពីវិមជ្ឈការដែលគ្រោងអនុម័តចេញនៅឆ្នាំ២០០៥ ។ បើសិនរដ្ឋាភិបាលនាអនាគតសំរេចបង្កើតក្រសួងដាច់ដោយឡែកមួយសំរាប់អាជ្ញាធរខេត្ត និងមូលដ្ឋាន, គេគួរពិចារណាពីការធ្វើសមាហរណកម្មលេខាធិការដ្ឋាន STF ថែមទៀតទៅក្នុងក្រសួងនោះ ។ ប៉ុន្តែក្រសួងនោះនឹងត្រូវមានមូលដ្ឋានមួយដ៏រឹងមាំដើម្បីអាចធ្វើការសំរបសំរួលផលប្រយោជន៏តាមវិស័យដ៏ខ្លាំងៗបាន ។*

បញ្ហាគន្លឹះមួយទៀតគឺ *ការពង្រឹងបទប្បញ្ញត្តិស្តីពីការផ្តល់ហិរញ្ញប្បទានឱ្យអាជ្ញាធរមូលដ្ឋាន* ។ បញ្ហាប្រឈមដ៏បន្ទាន់មួយ គឺ CFS ត្រូវបានគ្រប់គ្រងដោយអនុក្រឹត្យមួយដែលមានតំលៃអនុវត្តន៏ត្រឹមចុងឆ្នាំ២០០៤ ប៉ុណ្ណោះ ។ ក្រោយឆ្នាំ២០០៤ ការផ្ទេរថវិកាផ្សេងៗដែលសព្វថ្ងៃអាចជួយឱ្យមានការអភិវឌ្ឍន៏មួយចំនួននៅក្នុងមូលដ្ឋាន នឹងមានលក្ខណៈមិនច្បាស់លាស់ទេ ។

*ជំរើសគោលនយោបាយមួយ គឺការផ្តល់ក្របខ័ណ្ឌច្បាប់កាន់តែខ្ពស់ដល់មូលនិធិឃុំ/សង្កាត់ បើអាចធ្វើឡើងតាមរយៈច្បាប់គឺជាការប្រសើរ ។*

### *យន្តការនានាសំរាប់សំរេចគោលដៅកំណែទំរង់*

បញ្ហាប្រឈមក្រុមទី៣ ជាប់ទាក់ទងនឹងយន្តការសំរាប់សំរេចគោលដៅកំណែទំរង់ ។ បញ្ហាប្រឈមដ៏ធំមួយគឺ ការកសាងសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់។ កន្លងមកមានការប្រឹងប្រែងច្រើនហើយក្នុងការងារនេះដែលធ្វើឱ្យសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់បានចេះដឹងច្រើនគួរសមពីរឿងតើត្រូវគ្រប់គ្រងដំណើរការយ៉ាងណា, តើត្រូវមានអ្វីខ្លះដើម្បីជំរុញដំណើរការទៅមុខ, តើត្រូវបំពេញទំរង់អ្វីខ្លះក្នុងវដ្តធ្វើផែនការ និងថវិកា ។ កង្វះចំណេះដឹងស្ថិតលើចំនុចលំអិតៗដូចជា តើត្រូវបំពេញទំរង់យ៉ាងដូចម្តេច, តើពួកគេអាចផ្តល់អាទិភាពដល់អ្វីមួយឱ្យខ្ពស់ជាងអ្វីមួយទៀតដែរឬទេ ។ មកទល់ពេលនេះ ឃុំ/សង្កាត់បានពឹងផ្អែកយ៉ាងច្រើនលើ "យោបល់" របស់អាជ្ញាធរថ្នាក់លើៗ ។

*ជំរើសមួយដើម្បីកែលំអទាំងសមត្ថភាព និងទំនុកចិត្ត (ដែលសំខាន់ដូចគ្នា) គឺផ្តោតកាន់តែខ្លាំងឡើងលើការរៀនសូត្រតាមខ្សែផ្តេកពីអ្នកមានឋានៈស្មើដែលសំដៅកែលំអកិច្ចសហការ និងការចែករំលែកបទពិសោធន៏អន្តរសហគមន៏ ។ រឿងនេះក៏នឹងជួយបង្កើនតំរូវការអំពី និងការរកឃើញដោយសហគមន៏ នូវសមត្ថភាពណាដែលមានតំរូវការ ។ អ្នកខ្លះជជែកវែកញែកថារឿងនេះត្រូវរង់ចាំការបង្កើតសមាគមអាជ្ញាធរមូលដ្ឋាន ដែលជាដំណើរការមានរយៈពេលវែង ដូច្នេះការរៀនសូត្រពីអ្នកមានឋានៈស្មើ និងការចែករំលែកពត៌មានតាមខ្សែផ្តេក អាចជាច្រកមួយសំរាប់កសាងសមត្ថភាពរបស់អាជ្ញាធរ ក៏ដូចជាតួអង្គនានាដែលកំពុងស្វែងរកតួនាទីមានលក្ខណៈជាប់ទាក់ទងល្អដើម្បីជួយបំពេញនៅក្នុងកំណែទំរង់វិមជ្ឈការ ។*

ទិដ្ឋភាពសំខាន់បំផុតមួយនៃការកែលំអរបបប្រជាធិបតេយ្យនៅមូលដ្ឋានត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកំណែទំរង់តាមរយៈ *ដំណើរការធ្វើផែនការគ្រប់ជ្រុងជ្រោយសំរាប់ផែនការអភិវឌ្ឍន៏ឃុំ/សង្កាត់* (CDP) ដែលសំដៅផ្លាស់ប្តូរចិត្តគំនិតរបស់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ឱ្យងាកទៅអនុវត្តដំណើរការមានការចូលរួម ។ ថ្វីបើវិធីនេះជាចំណែកដ៏សំខាន់បំផុតមួយនៃនីតិវិធីកសាងរបបប្រជាធិបតេយ្យនៅមូលដ្ឋានក្តី ប៉ុន្តែវាបង្កើតការរំពឹងទុកមួយចំនួនដែលក្រុមប្រឹក្សាឃុំ/សង្កាត់ ពិបាកបំពេញឱ្យបាន ហើយវាក៏មានលក្ខណៈគ្រប់ជ្រុងជ្រោយខ្លាំងណាស់ បើធៀបនឹងអ្វីដែលបានទទួលបាននៅកំរិតឃុំ/សង្កាត់ ។ ក្នុងនេះដំណោះស្រាយមិនមែនការធ្វើឱ្យដំណើរការមានលក្ខណៈសាមញ្ញនោះទេ (ពីព្រោះវាជាគ្រឿងផ្សំមួយដ៏សំខាន់សំរាប់ការកសាងរបបប្រជាធិបតេយ្យនៅមូលដ្ឋាន) ប៉ុន្តែគឺការបង្កើនលំហូរមូលនិធិដ៏ចាំបាច់ៗសំរាប់ជួយគាំទ្រវា ។ តាមមតិអ្នកជាប់ពាក់ព័ន្ធនៅគ្រប់កំរិតរដ្ឋាភិបាលដែលបានឆ្លើយសំភាសន៏ក្នុងពេលធ្វើការសិក្សានេះ លំហូរមូលនិធិយ៉ាងទៀងទាត់ និងកាន់តែច្រើន គឺត្រូវតែមានជាស្រេចនៅឆ្នាំ២០០៤ និង២០០៥នេះ។ កង្វះមូលនិធិរបស់រដ្ឋាភិបាលនៅឆ្នាំ២០០៣ ដោយសារការបះបោរប្រឆាំងស្ថានទូតថៃ, ឥទ្ធិពលនៃជំងឺ SARS, និងចំនាយលើការបោះឆ្នោត បានប៉ះពាល់ជាខ្លាំងដល់ការបើកផ្តល់មូលនិធិ ដែលជាចំណែករបស់រដ្ឋាភិបាលនៅក្នុងមូលនិធិឃុំ/សង្កាត់ (CSF) ។ ដូច្នេះបន្ទុកក៏ធ្លាក់ទៅលើឃុំ/សង្កាត់ និងវិស័យឯកជននៅមូលដ្ឋានដែលជាទូទៅរកគិតមិនយល់សោះថា ហេតុអ្វីបានជាមូលនិធិមិនហូរចុះមក ។ ឥទ្ធិពលរយៈពេលវែងដ៏ធ្ងន់ធ្ងរគឺទំនុកចិត្តរបស់ប្រជាជននិងវិស័យឯកជនចំពោះអាជ្ញាធរនៅមូលដ្ឋាន ដែលអាជ្ញាធរនេះបានចំណាយកំលាំងយ៉ាងច្រើនកសាងវាឡើង និងដែលត្រូវទទួលរងការគំរាមកំហែងដោយសារតែមូលនិធិមិនហូរចុះឱ្យបានសមស្រប ។

*ពេលនេះរដ្ឋាភិបាលជួបបញ្ហាដ៏ធ្ងន់ធ្ងរ ដោយសាររដ្ឋាភិបាលថ្មីមិនទាន់បង្កើតបាន ។ រឿងនេះក៏អាចមានផលប៉ះពាល់ខាងហិរញ្ញវត្ថុដល់ការងារអនុវត្តន៏ដែរ ។ ចំណុចសំខាន់គឺរដ្ឋាភិបាលគួរឱ្យអាទិភាពទី១ ដល់ CSF ដើម្បីរក្សាសន្ទុះជឿនទៅមុខ និងទំនុកចិត្តដែលកសាងបានហើយ កុំឱ្យវារេចរិលទៅវិញ (សំខាន់ណាស់សំរាប់ឆ្នាំ២០០៤) ។ បញ្ហារយៈពេលវែងមួយទៀត គឺត្រូវចាប់ផ្តើមស្វែងរកប្រភពចំណូលផ្ទាល់របស់អាជ្ញាធរមូលដ្ឋានដើម្បីបង្កើនភាពអាចទាយទុកមុននៃមូលនិធិឃុំ/សង្កាត់ និងធានាឱ្យមានចំណងទាក់ទងជិតស្និទ្ធ រវាងការយកពន្ធ/កំរៃសេវា និងការផ្តល់សេវាផ្សេងៗ ។*

ផ្សារភ្ជាប់នឹងចំនុចទាំងពីរខាងលើ គឺបញ្ហាគួបឃុំ/សង្កាត់បញ្ចូលគ្នាដែលជាការកាត់បន្ថយចំនួនឃុំ/សង្កាត់ ដោយពង្រីកព្រំដែនឃុំ/សង្កាត់។ ក្នុងច្បាប់មានសេចក្តីចែងពីរឿងនេះ។ លោក Blunt (2003) បានលើកថាការគួបឃុំ/សង្កាត់បញ្ចូលគ្នា គឺជាទិដ្ឋភាពដ៏សំខាន់សំរាប់ពន្លឿនការកសាងសមត្ថភាពឃុំ/សង្កាត់។ ការគួបបញ្ចូលគ្នានេះ មានបញ្ហាប្រឈម ៤ ដែលគួរគួសបញ្ជាក់ គឺមាន (១)តើស្រុកក្នុងរូបភាពដែលយើងធ្លាប់ស្គាល់អាចរួចរស់ពីការគួបឃុំ/សង្កាត់បញ្ចូលគ្នាឬទេ? សំនួរនេះជាប់ទាក់ទងនឹងអ្វីដែលអាចកើតមានឡើងចំពោះបុគ្គលិកនៅកំរិតស្រុក ។ ឧទាហរណ៏ តើយើងនឹងឃើញមានការបញ្ជូនបុគ្គលិកពីស្រុកទៅឱ្យឃុំ/សង្កាត់ឬយ៉ាងណា? ទោះបីជាគ្មានការគួបឃុំ/សង្កាត់ចូលគ្នាក្តី ក៏គេអាចបញ្ជូនបុគ្គលិកពីការិយាល័យកសិកម្មនៃស្រុកទំហំមធ្យមៗទៅតាមឃុំ/សង្កាត់នៅពេលនេះបាន ដោយមិនចាំបាច់ជ្រើសជួលបុគ្គលិកបន្ថែមទេ ។ បើមានការគួបឃុំ/សង្កាត់បញ្ចូលគ្នា គេនឹងអាចធ្វើដូច្នេះបានសំរាប់វិស័យឯទៀតៗ ។ (២)តើមានលក្ខណៈវិនិច្ឆ័យអ្វី

ខ្លះសំរាប់ប្រើក្នុងការគួបឃុំ/សង្កាត់បញ្ចូលគ្នា? បើសិនគេសន្មតថា លក្ខណៈវិនិច្ឆ័យសំខាន់ៗមួយចំនួនអាចជាសក្តានុពលខាងសេដ្ឋកិច្ចនិងវត្តមានធនធានធម្មជាតិ ដូច្នេះសំនួរគឺៈ (៣)តើកម្ពុជាមានទិន្នន័យសំរាប់ជួយដល់ការជ្រើសរើសលក្ខណៈវិនិច្ឆ័យឬទេ? ចំណុចចុងក្រោយគឺ (៤)រឿងនេះត្រូវមានការសំរបសំរួលជាមួយច្បាប់រៀបចំអង្គការស្តីពីវិមជ្ឈការដែលនឹងកំណត់ពីតួនាទី និងមុខងាររបស់ខេត្ត និងស្រុក និងដែលគ្រោងអនុម័តនៅឆ្នាំ២០០៥ ។

*ជំរើសខាងគោលនយោបាយសំរាប់រដ្ឋាភិបាលគឺ ដំបូងត្រូវមានដំណើរការមួយដែលក្នុងនេះ តួនាទីទៅអនាគតរបស់ស្រុកត្រូវបានលើកមកពិភាក្សា។ រឿងនេះផ្សារភ្ជាប់គ្នានឹងសេចក្តីសំរេចថា តើមានសេវាអ្វីខ្លះដែលអាចផ្គត់ផ្គង់ដោយឃុំ/សង្កាត់ និងដោយទីភ្នាក់ងារឯទៀត។ ដំណើរការស្វែងរកមើលប្រហែលអាចចាប់ផ្តើមនៅចុងឆ្នាំ២០០៤ និងប្រហែលអាចមានគំរោងសាកល្បងនៅចុងឆ្នាំ២០០៥ ។ ម្យ៉ាងទៀត គេត្រូវមានទិន្នន័យពីធនធានធម្មជាតិ និងសក្តានុពលសេដ្ឋកិច្ចនៅមុនពេលចាប់ផ្តើមដំណើរការកំណត់ព្រំដែនឃុំ/សង្កាត់ ។ ដូច្នេះសកម្មភាពទាំងនេះប្រហែលមិនអាចផ្តល់លទ្ធផលបានទាន់ពេល ដើម្បីអាចធ្វើការកំណត់ព្រំដែនឱ្យបានមុនអាណត្តិខាងមុខនៃក្រុមប្រឹក្សាឃុំ/សង្កាត់ដែលគ្រោងបោះឆ្នោតនៅឆ្នាំ២០០៧ នោះទេ ។ ដោយមូលហេតុនេះ រដ្ឋាភិបាលគួរកំណត់យកអាណត្តិទី៣នៃឃុំ/សង្កាត់វិញដើម្បីអាចមានពេលអនុវត្តដំណើរការទាំងនេះ ។ ក្នុងអាណត្តិទី២នៃឃុំ/សង្កាត់ និងស្របតាមប្រពៃណីនៅក្នុងកំណែទំរង់វិមជ្ឈការ, ការគួបឃុំ/សង្កាត់បញ្ចូលគ្នាអាចអនុវត្តជាការសាកល្បងក្នុងតំបន់ជ្រើសរើសមួយចំនួន ។ ការងារនេះនឹងផ្តល់ពត៌មានពីបញ្ហាចំបងៗនៃការគួបឃុំ/សង្កាត់បញ្ចូលគ្នា ព្រមទាំងជួយរដ្ឋាភិបាលឱ្យត្រៀមរៀបចំដោះស្រាយវា ។*

## ឱណាមិកនៅមូលដ្ឋាន

បញ្ហាប្រឈមក្រុមទី ៤ ជាប់ទាក់ទងនឹងស្ថានភាពនៅកំរិតឃុំ/សង្កាត់ និងសកម្មភាពជាច្រើនដែលកំពុងប្រព្រឹត្តទៅ ដើម្បីជួយលើកកំពស់តួនាទីរបស់ឃុំ/សង្កាត់ និងដែលមិនបានសំរបសំរួលគ្នាបានល្អទាំងអស់ទេ ។ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់គិតថា ខ្លួនមានឥទ្ធិពលតិចតួចណាស់ ធៀបនឹងបន្ទុកការងារដ៏ពិបាកធ្ងន់ធ្ងរ ។ រឿងនេះចោទជាពិសេសចំពោះសមាជិកជាស្ត្រី ដែលភាគច្រើនតាមការជួបពិភាក្សាជាមួយយើង គឺមិនសូវច្បាស់លាស់ក្នុងចិត្តទេពីសមត្ថភាពរបស់ខ្លួន ដើម្បីឈរឈ្មោះបោះឆ្នោតនៅលើកក្រោយទៀត ។ ពួកគេមានសមត្ថភាព ប្រហែលមិនចាញ់បុរសទេ ពីព្រោះភាគច្រើនមានបទពិសោធន៍ធ្វើការជាមួយ NGOs និងបានរៀនសូត្រយូរឆ្នាំដូចសហសេវិកជាបុរសដែរ ។ ដូច្នេះបញ្ហាចោទគឺមិនមែនកង្វះសមត្ថភាពទេ ប៉ុន្តែកង្វះលទ្ធភាពធ្វើសេចក្តីសំរេចផ្សេងៗ ។ ម្យ៉ាងទៀត ច្បាប់បានប្រគល់ឱ្យសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ជាស្ត្រីនូវការទទួលខុសត្រូវលើការងារខាងនារី និងកុមារ ដូច្នេះក៏បានកាត់បន្ថយតួនាទីរបស់ពួកគេថែមទៀត ពីព្រោះសព្វថ្ងៃសឹងតែគ្មានមូលនិធិអ្វីសោះដែលត្រូវបានបែងចែកសំរាប់បំរើសកម្មភាពនេះ។

បញ្ហាមួយទៀតគឺ ការផ្តល់មូលនិធិរបស់គណបក្សសំរាប់គំរោងអភិវឌ្ឍន៍នៅមូលដ្ឋាន ។ នៅតាមកន្លែងជាច្រើន មានការស្នើសុំឱ្យអ្នកជំនួញចូលវិភាគទានដល់គំរោងផ្តល់មូលនិធិដោយគណបក្ស ដែលក្រោយមកគេបង្ហាញវាថាជាអំណោយរបស់គណបក្ស ។ ទង្វើនេះ បានកាត់បន្ថយអារម្មណ៍ជាម្ចាស់ក្នុងចំណោមអ្នកបានចូលវិភាគទាន ហើយប្រហែលមិនបានជួយអ្វីច្រើនទេដល់ដំណើរការប្រមូលពន្ធក្នុងមូលដ្ឋានដែលគ្រោងធ្វើទៅអនាគត ។ មានករណីជាច្រើននៃ NGOs ដែលបានអនុវត្តគំរោងអភិវឌ្ឍន៍ដោយរំលងចោលក្រុមប្រឹក្សាឃុំ/សង្កាត់ ពីព្រោះការអនុញ្ញាតផ្សេងៗសំរាប់សកម្មភាពបែបនេះ ជារឿយៗត្រូវបានស្នើសុំ និងផ្តល់ឱ្យដោយអាជ្ញាធរស្រុក ឬខេត្ត ។

គេឃើញមានសញ្ញាដំបូងៗ និងដោយកន្លែងៗ នៃការធ្វើនយោបាយយ៉ាងខ្លាំងនៅកំរិតមូលដ្ឋាន ក្នុងនេះសញ្ញាមួយគឺ ការពិបាកទទួលបានការគាំទ្រ និងវិភាគទានជួយមូលដ្ឋាន ពីបុគ្គលដែលមានជំនឿលើគណបក្សនយោបាយខុសគ្នាពីលោកមេឃុំ/សង្កាត់ ។ រឿងនេះបង្ហាញថា ការមិនទុកចិត្តគ្នានៅថ្នាក់មូលដ្ឋាននៅមានកំរិតខ្ពស់នៅឡើយ ហើយប្រហែលមានការចាំបាច់ត្រូវផ្តោតកាន់តែខ្លាំងឡើងលើការកសាងនូវអ្វីដែលគេហៅថា "ចំណងខ្សោយ"។ ចំណងខ្សោយត្រូវបានកសាងឡើងតាមរយៈបណ្តាញ និងសមាគមនានា ។ កម្ពុជាជាឧទាហរណ៍នៃប្រទេសមួយដែលមាន "ចំណងខ្លាំង" ដ៏រឹងមាំដូចជាខ្សែរយៈក្រុមគ្រួសារ និងគណបក្ស ហើយសេចក្តីសំរេចរបស់បុគ្គលតែងទទួលរងឥទ្ធិពលមួយភាគធំអំពីរចនាសម្ព័ន្ធ "ចំណងខ្លាំង" ។ អ្វីដែលកម្ពុជាមិនទាន់មាន ឬមានតិចតួច គឺ "ចំណងខ្សោយ" ដូចជាសមាគម និងបណ្តាញផ្សេងៗ ដែលជាទូទៅគេច្រើនហៅថា ទីភ្នាក់ងារសំរាប់មូលធនសង្គម (agencies for social capital) ។ ស្ថាប័នចំណងខ្សោយធ្វើការងារឆ្លងកាត់បណ្តាស្ថាប័នចំណងខ្លាំង និងជួយបង្កើតបណ្តាញ និងទំនាក់ទំនងធូរទូលាយដែលអាចជួយកាត់បន្ថយការមិនទុកចិត្តគ្នា និងបង្កើនសកម្មភាពសហ គមន៍។ ស្ថានភាពបែបនេះមានតំរូវការខ្លាំងណាស់នៅក្នុងវប្បធម៌នយោបាយកម្ពុជាសព្វថ្ងៃ ។

*គណបក្សនយោបាយនានាអាចឆ្លៀតឱកាសនេះ ដើម្បីបង្កើនកូតាស្ត្រីសំរាប់តួនាទីខ្ពស់ៗក្នុងគណបក្ស និងធានាឱ្យស្ត្រីមានឥទ្ធិពលកាន់តែច្រើនឡើង ។ កំណើនការប្រើប្រាស់ក្រុមប្រឹក្សាឃុំក្នុងការបញ្ជូនធនធាន នឹងជួយកសាងភាពជាម្ចាស់នៅមូលដ្ឋាន ។ ម្យ៉ាងទៀតក៏មានតំរូវការជួយគាំទ្រដល់ការកសាងស្ថាប័នចំណងខ្សោយនានា ដើម្បីជួយបង្កើនការចូលរួមរបស់សហគមន៍ និងសកម្មភាពជួយគាំទ្រដល់ការងារក្រុមប្រឹក្សាឃុំ ។*

## កំណត់សំគាល់

១ មូលនិធិឃុំ/សង្កាត់ គឺជាមូលនិធិផ្ទេរពីរដ្ឋាភិបាលថ្នាក់ជាតិ និងអ្នកផ្តល់ជំនួយ ក្នុងនេះ RGC ផ្តល់ចំនួន ២,៥% នៃចំណូលក្នុងស្រុករបស់ខ្លួន ហើយអ្នកផ្តល់ជំនួយផ្តល់ប្រហែល ១៦% នៃមូលនិធិសរុបដែលបានផ្ទេរ ។

២ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (២០០១) និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ (២០០១) ។

៣ សូមមើលអត្ថបទរបស់លោក Robert Oberndorf ក្នុងទស្សនាវដ្តីលេខនេះដែរ ។

៤ Manor, J. 2003. *Local Governance.* Paper presented at a SIDA seminar on Good Governance. Stockholm. September 2003.

៥ Sar, K. 2002. Thematic Paper of the Deputy Prime Minister Sar Kheng at the National Symposium on Decentralisation and Local Governance on May 15-16 2002. Unpublished.

៦ ការសិក្សាបានធ្វើឡើងក្នុង ១៥ឃុំ ដែលស្ថិតក្នុង ១៥ស្រុក ក្នុង ៨ខេត្ត និងមានអ្នកពាក់ព័ន្ធនៅកំរិត ភូមិ ឃុំ ស្រុក ខេត្ត និងរដ្ឋាភិបាលមជ្ឈិម ។

៧ Blunt, P. 2003. *The Strategic Management of Capacity Building for Decentralisation and Deconcentration in the*

# បញ្ហាប្រឈមនៃកំណែទំរង់វិមជ្ឈការសារពើពន្ធនៅកម្ពុជា: ការស្វែងរកប្រភពចំណូលផ្ទាល់សំរាប់ឃុំ/សង្កាត់

នៅឆ្នាំ២០០៣ និង២០០៤ សកម្មភាពស្រាវជ្រាវរបស់កម្មវិធីស្រាវជ្រាវផ្តោត លើគោលនយោបាយស្តីពីវិមជ្ឈការ (PORDEC) បានពិនិត្យពីកំណែទំរង់វិមជ្ឈការសារពើពន្ធ ។ អ្នកស្រាវជ្រាវ អេង នេត្រា បានបូកសរុបសង្ខេប ពីរបកគំហើញមួយចំនួន ។ *

## ការរីកលូតលាស់ និងបញ្ហាប្រឈម

បច្ចុប្បន្ន ក្រុមប្រឹក្សាឃុំ/សង្កាត់កំពុងទទួលរ៉ាប់រងការទទួលខុសត្រូវថ្មីៗមួយចំនួន ។ ភារកិច្ចដ៏សំខាន់បំផុតមួយរបស់ពួកគេ គឺការផ្តល់សេវាទាំងនៅក្នុងសកម្មភាពអភិវឌ្ឍន៍ និងរដ្ឋបាល ។ កន្លងមក សេវាជាតួយ៉ាងផ្តល់ដោយក្រុមប្រឹក្សាឃុំ/សង្កាត់គឺ គំរោងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានតូចៗ ដូចជា អណ្តូង ម៉ាស៊ីនបូមទឹកស្អាត ដាក់លូ ស៊ីម៉ង់ត៍ និងគំរោងសាងសង់តូចៗមួយចំនួនទៀត ដូចជា បន្ទប់រៀន ប្រឡាយទឹក និងបង្គន់សាធារណៈ ។

ខាងផ្នែកចំនូល ក្រុមប្រឹក្សាឃុំ/សង្កាត់សព្វថ្ងៃមានប្រភពមូលនិធិ ៣ សំខាន់ៗ ។ ទី១ មាត្រា៧៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (LAMC) បញ្ជាក់ពីសិទ្ធិរបស់ឃុំ/សង្កាត់ដើម្បីទទួលចូលថវិកាខ្លួននូវអំណោយផ្ទេរពីថវិកាជាតិ ។ ច្បាប់ក៏តំរូវឱ្យរដ្ឋាភិបាលមជ្ឈិមបង្កើតមូលនិធិឃុំ/សង្កាត់ (CSF) ដែលអាចប្រើសំរាប់ទទួលប្រាក់បញ្ញើ និងជាប្រភពនៃការផ្ទេរមូលនិធិសំរាប់ឃុំ និងសង្កាត់ ។ CSF មានរួមបញ្ចូលទាំងការផ្ទេរនានាអំពីថវិកាជាតិ និងអំពីទុនរបស់ម្ចាស់អំណោយសំរាប់ថ្នាក់ឃុំ/សង្កាត់ដែលត្រូវបានកំណត់មុខសញ្ញាសំរាប់ការងារអភិវឌ្ឍន៍ និងរដ្ឋបាល ។ ប្រភពមូលនិធិទី២ គឺប្រាក់កំរៃបានពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងប្រាក់កំរៃ/ប្រាក់ទូទាត់ដ៏សមស្របមួយចំនួនទៀតដល់ឃុំ/សង្កាត់ចំពោះការដើរតួនាទី ជាទីភ្នាក់ងារបំពេញមុខងារមួយចំនួនដែលក្រសួង និងស្ថាប័នផ្សេងទៀតផ្ទេរសិទ្ធិមកឱ្យ ។ សព្វថ្ងៃ ចំនូលដែលឃុំ/សង្កាត់ទទួលបានពីការបំពេញមុខងារជាទីភ្នាក់ងារ គឺមានតែប្រាក់កំរៃលើការចុះបញ្ជីអត្រានុកូលដ្ឋានមួយមុខគត់ ដែលមានចំនួនតិចតួចបំផុត ។ ក្នុងពេលរង់ចាំការចេញបទប្បញ្ញត្តិដ៏ចាំបាច់នានាសំរាប់គាំទ្រច្បាប់ ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំ/សង្កាត់ (LAMC) ឃុំមានសិទ្ធិទទួលមូលនិធិប្រភេទទី៣ ដែលជាចំនូលពីប្រភពរបស់ខ្លួន តាមរយៈការប្រមូលចំណូលពន្ធ ចំណូលមិនមែនពន្ធ និងកំរៃលើសេវា ។ ក្នុងពេលនេះ ឃុំ/សង្កាត់គ្មានប្រមូលពន្ធអ្វីទេ ក្រៅតែពីវិភាគទានក្នុងមូលដ្ឋានសំរាប់គំរោងអភិវឌ្ឍន៍ ។ វិភាគទានក្នុងមូលដ្ឋានចំពោះគំរោងផ្តល់ទុនដោយ CSF អាចចាត់ទុកជាដំណាក់កាលទី១ នៅក្នុងប្រព័ន្ធប្រមូលពន្ធនៅមូលដ្ឋាន ។

*សព្វថ្ងៃ ចំនូលដែលឃុំ/សង្កាត់ទទួលបានពីការបំពេញមុខងារជាទីភ្នាក់ងារគឺមានតែប្រាក់កំរៃលើការចុះបញ្ជីអត្រានុកូលដ្ឋានមួយមុខគត់ដែលមានចំនួនតិចតួចបំផុត ។*

ពីរឆ្នាំក្រោយការបោះឆ្នោតឃុំ ក្រៅពីការពិភាក្សាពីប្រភពចំនូលរបស់ឃុំ/សង្កាត់ ដូចបានរៀបរាប់ខាងលើ គេឃើញមានសេចក្តីសំរេច និងការរីកចំរើនតិចតួចណាស់ក្នុងការកសាងគោលការណ៍ណែនាំ និងបទប្បញ្ញត្តិផ្សេងៗដើម្បីអនុញ្ញាតអោយឃុំ/សង្កាត់ប្រមូលចំនូលពីប្រភពផ្ទាល់របស់ខ្លួន ។

មានបញ្ហាច្រើនដែលធ្វើឱ្យដំណើរការនេះយឺតយ៉ាវ ហើយសំខាន់បំផុតគឺកង្វះពត៌មាន និងទិន្នន័យសំរាប់ជួយកំណត់នូវប្រភពចំនូលផ្ទាល់ជាសក្តានុពលរបស់អាជ្ញាធរមូលដ្ឋាន និងប្រភពចំណូលជាមុខសញ្ញាសំរាប់ផ្ទេរពីខេត្តទៅឱ្យឃុំ ឬសំរាប់បែងចែករវាងខេត្ត និងឃុំ/សង្កាត់ ។ ឧទាហរណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (LAMC) ផ្តល់អំណាចឱ្យឃុំ/សង្កាត់ប្រមូលពន្ធដី ពន្ធលើអចលនទ្រព្យ ពន្ធលើថ្លៃជួលទ្រព្យ និងកំរៃលើអ្នកប្រើប្រាស់សេវា ប៉ុន្តែអនុក្រឹត្យផ្សេងៗសំរាប់កំណត់អាណត្តិពិតប្រាកដ មិនទាន់អនុម័តចេញនៅឡើយទេ ។ កិច្ចពិភាក្សានៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំនត់ពន្ធជាសក្តានុពលមួយចំនួនដែលឃុំ/សង្កាត់ អាចប្រមូលយកបានជាអាទិ៍ ពន្ធលើដីមិនបានប្រើប្រាស់ ពន្ធលើមធ្យោបាយដឹកជញ្ជូន ពន្ធប៉ាតង់ ពន្ធលើសត្តឃាតដ្ឋាន វិភាគទានសំរាប់ការងារកែលំអ ពន្ធលើសេវាលំហែកំសាន្ត និងការបែងចែកអាករលើផលរបរ និងអាករលើតំលៃបន្ថែម (VAT) ។ នៅមានប្រភពមូលនិធិជាសក្តានុពលច្រើនទៀតក្នុងនេះមានទាំងប្រាក់កំរៃលើសេវាផ្សេងៗផង ។

មានការព្រួយបារម្ភមួយចំនួនអំពីប្រភេទពន្ធ ដោយសារលទ្ធភាពមានទំនាស់ផលប្រយោជន៍រវាងស្ថាប័នផ្សេងៗ ។ ពន្ធដែលប្រហែលត្រូវជួបការជំទាស់ពីថ្នាក់ជាតិ គឺមានពន្ធលើទ្រព្យសម្បត្តិ និងដីធ្លី ពីព្រោះវាប៉ះពាល់ដល់គោលនយោបាយមិនយកពន្ធលើ ដីស្រែ និងទ្រព្យសម្បត្តិកសិកម្ម ។

ទិដ្ឋភាពទីពីរដែលបន្ថយល្បឿន ដំនើរការស្វែងរកប្រភពចំនូលផ្ទាល់របស់អាជ្ញាធរមូលដ្ឋានគឺ ការយកពន្ធក្រៅផ្លូវការក្នុងពេលសព្វថ្ងៃ ។ ដោយសាររឿងនេះ ការបង្កើតពន្ធអាករជាផ្លូវការអាចនាំឱ្យមានការយកពន្ធ "ពីរដង" ដែលនឹងក្លាយជាបន្ទុកមួយទៀតសំរាប់អ្នកក្រ ។ ដូច្នេះបញ្ហាប្រឈមគឺ ការស្វែងរកពន្ធអាករដែលអាចប្រមូលយកបានក្នុងស្ថានភាពបច្ចុប្បន្ន ដោយចៀសវាងការយកពន្ធពីរដង ។ ម្យ៉ាងទៀតការពង្រីកថែមនូវការយកពន្ធ និងកំរៃសេវា ត្រូវរង់ចាំផងដែរនូវការប្រតិបត្តិកាន់តែប្រសើរនូវច្បាប់ជាទូទៅ ហើយរឿងនេះអាស្រ័យលើការពង្រឹងគណនេយ្យភាពនៅកំរិតមូលដ្ឋាន ។ នេះជាបញ្ហាប្រឈមចំបងមួយ ដែលមិនងាយដោះស្រាយទេ និងដែលធំហួសពីលទ្ធភាពដោះស្រាយនៃកំណែទំរង់វិមជ្ឈការសារពើពន្ធ ។

បញ្ហាប្រឈមទីបីគឺ តើចំនូលពីប្រភពរបស់ខ្លួនផ្ទាល់ទាំងអស់នេះត្រូវចាត់ចែងធ្វើយ៉ាងដូចម្តេច ។ នេះជាបញ្ហាទាំងខាងភស្តុភារ (ដោយសារកង្វះហិបប្រាក់បញ្ញើមានសុវត្ថិភាពនៅតាមឃុំ/សង្កាត់ និងកង្វះប្រព័ន្ធធនាគារថ្នាក់ឃុំ) និងខាងសមត្ថភាព (គ្មានគណនេយ្យករសំរាប់ឃុំ/សង្កាត់ទេ) ។

---

* អត្ថបទនេះផ្អែកលើបទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហាប្រឈមនៃការតាក់តែងរចនាវិមជ្ឈការដែល វបសអ រៀបចំធ្វើនៅសណ្ឋាគារ សាន់វេ នាថ្ងៃ ២៩ មករា ២០០៤ ឯរបាយការណ៍ពេញលេញចងក្រងជាឯកសារពិភាក្សាដោយៈ Rusten *et al. (2004)* ។ ពត៌មានសំរាប់អត្ថបទនេះ ដកស្រង់ផងដែរពីការងារសព្វថ្ងៃរបស់ MEF, UNCDF និង CDRI ដើម្បីពិនិត្យមើលពីរចនាសម្ព័ន្ធពន្ធ ដែលមានស្រាប់ និងប្រភពពន្ធជាមុខសញ្ញាសំរាប់បែងចែករវាងខេត្ត និងឃុំ ។

បច្ចុប្បន្ន មានគំរោងសាកល្បងមួយចំនួនកំពុងដំណើរការតាមជំរើសទាំងពីរខាងលើនេះ ដើម្បីបង្កើនគណនេយ្យភាពខាងសារពើពន្ធ ។ មូលនិធិអភិវឌ្ឍន៍មូលធននៃអង្គការសហប្រជាជាតិ (UNCDF) នឹងជួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឆ្នាំ២០០៤/២០០៥ ដើម្បីធ្វើគំរោងសាកល្បងទៅលើប្រព័ន្ធធនាគារឃុំ/សង្កាត់ (ជំរើសទី១) និងការិយាល័យរតនាគារស្រុក (ជំរើសទី២) ដើម្បីចៀសវាងការផ្ញើប្រាក់នៅខេត្តដូចក្នុងពេលសព្វថ្ងៃ ។

បញ្ហាប្រឈមទី៤ ជាប់ទាក់ទងនឹងសមត្ថភាព និងឆន្ទៈរបស់រដ្ឋាភិបាលមជ្ឈិមដើម្បីដោះស្រាយកំណត់ប្រភពចំនូលផ្ទាល់របស់អាជ្ញាធរមូលដ្ឋាន និងជំរើសផ្សេងៗទៀតសំរាប់ការបែងចែកចំនូល និងការផ្ទេរចំណូលរវាងខេត្ត និងឃុំ ។ គំរោងការផ្តល់សេវាតាមច្រកចេញចូលតែមួយ (OWSD) បានធ្វើអោយដំណើរការនេះពិបាកមួយកំរិត ដោយសារសព្វថ្ងៃគេមិនច្បាស់លាស់សោះថាតើរដ្ឋាភិបាលនឹងអនុញ្ញាតអោយមានការផ្ទេរ/ការបែងចែកចំណូលឡើងវិញរវាង (១) ខេត្ត និង ស្រុក ឬក៏ (២) រវាងខេត្ត និងឃុំ ។

ម្យ៉ាងទៀត បញ្ហាប្រឈមជាទូទៅមួយក្នុងដំណើរការបែបនេះគឺ ការសំរបសំរួលរវាងស្ថាប័ននានានៅថ្នាក់ជាតិ ។ សេចក្តីសំរេចឱ្យអនុវត្តទៅមុខនូវផែនការឱ្យឃុំ/សង្កាត់មានប្រភពចំនូលផ្ទាល់ គឺថ្នាក់ជាតិជាអ្នកធ្វើ ហើយវាអាស្រ័យលើកិច្ចព្រមព្រៀងរវាងគណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC) និងក្រសួងពាក់ព័ន្ធនានា ។ ការងារពង្រឹងហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋានត្រូវតែដឹកនាំ និងគ្រប់គ្រងដោយរដ្ឋាភិបាលមជ្ឈិមដ៏រឹងមាំមួយ ។

*ប្រភពចំនូលជាសក្តានុពលសំរាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ គឺមានប្រាក់កំរៃយកពីអ្នកប្រើប្រាស់នូវសេវាដែលផ្តល់ដោយក្រុមប្រឹក្សាឃុំ និងការប្រមូលពន្ធពីមូលដ្ឋានយកពន្ធសាមញ្ញៗ និងអាជីវកម្មខ្នាតតូច ។*

## ការប្រមូលពន្ធបច្ចុប្បន្ន

នាបច្ចុប្បន្នមាន ពន្ធ អាជ្ញាប័ណ្ណ ប្រាក់កំរៃ និងថ្លៃសេវាផ្សេងៗជាច្រើន ដែលប្រមូលយកនៅកំរិតឃុំ/សង្កាត់ ។ ភាពខុសគ្នារវាងពន្ធប្រាក់កំរៃ ឬថ្លៃសេវា និងអាជ្ញាប័ណ្ណ គឺមិនច្បាស់លាស់ទេ ។ ការប្រមូលយកមួយចំនួនគេហៅថាថ្លៃសេវា ប៉ុន្តែតាមពិតគឺជាពន្ធ ពីព្រោះពុំមានការផ្តល់សេវាណាមួយដោយផ្ទាល់ ឬដោយប្រយោលទៅឱ្យអ្នកបង់ប្រាក់ទាំងនេះទេ ។ ម្យ៉ាងទៀត នៅមានប្រាក់កំរៃផ្សេងៗជាច្រើន សំរាប់ទំរង់បែបបទ និងលិខិតអនុញ្ញាតនានា ។ សព្វថ្ងៃមានពន្ធផ្លូវការ ៦ប្រភេទ ដែលសាលាខេត្តប្រមូលយកសំរាប់ថវិកាខេត្ត គឺមាន ពន្ធប៉ាតង់ ពន្ធលើមធ្យោបាយដឹកជញ្ជូន ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធលើសត្តឃាតដ្ឋាន ពន្ធលើការផ្ទេរកម្មសិទ្ធិ និងពន្ធលើការបំភ្លឺសាធារណៈ ។ នៅឆ្នាំសារពើពន្ធ២០០៣ ចំណូលពីប្រភពពន្ធទាំងនេះគឺ ២១៣លានរៀលសំរាប់ខេត្តតាកែវ, ២.២៩៩លានរៀលសំរាប់ខេត្តសៀមរាប និង ៧.៦៦៨លានរៀលសំរាប់រាជធានីភ្នំពេញ[១] ។

## ការគ្រប់គ្រង និងរចនាសម្ព័ន្ធនៃការប្រមូលពន្ធបច្ចុប្បន្ន

មន្ទីរពន្ធដារខេត្ត/ក្រុង គឺជាទីភ្នាក់ងារតែមួយគត់ដែលទទួលខុសត្រូវលើការប្រមូលពន្ធ ហើយក្នុងការប្រមូលពន្ធជាក់ស្តែងគឺ មានការិយាល័យពន្ធដារស្រុកជួយប្រមូលនៅកំរិតស្រុក ។ ប្រាក់ចំនូលដែលប្រមូលបានទាំងអស់ត្រូវបានផ្ទេរចូលទៅក្នុងរតនាគារខេត្ត ។ មន្ទីរជំនាញផ្សេងទៀតមានប្រមូលប្រាក់កំរៃ និងថ្លៃសេវាមួយចំនួននៅកំរិតឃុំ/សង្កាត់ ។ ផ្អែកទៅតាមប្រភេទរបស់វា ពន្ធខ្លះត្រូវបានបែងចែករវាងអ្នកពាក់ព័ន្ធផ្សេងៗដូចជា ថ្នាក់មជ្ឈិម ខេត្ត និងឃុំ-សង្កាត់ ។ ការប្រមូលពន្ធភាគច្រើន គឺជាការទទួលខុសត្រូវរបស់នាយកដ្ឋានពន្ធដារ ។

ក្នុងការអនុវត្តន៍ជាក់ស្តែង អង្គការចាត់តាំងសំរាប់ការប្រមូលពន្ធគឺអាស្រ័យទៅតាមប្រភេទពន្ធ និងកន្លែងប្រមូលពន្ធ ។ សំរាប់ពន្ធខ្លះ និងតំបន់ខ្លះមានការផ្ទេរសិទ្ធិឱ្យបុគ្គលិកថ្នាក់ស្រុកធ្វើការប្រមូល, រីឯពន្ធខ្លះ និងតំបន់ខ្លះទៀត បុគ្គលិករបស់ខេត្ត និងមជ្ឈិម ប្រមូលពន្ធចំរុះគ្នា ។ ម្យ៉ាងទៀត មានប្រាក់កំរៃ និងថ្លៃសេវាមួយចំនួន ត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុនឯកជនធ្វើការប្រមូល (ការប្រមូល "ភាស៊ី" ពីទីផ្សារ និងសត្តឃាតដ្ឋាន) ។ ការបែងចែកភារកិច្ចរវាងអាជ្ញាធរថ្នាក់ផ្សេងៗ គឺជាបញ្ហាប្រឈមមួយ ពីព្រោះអាជ្ញាធរថ្នាក់ក្រោមជាតិនីមួយៗបានចូលរួមក្នុងការប្រមូលពន្ធ ។ ទាំងអ្នកប្រមូលពន្ធខ្លួនឯង ទាំងអ្នកបង់ពន្ធ គឺមិនបានដឹងច្បាស់ទេថា តើស្ថាប័នណាក្តោបក្តាប់[២]ការទទួលខុសត្រូវជាក់ស្តែង លើការប្រមូលពន្ធប្រភេទខុសៗគ្នាទាំងនេះ ។ ការចូលរួមដ៏ធំទូលំទូលាយបែបនេះ បានបង្កើតច្រកសំរាប់ការស្វែងរកកំរៃ ។ មន្ត្រីដែលចូលពាក់ព័ន្ធក្នុងការប្រមូលពន្ធបានស្វះស្វែងរកផលចំណេញសំរាប់ខ្លួនឯង ក្នុងរូបភាពជាការបង់ប្រាក់សំរាប់ការទទួលខុសត្រូវរបស់ពួកគេដែលជារឿយៗ គឺជាការទទួលខុសត្រូវដែលពួកគេបានជ្រៀតខ្លួនចូល (ជារឿយៗតាមរយៈការបង់ប្រាក់) ដើម្បីបានទទួលផលចំណេញ ។

ប្រាក់ពន្ធប្រមូលបាន ប្រែប្រួលខុសគ្នាពីអាជីកម្មមួយទៅអាជីវកម្មមួយ និងពីកន្លែងមួយទៅកន្លែងមួយ ។ ការតថ្លៃ ឬការចរចា គឺអាចធ្វើទៅបាន ។ ការចរចាអាចធ្វើរួមគ្នា (ឧទាហរណ៍ ក្រុមអ្នកកិនស្រូវ, អាជីវករទាំងអស់នៅទីផ្សារ) ឬក៏តាមបុគ្គលម្នាក់ៗ ។ អាចមានបទប្បញ្ញត្តិដែលបានកំណត់ចេញរួចហើយនៅក្នុងប្រព័ន្ធសំរាប់កំណត់ប្រាក់ពន្ធ ប៉ុន្តែដែលមិនបានយកមកប្រើ ។ បទសំភាសន៍ជាមួយអង្គភាពអាជីវកម្មតូចៗនៅគ្រប់ខេត្តបានបង្ហាញថា ពុំមានការប្រើប្រព័ន្ធជាប់លាប់អ្វីសំរាប់កំណត់ប្រាក់ពន្ធលើអាជីវកម្មនានាទេ ។ រឿងនេះ ប្រហែលជាប់ទាក់ទងនឹងរចនាសម្ព័ន្ធទីផ្សារ និងអាជីវកម្មផ្សេងៗ ។ ទីផ្សារខ្លះដែលមានការរៀបចំល្អ គឺមានការយកពន្ធយ៉ាងទៀងទាត់[៣] រីឯទីផ្សារមួយចំនួនទៀត កំរឬក៏មិនដែលបង់ពន្ធសោះ ហើយបើកាលណាមានការបង់ពន្ធ ការប្រមូលពន្ធត្រូវជួបឧបសគ្គនៃការប្រកាន់បក្សពួក និងកង្វះតំលាភាព[៤] ។ ដូច្នេះហើយ អត្រាពន្ធ និងប្រាក់ពន្ធដែលប្រមូលយក វាប្រែប្រួលខុសគ្នាទៅតាមអង្គភាពប្រមូលពន្ធតាមពេលវេលា និងតាមទីកន្លែង ។

## ប្រភពចំនូលជាសក្តានុពល សំរាប់ក្រុមប្រឹក្សាឃុំ/សង្កាត់

ប្រភពចំនូលជាសក្តានុពលសំរាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ គឺមានប្រាក់កំរៃយកពីអ្នកប្រើប្រាស់នូវសេវាដែលផ្តល់ដោយក្រុមប្រឹក្សាឃុំ និងការប្រមូលពន្ធពីមូលដ្ឋានយកពន្ធសាមញ្ញៗ និងអាជីវកម្មខ្នាតតូច ។ ប្រាក់កំរៃយកពីអ្នកប្រើប្រាស់ដែលតាក់តែងរៀបចំបានល្អ អាចជួយកែលំអអត្ថប្រយោជន៍សេវាសាធារណៈ ជាពិសេសចំណាយខាងសុខាភិបាល និងអប់រំ ប៉ុន្តែសេចក្តីសំរេចក្នុងរឿងនេះត្រូវធ្វើយ៉ាងប្រយ័ត្នប្រយែង ដើម្បីធានាឱ្យក្រុមប្រជាជនអ្នកក្រីក្រមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានសេវាគុណភាពល្អ ។ ប្រភពចំនូលផ្ទាល់ជាសក្តានុពលទី២នៃឃុំ/សង្កាត់ គឺការប្រមូលពន្ធ ។ នៅតាមឃុំ និងភូមិ (ក្នុងខេត្តបានសិក្សានានា) មានសកម្មភាព និងអាជីវកម្មជាច្រើនដែលមានសក្តានុពលខ្ពស់ក្លាយជាប្រភពចំនូល (មិនរាប់បញ្ចូលក្រុមហ៊ុន និងឧស្សាហកម្មធំៗទេ) ។ ការប្រមូលពន្ធពីទីផ្សារអាចជាប្រភពចំនូលដ៏ធំបំផុតមួយរបស់ឃុំ/សង្កាត់ ។ ទីផ្សារនានានៅក្នុងឃុំ ដំណើរការតែនៅពេល

ព្រឹកប៉ុណ្ណោះ ហើយអាចមានដល់ ២០០រាន និងតូបរាប់សិបទៀតនៅព័ទ្ធជុំវិញ ។ តាមធម្មតា ភ្នាក់ងារខេត្តជាអ្នកគ្រប់គ្រង និងដំណើរការទីផ្សារនានា ។ មានភ្នាក់ងារមួយចំនួន ដែលត្រូវបានចាត់ជាភ្នាក់ងារសារពើរពន្ធរបស់រដ្ឋ ដើម្បីប្រមូលពន្ធពីទីផ្សារ (ភាស៊ី) ។ អ្នកដែលចង់ក្លាយជាភ្នាក់ងាររដ្ឋ ត្រូវដាក់ពាក្យសុំដេញថ្លៃជាមួយរដ្ឋាភិបាលដោយត្រូវបញ្ជាក់ថា សុខចិត្តបង់ប្រាក់ក្នុងតំលៃប៉ុន្មានៗ ដើម្បីទទួលបាននូវឯកសិទ្ធិក្នុងការប្រមូលពន្ធពីទីផ្សារបាន ។ ជាគោលការណ៍ អ្នកដែលដេញថ្លៃខ្ពស់បំផុត នឹងទទួលបានកិច្ចសន្យារយៈពេល ១ ឆ្នាំ ។

ក្រៅពីការប្រមូលពន្ធពីទីផ្សារ ក៏នៅមានប្រភពប្រមូលពន្ធជាច្រើនទៀតដែលជាអាជីវកម្មធម្មតា ត្រូវជាប់ពន្ធនៅថ្នាក់ឃុំ[៥] ដូចជា ម្ចាស់រោងម៉ាស៊ីនកិនស្រូវ អ្នកផលិតស្រា អ្នកផលិតឥដ្ឋ/ក្បឿង អ្នកផលិតទឹកកក ម៉ាស៊ីនភ្លើង អ្នកលក់អាហារ តូបលក់គ្រឿងទេស អ្នកលក់ផលិតផល/អនុផលព្រៃឈើនិងអុស អាជីវកម្មដែលជាប់ទាក់ទិននឹងធនធានធម្មជាតិ និងអ្នករកស៊ីបញ្ចាលអាគុយ ។ ជាទូទៅ អាជីវកម្មទាំងអស់នេះ បានបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចាប់ពី ៥.០០០-៣៥.០០០រៀល ។ ជាឧទាហរណ៍ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ តាមធម្មតា គេបង់តែពន្ធប៉ាតង់ពី ៥.០០០-១៥.០០០រៀល/ឆ្នាំតែប៉ុណ្ណោះ ។

ឱ្យបន្ទុកពន្ធធ្ងន់ហួសប្រមាណ និងដែលបានជំរុញមួយកំរិតដល់ប្រព័ន្ធបង់ពន្ធក្រៅផ្លូវការ ។ ក្នុងដំណើរការនេះ បញ្ហាបានចោទកាន់តែធ្ងន់ធ្ងរឡើងដោយសារឃុំ/សង្កាត់ ខ្វះសមត្ថភាពស្ថាប័ន និងការកត់ត្រាផ្លូវការ ដើម្បីថែរក្សា និងរាយការណ៍ពីចំនូលប្រមូលបាន ។ នេះជាបញ្ហាដ៏ធំមួយក្នុងដំណាក់កាលបច្ចុប្បន្ននៃកំណែទំរង់វិមជ្ឈការ ពីព្រោះឃុំ/សង្កាត់ពុំមានដោយផ្ទាល់ទេនូវគណនេយ្យករ គណនីធនាគារ កំណត់ត្រាសមស្របសំរាប់ការត្រួតពិនិត្យជាសាធារណៈ ឬក៏រចនាសម្ព័ន្ធហិរញ្ញវត្ថុមួយដែលរឹងប៉ឹងស្រាប់ ។ រឿងទាំងអស់នេះ គឺជាបញ្ហាប្រឈមយ៉ាងសំខាន់ខាងតំលាភាព និងគណនេយ្យភាពនៅក្នុងដំណើរការបង្កើតការយកពន្ធនៅកំរិតឃុំ/សង្កាត់ ។ ទិដ្ឋភាពមួយទៀតគឺ ឃុំ/សង្កាត់ ត្រូវបំពាក់ឱ្យខ្លួនឯងនូវរចនាសម្ព័ន្ធរដ្ឋបាលមួយដែលមានបទពិសោធន៍ និងសមត្ថភាពក្នុងការប្រមូលពន្ធ ។ កត្តាសំខាន់ដូចគ្នាមួយទៀតគឺ ឆន្ទៈខាងនយោបាយរបស់ក្រសួងពាក់ព័ន្ធនៅថ្នាក់ជាតិ ។ ថ្វីបើសព្វថ្ងៃមានអាជ្ញាធរស្របច្បាប់ និងឆន្ទៈនយោបាយក្នុងកំរិតណាមួយ ដើម្បីជំរុញកំណែទំរង់វិមជ្ឈការសារពើពន្ធឱ្យមានការរីកចំរើនទៅមុខក្តី ប៉ុន្តែត្រូវមានដំណើរការពិគ្រោះយោបល់ស្វែងរកការមូលមតិគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់ពីយន្តការ និងយុទ្ធសាស្ត្រផ្សេងៗសំរាប់ធ្វើឱ្យដំណើរការនេះលូតលាស់ទៅមុខ ។

## ការរំពឹងទុក និងបញ្ហាប្រឈមក្នុងដំណើរការបង្កើតប្រព័ន្ធប្រមូលពន្ធនៅឃុំ/សង្កាត់

*ថ្វីបើសព្វថ្ងៃមានអាជ្ញាធរស្របច្បាប់ និងឆន្ទៈនយោបាយក្នុងកំរិតណាមួយ ដើម្បីជំរុញកំណែទំរង់វិមជ្ឈការសារពើពន្ធឱ្យមានការរីកចំរើនទៅមុខក្តី ប៉ុន្តែ ត្រូវមានដំណើរការពិគ្រោះយោបល់ស្វែងរកការមូលមតិគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់ពីយន្តការ និង យុទ្ធសាស្ត្រផ្សេងៗសំរាប់ធ្វើឱ្យដំណើរការនេះលូតលាស់ទៅមុខ ។*

ក្នុងការជជែកវែកញែកពីការយកពន្ធដោយឃុំ/សង្កាត់ ជារឿយៗមានគេលើកជាមតិថា ថ្នាក់មូលដ្ឋានមិនអាចទទួលរ៉ាប់រងពន្ធបានទេ ដោយគេពិពណ៌នាថា ជាបញ្ហាភាពក្រីក្រ ។ ប៉ុន្តែ ការសិក្សាធ្វើឡើងដោយ វបសអ លើអាជីវកម្មជ័រទឹក និងផលិតផលត្រី បានបង្ហាញវត្តមានជាទូទៅនូវប្រព័ន្ធ "មិនផ្លូវការ" មួយនៃពន្ធ និងប្រាក់កំរៃ ។ អ្នកនៅក្នុងអាជីវកម្មទាំងអស់នេះ ត្រូវបង់ប្រាក់កំរៃទៅអោយមន្ត្រីផ្សេងៗទៀតជាច្រើននាក់ ដើម្បីទទួលបានលិខិតអនុញ្ញាតគ្រប់ប្រភេទតាមការតំរូវឡើងរបស់គេ សំរាប់ដឹកជញ្ជូនផលិតផលទៅទីផ្សារ (Prom and Mckenney 2003) ។ ការរៀបរាប់ខាងលើបានបង្ហាញថា ក្នុងពេលដ៏ខ្លីខាងមុខ ពុំមានតំរូវការដាក់អនុវត្តពន្ធ និងប្រាក់កំរៃប្រភេទថ្មីៗផ្សេងទៀតទេ ពីព្រោះសកម្មភាពជាច្រើននៅថ្នាក់ឃុំ/សង្កាត់ ត្រូវបានយកពន្ធរួចជាស្រេចហើយ ដូច្នេះអ្វីដែលត្រូវធ្វើ គឺការផ្ទេរ និងការបែងចែកឡើងវិញនូវប្រាក់ចំនូលទាំងនេះ ។

មានបញ្ហាប្រឈមជាច្រើនដែលអាចផុសឡើង នៅក្នុងដំណើរការស្វែងរក និងកំណត់ចេញនូវប្រភពចំនូលផ្ទាល់របស់ឃុំ/សង្កាត់ ។ ក្នុងនេះបញ្ហាចំបងគេគឺ តើពន្ធនិងប្រភពចំនូលអ្វីដែលគួរផ្ទេរ និងបែងចែក រវាងសាលាខេត្ត និងឃុំ ។ ដោយសារមានការចូលរួមពីអាជ្ញាធរច្រើនកំរិតណាស់ក្នុងការប្រមូលពន្ធ ដូច្នេះធនធាននៅមូលដ្ឋាន ត្រូវបានយកពន្ធរួចជាស្រេចដែលធ្វើឱ្យរេចរិលដល់ប្រភពចំណូលរបស់ឃុំ/សង្កាត់ ។ បញ្ហាប្រឈមទីពីរគឺអំពើពុករលួយ ជាទូទៅក្នុងទំរង់ជាការប្រមូលពន្ធ/ប្រាក់កំរៃក្រៅផ្លូវការដែលជាចំណែកមួយនៃដំណើរការប្រមូលពន្ធ ។ម្យ៉ាងទៀត មានការយកពន្ធត្រួតគ្នា ២-៣ដងយ៉ាងច្បាស់លើទំនិញ និងសេវាមួយចំនួនដែលធ្វើ

### កំណត់សំគាល់

១. កិច្ចសំភាសន៍ជាមួយមន្ទីររតនាគារខេត្តក្នុងពេលចុះសិក្សាស្រាវជ្រាវ ។

២. កិច្ចសំភាសន៍ជាមួយអភិបាលស្រុក និងសមាជិកក្រុមប្រឹក្សាឃុំនៅតាមខេត្តនានាក្នុងពេលចុះធ្វើការសិក្សាស្រាវជ្រាវ ។

៣. កិច្ចសំភាសន៍ជាមួយអ្នកធ្វើឥដ្ឋនៅខេត្តសៀមរាបនៅថ្ងៃទី១៧ មិថុនា ២០០៣ (សូមមើល Rusten *et al.* 2004) ។

៤ អង្កេតទីផ្សារ នៅក្រុងកែប (សីហា២០០៣) និងខេត្តកំពង់ស្ពឺ (មិថុនា ២០០៣) (សូមមើល Rusten *et al.* 2004) ។

៥ មិនមែនគ្រប់អាជីវកម្ម និងទីផ្សារទាំងអស់សុទ្ធតែត្រូវបានយកពន្ធនោះទេ ថ្វីបើសព្វថ្ងៃអាជីវកម្មភាគច្រើនបានបង់ពន្ធក្តី ។

### ឯកសារយោង

Eng, N. and C. Rusten. 2004 (forthcoming). *Fiscal Decentralisation: Existing taxation and potential tax candidates for reassignment and sharing between the province and the commune*. Cambodia Development Resource Institute. Phnom Penh.

Prom, T. and B. McKenney. 2003. Forest Trade in Cambodia: A Case Study of Resin. *Cambodia Development Review*. Vol. 7, issue 2.

Rusten, C. S. Kim, N. Eng and K. Pak. 2004 (in print). *The Challenges of the Decentralisation Design*. Cambodia Development Resource Institute. Phnom Penh.

# សុខដុមនីយកម្មច្បាប់ជាប់ទាក់ទងនឹងវិមជ្ឈការ

*លោក Robert Oberndorf ជាទីប្រឹក្សាឯករាជ្យខាងច្បាប់ម្នាក់ បានពិនិត្យពីបរិបទច្បាប់នៅជុំវិញកំណែទំរង់វិមជ្ឈការ ដែលកំពុងដំណើរការនៅកម្ពុជា ។ **

រាជរដ្ឋាភិបាលកម្ពុជា (RGC) កំពុងអនុវត្តកំណែទំរង់វិមជ្ឈការ ដើម្បីផ្ទេរអំណាចទៅឱ្យអាជ្ញាធរពាក់កណ្ដាលស្វ័យយ័ត ដែលជាប់ឆ្នោតនៅកំរិតឃុំ-សង្កាត់ និងដើម្បីពង្រឹងតួនាទីនានារបស់ខេត្ត-ក្រុង ក្នុងលក្ខណៈជាអង្គភាពវិមជ្ឈការនៃថ្នាក់មជ្ឈិម ។ នៅខែមីនា ២០០១ RGC បានចាប់ផ្ដើមយ៉ាងក្លាហាននូវបទពិសោធន៍ថ្មីមួយក្នុងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការរដ្ឋាភិបាល តាមការអនុម័តច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (LAMC) និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ហើយក្រោយមកទៀត តាមការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នៅខែកុម្ភៈ ២០០២ ។ ធនធាន សិទ្ធិអំណាចធ្វើចំណាយ និងមុខងារច្រើនទៀតត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរមូលដ្ឋាន ហើយអភិបាលខេត្តនានាក៏បានទទួលភារកិច្ចជួយគាំទ្រ និងធ្វើការត្រួតពិនិត្យលើក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ ។ ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងនេះ ច្បាប់និងបទប្បញ្ញត្តិជាច្រើន ត្រូវបានអនុម័តចេញក្នុងរយៈពេលមួយដ៏ខ្លី ។ ការយល់ដឹងថា តើច្បាប់និងបទប្បញ្ញតិទាំងនេះ វាស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់ដែលមានស្រាប់យ៉ាងដូចម្ដេច និង តើការប្រឹងប្រែងធ្វើវិមជ្ឈការសព្វថ្ងៃរបស់រដ្ឋាភិបាល វាស៊ីសង្វាក់គ្នាប៉ុណ្ណាជាមួយនឹងរចនាសម្ព័ន្ធច្បាប់ជាទូទៅនៅកម្ពុជា, គឺជារឿងមួយសំខាន់ណាស់សំរាប់ជោគជ័យជាបន្តទៀតនៅក្នុងដំណើរការធ្វើវិមជ្ឈការ ។

## ក្របខ័ណ្ឌច្បាប់

ដើម្បីស្វែងយល់ពីច្បាប់ និងបទប្បញ្ញត្តិនានា ដែលបានអនុម័តដើម្បីគាំទ្រដល់កំណែទំរង់វិមជ្ឈការ (ដោយមិននិយាយអំពីច្បាប់ និងបទប្បញ្ញត្តិនានាដែលមិនទាន់តាក់តែងនោះផង) គេត្រូវមានការយល់ដឹងជាមូលដ្ឋានអំពីក្របខ័ណ្ឌច្បាប់នៅកម្ពុជា ។ ច្បាប់ និងបទប្បញ្ញត្តិនានារបស់កម្ពុជាមានលំដាប់ថ្នាក់ច្បាស់លាស់ ហើយសុពលភាព និងអំណាចនៃច្បាប់នីមួយៗផុសចេញពីវិធានកំពូលមួយនៅក្នុងរចនាសម្ព័ន្ធឋានានុក្រមនៃច្បាប់ ។ នៅខាងក្រោម គឺជាការអធិប្បាយត្រួសៗពីឋានានុក្រមជាទូទៅនៃច្បាប់នៅព្រះរាជាណាចក្រកម្ពុជា: ១) រដ្ឋធម្មនុញ្ញ ២) ច្បាប់ ៣) រាជក្រឹត្យ ៤) អនុក្រឹត្យ ៥) ប្រកាស ៦) សារាចរ ៧) ដីកា ។

នៅក្នុងឋានានុក្រមច្បាប់នេះ គេអាចធ្វើការសង្កេតជាទូទៅមួយចំនួនអំពីដែនអនុវត្ត និងពេលវេលា ។ បើបទប្បញ្ញត្តិណាមួយត្រូវបានអនុម័តដោយស្ថាប័នកំរិតកាន់តែខ្ពស់ ការអនុមតិចេញជាក់ស្ដែងត្រូវស៊ីពេលកាន់តែច្រើនដោយសារត្រូវឆ្លងកាត់ការពិនិត្យឡើងវិញនៅច្រើនកំរិត ។ ឧទាហរណ៍ ច្បាប់មួយដែលតាក់តែងឡើងនៅកំរិត RGC ត្រូវឆ្លងកាត់ដំណើរការពិនិត្យឡើងវិញនៅក្នុងក្រសួងជំនាញ ទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋសភា និងព្រឹទ្ធសភា ចំណែកឯប្រកាសវិញគឺ ត្រូវបានពិនិត្យឡើងវិញតែនៅក្នុងសាមីក្រសួងដែលអនុម័តវាចេញប៉ុណ្ណោះ[១] ។ សេចក្ដីសំរេចណាមួយដែលត្រូវជាប់ទាក់ទងនឹងការអនុមតិ ឬវិសោធនកម្មច្បាប់ ត្រូវតែគិតគូរពីកត្តាខាងពេលវេលានេះ ។

ទិដ្ឋភាពមួយទៀតដែលគួរពិចារណាគឺ ដែនអនុវត្តនៃឯកសារច្បាប់ ។ ច្បាប់មានដែនអនុវត្តធំទូលាយ ហើយអនុវត្តលើគ្រប់អង្គភាពរដ្ឋ និងទីតាំងភូមិសាស្ត្រនៅក្នុងប្រទេស លើកលែងតែក្នុងអត្ថបទច្បាប់មានសេចក្ដីចែងជាក់លាក់កាត់បន្ថយដែនអនុវត្ត ។ ប្រកាសច្រើនមានកំលាំងអនុវត្តតែនៅក្នុងក្រសួងដែលអនុម័តវាចេញប៉ុណ្ណោះ ហើយដីកាមានកំលាំងអនុវត្តតែក្នុងតំបន់ភូមិសាស្ត្រនៃខេត្ត ឬឃុំ-សង្កាត់ ដែលអនុម័តវាចេញនោះដែរ ។

*ច្បាប់:* នេះជាប្រភពចំបងនៃច្បាប់អនុវត្តនៅកម្ពុជា ។ ច្បាប់ត្រូវអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ។ ពេលខ្លះគេច្រឡំច្បាប់ជាមួយនឹង ក្រមដែលជារាជក្រឹត្យមួយបែបរបស់ព្រះមហាក្សត្រ ឬប្រមុខរដ្ឋ សំរាប់ប្រកាសឱ្យប្រើច្បាប់អ្វីមួយ ។

*រាជក្រឹត្យ:* រដ្ឋធម្មនុញ្ញបានចែងថា "តាមសេចក្ដីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ច មន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា..."[២] ។ RGC បានប្រើប្រាស់បទប្បញ្ញត្តិនេះ ដើម្បីបង្កើតស្ថាប័នអន្តរក្រសួងកំរិតខ្ពស់ដូចជា គណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC) និងឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

*អនុក្រឹត្យ:* ជាឯកសារច្បាប់មួយដែលជាទូទៅត្រូវបានប្រើប្រាស់ដើម្បីដាក់អនុវត្ត និងផ្ដល់ការបំភ្លឺលើបទប្បញ្ញត្តិជាក់លាក់មួយចំនួនក្នុងច្បាប់ និងមានប្រើផងដែរដើម្បីបញ្ជាក់ពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពរដ្ឋ (ក្រសួង-មន្ទីរ) ឬដើម្បីតែងតាំងមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល ។ អនុក្រឹត្យច្រើនតែតាក់តែងឡើងដោយក្រសួងមួយ ឬក្រសួងច្រើនរួមគ្នាដែលមានសមត្ថកិច្ចដូចគ្នាក្នុងវិស័យត្រូវធ្វើច្បាប់ ។ នៅពេលតាក់តែងរួចរាល់ហើយ អនុក្រឹត្យត្រូវដាក់ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសំរេច ។ នៅពេលគណៈរដ្ឋមន្ត្រីបានអនុម័តយល់ព្រមហើយ អនុក្រឹត្យនោះត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី និងចុះហត្ថលេខាអមដោយរដ្ឋមន្ត្រីដែលទទួលបន្ទុកអនុវត្ត និងពង្រឹងការអនុវត្តន៍ ។ សិទ្ធិអំណាចដើម្បីបង្កើតអនុក្រឹត្យ ទោះដោយផ្ទាល់ឬដោយប្រយោលក្ដី ត្រូវតែចេញមកពីបទប្បញ្ញត្តិជាផ្លូវការដែលមានកំរិតខ្ពស់ជាង ដូចជា ច្បាប់ ជាដើម ។

*ប្រកាស:* ជាបទប្បញ្ញត្តិរបស់ក្រសួង ឬអន្តរក្រសួង ដែលត្រូវបានប្រើប្រាស់ដូចអនុក្រឹត្យដែរ ដើម្បីអនុវត្ត និងផ្ដល់ការបំភ្លឺនូវបទប្បញ្ញតិជាក់លាក់មួយចំនួនក្នុងឯកសារច្បាប់កំរិតខ្ពស់ជាង ។ ជារឿយៗគេប្រើប្រកាសដើម្បីផ្ដល់សេចក្ដីណែនាំដ៏ចាំបាច់នានា ដើម្បីអនុវត្តច្បាប់ ឬអនុក្រឹត្យ ។ តាមធម្មតា ប្រកាសត្រូវបានតាក់តែងនៅកំរិតនាយកដ្ឋានបច្ចេកទេស បន្ទាប់មកចុះហត្ថលេខាឱ្យមានប្រសិទ្ធភាពប្រើប្រាស់ដោយរដ្ឋមន្ត្រីម្នាក់ (ឬច្រើននាក់) នៃក្រសួងដែលត្រូវអនុវត្តប្រកាសនោះ ។ គួរកត់សំគាល់ថា ប្រកាសភាគច្រើនបានប្រើប្រាស់ដើម្បីអនុវត្តច្បាប់នៅកម្ពុជា ហើយមេរៀនដែលរៀនសូត្របានអាចដាក់បញ្ចូលយ៉ាងឆាប់ ពីព្រោះដំណើរការអនុម័តប្រកាសមាន

---

* អត្ថបទនេះ ផ្អែកទៅលើបទបង្ហាញរបស់លោក Oberndorf នៅក្នុងសិក្ខាសាលារបស់ វិបសអ ស្ដីពី "បញ្ហាប្រឈមនៃការតាក់តែងរចនាវិមជ្ឈការ" នៅសណ្ឋាគារសាន់វេ ថ្ងៃទី២៩ មករា ២០០៤ ។ ឯកសារ ពិភាក-ក្សាពេញលេញមានផ្សព្វផ្សាយ ដោយ វិបសអ នាខែមីនា ២០០៤ ។ *ទស្សនៈទាំងឡាយក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វិបសអ ទេ ។*

លក្ខណៈសាមញ្ញ និងលឿន ។ គុណវិបត្តិនៃប្រកាស គឺដែនអនុវត្តដ៏តូចរបស់វាដែលមានត្រឹមតែសាមីក្រសួងអ្នកអនុម័តវាចេញប៉ុណ្ណោះ ហើយក្រសួង និងអង្គភាពរដ្ឋឯទៀតៗពុំមានអារម្មណ៍ថា ខ្លួនមានកាតព្វកិច្ចត្រូវគោរពតាមប្រកាសនោះជានិច្ចជាកាលទេ ។

*សារាចរ:* ជាលិខិតូបករណ៍ចេញដោយនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ដើម្បីពន្យល់ ឬបំភ្លឺនូវវិធានការខាងច្បាប់ ឬក៏ដើម្បីដាក់បទបញ្ជា ។ ដូចប្រកាសដែរ សារាចរមានដែនអនុវត្តតូច ប៉ុន្តែងាយអនុម័តចេញ ។

*ដីកា:* ជាបទបញ្ជាចេញដោយអភិបាលខេត្ត ឬក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលមានកំលាំងជាច្បាប់នៅក្នុងដែន ភូមិសាស្ត្រ ឬសិទ្ធិអំណាចជាអាជ្ញាធរ ដែនដីនៃថ្នាក់ដឹកនាំទាំងនេះ ។ ដីកាមិនអាចប្រឆាំងនឹងច្បាប់ ឬបទប្បញ្ញត្តិនៅកំរិតជាតិទេ ។ ដីកាកំរិតឃុំ ក៏មិនអាចផ្ទុយគ្នាពី ដីកាខេត្តដែរ ។

## ច្បាប់ចំបងៗដែលបានអនុម័តហើយ

ខាងក្រោមនេះ គឺជាបញ្ជីនៃច្បាប់ និងបទប្បញ្ញត្តិចំបងៗដែលបានអនុម័តតាំងពីឆ្នាំ២០០១ ដើម្បីជួយទ្រទ្រង់ដល់កំណែទំរង់វិមជ្ឈការ ។ ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ដែលមានទាំងប្រកាស និងសេចក្តីណែនាំនានា មានច្រើនជាងនេះឆ្ងាយណាស់ ។

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (LAMC):** នេះគឺជាច្បាប់ដែលចាត់ទុកជាឯកសារគោលនយោបាយគន្លឹះ និងជាក្របខ័ណ្ឌ សំរាប់កម្មវិធី វិមជ្ឈការ ។ ច្បាប់នេះកំនត់ពីចំណុចសំខាន់ៗជាប់ទាក់ទងដល់តួនាទី ភារកិច្ច និងមុខងារនៃអង្គភាពផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងវិមជ្ឈការ និងផ្តល់ការអនុញ្ញាតចំពោះឯកសារច្បាប់សំរាប់ជួយគាំទ្រដ៏ចាំបាច់នានាដែលត្រូវអនុម័តចេញ ប៉ុន្តែមិនបានកំណត់ពីរយៈពេលដែលត្រូវធ្វើការអនុម័ត ឯកសារទាំងនេះទេ ។ ដូចច្បាប់នានាជាទូទៅនៅកម្ពុជាដែរ, LAMC មានខ្លឹមសារទូលំទូលាយណាស់ ហើយបទប្បញ្ញត្តិខ្លះមានន័យស្រពិចស្រពិលផង ដូច្នេះហើយត្រូវមានសេចក្តីបញ្ជាក់លំអិតដូចធម្មតានៅក្នុងអនុក្រឹត្យ និងប្រកាសសំរាប់ជួយគាំទ្រនានា ដែលច្បាប់នេះបានអនុញ្ញាតឱ្យបង្កើតឡើង ។

**ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់:** ច្បាប់នេះកំណត់ឡើងនូវវិធាន និងបទប្បញ្ញត្តិទាំងអស់ សំរាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់នៅកម្ពុជា ។ ខុសប្លែកពីច្បាប់ឯទៀតៗ ច្បាប់នេះមានលក្ខណៈលំអិត និងវែងខ្លាំងណាស់ ហើយរឿងនេះកើតចេញពីការពិតជាក់ស្តែងដែលត្រូវមានវិធាន និងបទប្បញ្ញត្តិទាំងអស់និងស្រេចបាច់ មុនពេលធ្វើការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់លើកទី១ នៅខែកុម្ភៈ ២០០២ ។ ការអនុមតិច្បាប់ក្នុងទំរង់នេះ គឺជាសញ្ញាបង្ហាញពីការប្តេជ្ញាចិត្តខាងនយោបាយដ៏រឹងមាំចំពោះដំណើរការធ្វើវិមជ្ឈការ ។ គួរកត់សំគាល់ដែរថា ច្បាប់នេះបានតាក់តែងឡើងដោយមានជំនួយបច្ចេកទេសពីខាងក្រៅយ៉ាងច្រើន ។

**រាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC):** រាជក្រឹត្យនេះបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់ NCSC ។

**អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់:** អនុក្រឹត្យនេះ បំពេញបន្ថែមនូវចំណុចលំអិតជាច្រើនដែលនៅខ្វះចន្លោះនៅក្នុង LAMC និងណែនាំពីទស្សនៈមួយចំនួនដែលមានពន្យល់យ៉ាងពេញលេញថែមទៀតនៅក្នុងឯកសារគាំទ្រផ្សេងៗ ដូចជាប្រកាសស្តីពីស្មៀនឃុំ/សង្កាត់ ជាដើម ។

**អនុក្រឹត្យស្តីពីមូលនិធិឃុំ/សង្កាត់:** អនុក្រឹត្យនេះ ចែងពីចំណុចលំអិតនានាដើម្បីបង្កើត និងគ្រប់គ្រងមូលនិធិឃុំ/សង្កាត់ រួមទាំងវិធានជាមូលដ្ឋានសំរាប់ការផ្ទេរមូលនិធិឃុំ/សង្កាត់នៅក្នុងរតនាគារខេត្ត និងវិធានបញ្ជាក់ពីតួនាទី និងភារកិច្ចរបស់អភិបាលខេត្ត និងរតនាគារខេត្ត ។

**អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់:** អនុក្រឹត្យនេះ ចែងពី ចំណុចលំអិតនានាសំរាប់គ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់ រួមទាំងវិធាន-ស្តីពីការ កសាង ការអនុមតិនិងការអនុវត្តន៍ថវិកាឃុំ/សង្កាត់ ប្រព័ន្ធគណនេយ្យនិង ការទូទាត់ របាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងចំណូលចំណាយ ការគ្រប់គ្រងទ្រព្យជាប់លាប់ និងសវនកម្មលើគណនេយ្យនិងប្រតិបត្តិការ ។ ឯកសារ នេះជាគន្លឹះ-មួយដ៏សំខាន់ ពីព្រោះការធ្វើផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាតួនាទី-មួយក្នុងចំណោមតួនាទីមួយចំនួនតូចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលត្រូវបានកំណត់យ៉ាងច្បាស់ ។

**ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DOLA):** ធាតុសំខាន់ (ជារឿយៗមានការភ័ន្តច្រឡំ) នៃប្រកាសនេះគឺវាបញ្ជាក់ពីការផ្ទេរភារកិច្ចជាច្រើននៃការប្រស្រ័យទាក់ទង ការឃ្លាំមើល និងការវាយតំលៃចេញពី NCSC និងក្រសួងមហាផ្ទៃ (MoI) ទៅឱ្យនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ។

**ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត/ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់:** ប្រកាសនេះ គឺជាដំណោះស្រាយបណ្តោះអាសន្ន រហូតដល់ច្បាប់រៀបចំអង្គការ (organic law) ស្តីពីការគ្រប់គ្រងខេត្ត ស្រុក ត្រូវបានតាក់តែង និងអនុម័ត ។ ប្រកាសនេះក៏ណែនាំ ពីការផ្ទេរថែមទៀតនូវតួនាទីធ្វើការ ប្រស្រ័យទាក់ទង ឃ្លាំមើល និងវាយតំលៃ ពីថ្នាក់ជាតិ ជាពិសេស NCSC, MOI និង DOLA ទៅឱ្យថ្នាក់ខេត្ត ។ មានការយល់ច្រឡំម្តងម្កាលដែរ ប៉ុន្តែតាមពិតការផ្ទេរនេះមិនមែនទៅឱ្យអភិបាលខេត្តតែម្នាក់ទេ តែទៅអាជ្ញាធរថ្នាក់ខេត្ត ពីព្រោះបុគ្គលតែម្នាក់ មិនអាចដោះស្រាយការទទួលខុសត្រូវនានាដែលត្រូវបានផ្ទេរមកឱ្យនោះទេ ។

**ប្រកាសស្តីពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត/ក្រុង:** ដូចប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត/ក្រុងខាងលើដែរ ប្រកាសនេះគឺជាដំណោះស្រាយបណ្តោះអាសន្ន រហូតដល់ច្បាប់រៀបចំអង្គការត្រូវបានតាក់តែង និងអនុម័ត ។

**ប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ/សង្កាត់:** ប្រកាសនេះបញ្ជាក់ពីមុខងារជាទូទៅរបស់ស្មៀនឃុំ/សង្កាត់ដែលបំរើការសំខាន់ជាលេខានៃក្រុមប្រឹក្សាឃុំ/សង្កាត់ ។

**ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់:** ប្រកាសនេះបញ្ជាក់ពីរចនាសម្ព័ន្ធ និងនីតិវិធីជាទូទៅសំរាប់ដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ ។ ដូចអនុក្រឹត្យស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឃុំដែរ ប្រកាសនេះសំខាន់ណាស់ ពីព្រោះវាស្ថិតក្នុងចំណោមបទប្បញ្ញត្តិមួយចំនួនតូចដែលបានកំនត់ច្បាស់ និងអាចយល់បានល្អ ពីតួនាទីក្រុមប្រឹក្សាឃុំ/សង្កាត់ ។

## យោបល់ស្តីពីបទប្បញ្ញត្តិដែលបានអនុម័តមកដល់ពេលនេះ

គួរលើកសរសើររាជរដ្ឋាភិបាលកម្ពុជា ដែលបានរៀបចំដាក់អនុវត្តក្របខ័ណ្ឌច្បាប់នេះក្នុងរយៈពេលមួយដ៏ខ្លី ធ្វើឱ្យគោលនយោបាយវិមជ្ឈការអាចអនុវត្តទៅបាននៅកម្ពុជា ។ កំរងច្បាប់ និងបទប្បញ្ញត្តិយ៉ាងច្រើនដែលបានអនុម័តចេញដើម្បីគាំទ្រវិមជ្ឈការ វាមានភាពស្មុគស្មាញ និងពិបាកយល់ ជា-ពិសេសចំពោះអ្នកគ្មានការបណ្តុះបណ្តាលខាងច្បាប់ ។ ម្យ៉ាងទៀត ការ តាក់តែងមិនសុទ្ធតែបានច្បាស់លាស់ល្អទេ ហើយជាទូទៅវានៅទាបជាងកំរិត ស្តង់

ជាក្នុងបណ្ដាប្រទេសអភិវឌ្ឍន៍[៣] ។ គួរកត់សំគាល់ជាសំខាន់ថា អ្នកដែលអនុវត្តជាក់ស្ដែងនូវច្បាប់និងបទប្បញ្ញត្តិ បានរាយការណ៍តិចតួចទេពី ឧបសគ្គនានាដែលបង្កឡើងដោយផ្ទាល់ពីបញ្ហាចោទនៅក្នុងច្បាប់ ។ រឿងនេះប្រហែលដោយសារច្បាប់នៅកម្ពុជាច្រើនតែអនុវត្តតាមរយៈប្រកាស ឬសេចក្ដីណែនាំ ។ សរុបមក កំរងច្បាប់ និងបទប្បញ្ញត្តិនេះ អាចអនុវត្តបាន ។ បញ្ហាភាគច្រើនបំផុតដែលរាយការណ៍ឡើង វាជាប់ទាក់ទងនឹងច្បាប់/បទប្បញ្ញត្តិដែលមិនទាន់មាននៅឡើយ ។

រឿងត្រូវប្រយ័ត្ន គឺការទាមទារឱ្យតាក់តែងឡើងវិញទាំងអស់នូវកំរងច្បាប់/បទប្បញ្ញត្តិ ដែលបានអនុម័តហើយ ដោយសារបញ្ហាចោទក្នុងការតាក់តែង ។ ទង្វើនេះនឹងស្រូបយកធនធានដ៏មានតំលៃនានាដែលគួរយកទៅប្រើនៅកន្លែងផ្សេងជាការប្រសើរ ពីព្រោះវាមិនប្រាកដទេថា ប្រព័ន្ធដែលត្រូវយកមកជំនួសអ្វីដែលបានតាក់តែងហើយ វានឹងពិតជាបានល្អជាងមុន ពីព្រោះវាអាចអន់ជាងមុនទៅទៀតក៏ថាបាន ។

### បញ្ហាទាក់ទិននឹងការបកស្រាយច្បាប់

បញ្ហាមួយ (មានច្រើនទៀត) ដែលទាក់ទិននឹងការបកស្រាយច្បាប់/បទប្បញ្ញត្តិដែលមានស្រាប់នៅពេលនេះ គឺជំនាញការច្បាប់ផ្សេងគ្នា អាចមានការបកស្រាយខុសគ្នាដោយយោងតាមសេចក្ដីសន្និដ្ឋានដែលគេចង់បាន ។ នេះជាតួនាទីរបស់អ្នកច្បាប់ និងអ្នកតស៊ូមតិជាទូទៅក្នុងពិភពលោក ។ ស្ថានការណ៍កាន់តែយ៉ាប់យ៉ឺនថែមទៀត នៅពេលដែលជំនាញការមិនមែនខាងច្បាប់ ចាប់ផ្ដើមធ្វើការបកស្រាយច្បាប់ ។ ក្នុងបរិបទកម្ពុជា មានការទទួលស្គាល់ជាទូទៅនូវគោលការណ៍ថា អង្គភាពរដ្ឋដែលមានសមត្ថកិច្ចក្នុងរឿងជាក់លាក់អ្វីមួយ គឺមានការទទួលខុសត្រូវបកស្រាយន័យក្នុងច្បាប់/បទប្បញ្ញត្តិក្នុងរឿងនោះ។ ឧ. ក្រសួងរៀបចំដែនដីនគររូបនីយកម្មនិងសំណង់ (MLMUPC) នឹងអាចប្រកាសថា ខ្លួនជាអង្គភាពតែមួយគត់ដែលអាចបកស្រាយន័យក្នុងច្បាប់ភូមិបាល។ ដូចគ្នាដែរ MOI អាចជជែកវែកញែកថា ច្បាប់/បទប្បញ្ញត្តិជាប់ទាក់ទងនឹងក្រុមប្រឹក្សាឃុំ/សង្កាត់ គឺមានតែ MOI ទេដែលអាចបកស្រាយបាន ។ រឿងនេះអាចស្មុគស្មាញខ្លាំង ពីព្រោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងជជែកវែកញែកថា ការបកស្រាយបទប្បញ្ញត្តិជាប់ទាក់ទងនឹងហិរញ្ញវត្ថុឃុំ/សង្កាត់ គឺជាការទទួលខុសត្រូវរបស់ខ្លួន ។ល។

នៅចុងបញ្ចប់ បើសិនមានទំនាស់លើការបកស្រាយច្បាប់/បទប្បញ្ញត្តិ អង្គចៅក្រម និងតុលាការ គួរមានតួនាទីជាអាជ្ញាកណ្ដាលចុងក្រោយ ដើម្បីអារកាត់លើអត្ថន័យនិងគោលបំណង ។ ជាអកុសល ផ្នែកតុលាការនៅទន់ខ្សោយច្រើន ហើយកម្ពុជាមិនទាន់មានបង្កើតយន្តការអ្វីមួយច្បាស់ទេសំរាប់ដោះស្រាយបណ្ដឹងតវ៉ានៅពេលមានបញ្ហាចោទខាងការបកស្រាយច្បាប់ ។

បច្ចុប្បន្ននេះ ការបកស្រាយ និងការអនុវត្តនីច្បាប់/បទប្បញ្ញត្តិនៅ កម្ពុជា វាជារឿងឆន្ទៈនយោបាយ ជាជាងរឿងអ្វីផ្សេងទៀត ។ ទោះបីច្បាប់/ បទប្បញ្ញត្តិ បានតាក់តែងល្អយ៉ាងណាក្ដី ប៉ុន្តែគ្មានអ្វីធានាថា នឹងអាចដាក់អនុវត្តតាមដូចពាក្យពេចន៍ដែលបានសរសេរនោះទេ ។ ពួកមន្ត្រីរាជការនឹងត្រូវធ្វើការបកស្រាយ និងអនុវត្តច្បាប់ ទៅតាមសេចក្ដីណែនាំ និងការគាំទ្រពីថ្នាក់លើ ឬតាមការយល់ឃើញរបស់ខ្លួនឯង ។

### ច្បាប់ និងបទដ្ឋានសំខាន់ៗដែលសព្វថ្ងៃនៅខ្វះ

បច្ចុប្បន្ននេះ ចន្លោះប្រហោងដែលលេចធ្លោជាងគេគឺ កង្វះច្បាប់រៀបចំអង្គការសំរាប់អាជ្ញាធរថ្នាក់ខេត្តនិងស្រុក ហើយការតាក់តែង និងការអនុម័តច្បាប់នេះ គ្រោងធ្វើនៅឆ្នាំ២០០៦ នៅមុនពេលបោះឆ្នោតឃុំ/សង្កាត់លើកក្រោយ ។ បទប្បញ្ញត្តិចំបង៧ផ្សេងទៀតដែលត្រូវដាក់អនុវត្តក្នុងរយៈពេលខ្លីនិងមធ្យមរួមមាន:

១) ច្បាប់/បទប្បញ្ញត្តិស្ដីពីការកំណត់ប្រភេទ អត្រា និងនីតិវិធី សំរាប់ប្រមូលចំណូលខាងសារពើពន្ធ ខាងមិនមែនសារពើពន្ធ និងខាងកំរៃសេវាសំរាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ (ត្រូវអនុវត្តក្នុងបរិបទនៃការសំរបសំរួលការគ្រប់គ្រងសារពើពន្ធនៅគ្រប់កំរិតនៃរដ្ឋាភិបាល)
២) ច្បាប់ស្ដីពីកំរៃខាងរដ្ឋបាលសំរាប់មុខងារទីភ្នាក់ងារដែលបានផ្ទេរទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់
៣) នីតិវិធីសំរាប់ ការជ្រើសរើស ការចូលកាន់តំណែង និងការផ្លាស់ប្ដូរប្រធានភូមិ, ការតែងតាំងអនុប្រធានភូមិ, និងនីតិវិធីអនុវត្តការងារ និងភារកិច្ចរបស់ប្រធានភូមិ
៤) គោលការណ៍ណែនាំស្ដីពីការជួលបុគ្គលិកសំរាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលមានតំរូវការ
៥) ការតាក់តែងដីកាឃុំ-សង្កាត់ (បទប្បញ្ញត្តិកំរិតមូលដ្ឋាន)
៦) គោលការណ៍ណែនាំ ស្ដីពីការបង្កើតគណៈកម្មាធិការសំរាប់ជួយអនុវត្តភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់
៧) គោលការណ៍ណែនាំស្ដីពីតួនាទី និងការទទួលខុសត្រូវរបស់ឃុំ/សង្កាត់ច្រើនដែលធ្វើការរួមគ្នា

### សេចក្ដីសន្និដ្ឋាន និងចំណុចគន្លឹះៗដើម្បីឈានទៅមុខ

ក្របខ័ណ្ឌច្បាប់ដែលបានដាក់អនុវត្តហើយ ថ្វីបើគេអាចទិតៀនថាមិនសូវសុក្រឹតក្ដី ប៉ុន្តែវាដំណើរការបាន និងកំពុងអនុវត្តដោយភាគីពាក់ព័ន្ធនានា ។ លទ្ធផលនេះគួរកត់សំគាល់ណាស់សំរាប់ប្រទេសមួយដូចកម្ពុជាដែលជួនកាលច្បាប់មួយត្រូវការពេលច្រើនឆ្នាំទើបអនុម័តបាន ឬក៏មិនអាចអនុវត្តបានសមស្របសោះ ។ ក្នុងនេះមានបញ្ហាសំខាន់១ជាច្រើនដែលត្រូវយកចិត្តទុកដាក់ក្នុងការកសាងថែមទៀតនូវច្បាប់នានាដែលជាប់ទាក់ទងនឹងវិមជ្ឈការ ។

បញ្ហាមួយគឺ ការផ្ដល់ឬការផ្ទេរមុខងារទីភ្នាក់ងារទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ ។ បើមានអនុម័តច្បាប់អ្វីមួយដែលផ្ដល់តួនាទី និងភារកិច្ចបន្ថែមទៅឱ្យរដ្ឋបាលកំរិតឃុំ-សង្កាត់ ត្រូវប្រុងប្រយ័ត្នតំរឹមវាជាមួយនឹងច្បាប់/បទប្បញ្ញត្តិដែលមានស្រាប់ ។ ម្យ៉ាងទៀត ត្រូវផ្ដល់ថវិកាឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីអនុវត្តសកម្មភាពជាកាតព្វកិច្ច ។ យោងតាមកំរិតសមត្ថភាពសព្វថ្ងៃរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ រាជរដ្ឋាភិបាលកម្ពុជាត្រូវប្រយ័ត្នប្រយែងកុំដាក់ការទទួលខុសត្រូវច្រើនពេកទៅលើរដ្ឋបាលកំរិតនេះដែលមានការលំបាកមួយចំនួនស្រាប់ទៅហើយ ក្នុងការដោះស្រាយបន្ទុករដ្ឋបាលដែលខ្លួនមានជាស្រេចនោះ ។

បញ្ហាមួយទៀតគឺត្រូវធានាថា ច្បាប់រៀបចំអង្គការស្ដីពីអភិបាលកិច្ចខេត្តនិងស្រុក នឹងប្រទាក់ក្រឡាល្អជាមួយនឹងច្បាប់ទ្រទ្រង់វិមជ្ឈការសព្វថ្ងៃ ។ ការអនុមតិច្បាប់នេះ ទាមទារការធ្វើវិសោធនកម្មច្បាប់ LAMC និងបទប្បញ្ញត្តិជួយគាំទ្រនានា ដូច្នេះវាសំខាន់ណាស់ដែលត្រូវរកឃើញតាំងពីដើមទីនូវវិសោធនកម្មដ៏ចាំបាច់នានា ដើម្បីគិតគូរពីដំណើរការដ៏វែងនៃការអនុមតិច្បាប់ឬធ្វើវិសោធនកម្មច្បាប់ ។ ជាទស្សនៈទូទៅត្រូវយកចិត្តទុកដាក់ឱ្យខ្លាំងពីវិសោធនកម្មនានាដែលត្រូវធ្វើឡើងចំពោះច្បាប់ដែលមានស្រាប់ ។

មានសំនួរចំបងមួយទាក់ទិននឹងអាណត្តិនៃ NCSC ដែលត្រូវបញ្ចប់មុនដល់អាណត្តិទី២នៃក្រុមប្រឹក្សាឃុំ/សង្កាត់ បើយោងតាមសេចក្ដីថែងនៅក្នុង

តទៅទំព័រទី ១៣...

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

ក្នុងប៉ុន្មានខែដើមឆ្នាំ២០០៣ សេដ្ឋកិច្ចពិភពលោកស្ថិតក្នុងស្ថានភាពស្ពឹកទ្រឹង សំខាន់គឺដោយសារការភ័យខ្លាចពីការជិតផ្ទុះសង្គ្រាមនៅអ៊ីរ៉ាក់ ការថយចុះទំនុកចិត្តរបស់អ្នកវិនិយោគ និងការគំរាមកំហែងនៃការឡើងថ្លៃប្រេង ។ នៅពេលចប់ពីសង្គ្រាម គេឃើញមានសញ្ញាមួយចំនួននៃការរើបសេដ្ឋកិច្ច ហើយប្រទេសនានាក្នុងពិភពលោកហាក់ដូចកំពុងស្ទុះឡើងវិញ ។

សេដ្ឋកិច្ចពិភពលោក បានរើបឡើងគួរកត់សំគាល់នៅឆមាសទី២ ឆ្នាំ ២០០៣ ហើយមកដល់ចុងឆ្នាំ វាមានស្ថានភាពល្អជាងមុនច្រើន ។IMF បានប៉ាន់ស្មានថា កំណើន ផសស ពិភពលោកនៅឆ្នាំ២០០៣ គឺ ៣,២% ហើយនៅឆ្នាំ២០០៤ គឺ ៤,១% ។ ការស្ទុះឡើងវិញនេះហាក់ដូចនាំមុខដោយសេដ្ឋកិច្ចរបស់អាមេរិក និងជប៉ុន, ហើយឥណ្ឌា និងចិន ក៏ជួយមួយកំរិតដែរ ដោយបានរក្សាអត្រាកំនើនសេដ្ឋកិច្ចដ៏ខ្ពស់ "ដូចធម្មតា" របស់ខ្លួន ។

អាមេរិកដែលតំនាងឱ្យ ២០% នៃសេដ្ឋកិច្ចពិភពលោកមានកំណើនយ៉ាងខ្ពស់ដល់ ៨,២%នៅត្រីមាសទី៣ ឆ្នាំ២០០៣ ដែលជាកំនើនលឿនបំផុតក្នុងរយៈ២០ឆ្នាំចុងក្រោយ ។ នៅត្រីមាសទី៤ កំណើននេះបានធ្លាក់មកត្រឹម ៤,១% វិញ ប៉ុន្តែវានៅតែខ្ពស់គួរកត់សំគាល់បើធៀបនឹងនិន្នាការក្នុងពេលកន្លងមក ពីព្រោះវាផ្តល់អត្រាកំនើនសរុបប្រចាំឆ្នាំដល់ ២,៦% ។ IMF បានប៉ាន់ស្មានថា អាមេរិកមានកំនើន ៤% នៅឆ្នាំ២០០៤ ហើយនេះជារូបភាពមួយមានសុទិដ្ឋិនិយមល្អ ។

កត្តាចំបងៗដែលធ្វើឱ្យលទ្ធផលកាន់តែវិជ្ជមានឡើងនៅឆ្នាំ២០០៣ មានជាអាទិ៍ កំនើនវិនិយោគលើសំភារៈបរិក្ខារ និងសូហ្វវែរកុំព្យូទ័រ ព្រមទាំងការរំពឹងទុកថាប្រេងនឹងចុះថ្លៃ ។ ការថយកំណើន ផសស ត្រីមាសទី៤ ២០០៣ វាឆ្លុះបញ្ចាំងពីការថយចុះកំនើនចំណាយក្នុងមនុស្សម្នាក់ និងវិនិយោគជាប់លាប់លើលំនៅដ្ឋាន ព្រមទាំងកំនើនកាន់តែលឿននៃការនាំចូល ។

នៅតំបន់អឺរ៉ូ លទ្ធផលក្នុងឆ្នាំ២០០៣ ទាំងមូលនៅតែទន់ខ្សោយ ។ សំរាប់សហភាពអឺរ៉ុប១៥ប្រទេស (EU15) កំនើនធ្លាក់ចុះពី ១% ដល់ ០,៧% ហើយសំរាប់តំបន់អឺរ៉ូ វាធ្លាក់ចុះពី ០,៩% ដល់ ០,៤% ។ នៅត្រីមាសទី៤ ២០០៣ លទ្ធផលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងត្រីមាសមុនៗដែរ ។

**អត្រាកំនើននាពេលថ្មីៗនៅ EU**

| | Q4-03 | Q3-03 | '03 | '02 |
|---|---|---|---|---|
| តំបន់អឺរ៉ូ | 0.3 | 0.4 | 0.4 | 0.9 |
| EU15 | 0.4 | 0.4 | 0.7 | 1.0 |

*ប្រភព: Eurostat, 4 March,2003*

និន្នាការទាំងនេះបានគូសបញ្ជាក់ពីការរីកធំលឿនជាងនៃវិនិយោគ និងការនាំចូល បើធៀបនឹងចំណាយប្រើប្រាស់ឯកជន និងការនាំចេញ ។ ជាទូទៅប្រតិបត្តិការឧស្សាហកម្មបានកែលំអឡើង ប៉ុន្តែពាណិជ្ជកម្ម ការដឹកជញ្ជូន និងទូរគមនាគមន៍បានធ្លាក់ចុះ ។

សេដ្ឋកិច្ចជប៉ុនបានកើនឡើងតាមអត្រាពិត ១,៦% នៅត្រីមាសទី៤ ឆ្នាំ ២០០៣ បើធៀបនឹងត្រីមាសមុន ឬកើន ៦,៤% បើគិតជាអត្រាកំនើនប្រចាំឆ្នាំ ប៉ុន្តែវានៅទាបជាងអត្រាកំនើនរំពឹងទុក (៧%) ។ គួរបញ្ជាក់ដែរថា អត្រានេះ ខ្ពស់ច្រើនជាងកំណើនសេដ្ឋកិច្ចអាមេរិកក្នុងកំឡុងពេលដូចគ្នា ។

ទិន្នន័យជញ្ជីងទូទាត់ជប៉ុន គូសបញ្ជាក់ពីភាពរឹងប៉ឹងនៃកំនើនការនាំចេញ ដែលជាកត្តាគន្លឹះជំរុញការរើបឡើងវិញ ។ ចំណាយមូលធនបានកើនឡើង ៦,៣% ។ កំណើនយ៉ាងលឿននៃអតិរេកជញ្ជីងពាណិជ្ជកម្ម បានដាក់សំពាធលើប្រាក់យ៉េន ដែលនាំឱ្យមានអន្តរាគមន៍យ៉ាងខ្លាំងទៅលើទីផ្សារដើម្បីរារាំងការឡើងថ្លៃរូបិយវត្ថុ ជាពិសេសទល់នឹងប្រាក់ដុល្លារ ។ ប៉ុន្តែប្រាក់យ៉េនបានធ្លាក់ថ្លៃជិតដល់ ១១% ទល់នឹងប្រាក់អឺរ៉ូ គិតតាំងពីឆ្នាំ២០០២មក ហើយវាបានជួយជំរុញការនាំចេញទៅអឺរ៉ុប ។ ក្រៅពីការនាំចេញដែលមានសន្ទុះខ្លាំង តំរូវការក្នុងស្រុកក៏កើនដែរ ដោយសារអ្នកប្រើមានទំនុកចិត្តឡើងវិញ ។

សេដ្ឋកិច្ច**ចិន**បានកើន ៩,៩% នៅត្រីមាសទី៤ ឆ្នាំ២០០៣ ធ្វើឱ្យមានកំណើន ៩,១% សំរាប់ពេញមួយឆ្នាំ២០០៣ ដែលជាអត្រាខ្ពស់បំផុតតាំងពីឆ្នាំ១៩៩៧ មក ។ កំនើននៅឆ្នាំ២០០៣នេះ ជំរុញឡើងដោយសារកំនើនវិនិយោគ និងតំរូវការបរទេសយ៉ាងច្រើន យោងតាមរបាយការណ៍របស់ Channel News Asia ។ ការនាំចេញផលិតផលអេឡិចត្រូនិច (ដែលតំនាងឱ្យ ១/៣ នៃការនាំចេញទំនិញជាមូលធន) បានកើនឡើងយ៉ាងខ្លាំងដល់ ៥០% បើធៀបនឹងកាលពីមួយឆ្នាំមុន ។ ផលិតផលឧស្សាហកម្មបានកើនពីកំរិត ១៣% នៅឆ្នាំ២០០២ ដល់កំរិត ១៧% នៅឆ្នាំ២០០៣ ។

ក្នុងប្រទេស**អាស៊ាន**នានា មានសញ្ញានៃការរើបឡើងវិញ ។ អត្រាកំនើននៅឆ្នាំ២០០៣ មានត្រឹម ១,១% គឺទាបជាងឆ្នាំ២០០២ ដែលមាន ១,៥% ។ សកម្មភាពសេដ្ឋកិច្ចបានកើនឡើងនៅឆមាសទី២ ឆ្នាំ២០០៣ ដោយនៅត្រីមាសទី៤ វាមានកំណើន ៣,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០០២ ដែលបណ្តាលជាសំខាន់ដោយសារកំណើនតំរូវការគ្រឿងអេឡិចត្រូនិច និងឱសថ (តាម Channel News Asia) ។

ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម (MIT) បានកែតំរូវបង្កើនតួលេខប៉ាន់ស្មានរបស់ខ្លួនសំរាប់សេដ្ឋកិច្ចសឹង្ហបូរី ក្នុងឆ្នាំ២០០៤ បន្ទាប់ពីមានការរីកលូតលាស់យ៉ាងខ្លាំងតាមអត្រាប្រចាំឆ្នាំ ១១%នៅត្រីមាសទី៤ ឆ្នាំ២០០៣ ។ ផ្អែកតាមលទ្ធផលសេដ្ឋកិច្ចឆ្នាំ២០០៣ MIT បានព្យាករណ៍ឡើងវិញថា នៅឆ្នាំ២០០៤ សេដ្ឋកិច្ចមានកំនើនពី ៣,៥% ទៅ ៥,៥% (ធៀបនឹងតួលេខចាស់ពី ៣% ទៅ ៥%) ។

កំនើននៅត្រីមាសទី៤ វាខ្ពស់ជាងអត្រាប៉ាន់ស្មានប្រចាំឆ្នាំបានកែតំរូវតាមរដូវកាលទំហំ ៧,៩% របស់រដ្ឋាភិបាល ។ ដូចគ្នាដែរ កំណើនពីមួយឆ្នាំទៅមួយឆ្នាំកំរិត ៤,៩% វាខ្ពស់ជាងតួលេខប៉ាន់ស្មានទុកជាមុនរបស់រដ្ឋាភិបាលដែលមានត្រឹមតែ ៣,៧% ។ កំនើន ផសស នៅត្រីមាសទី៤ បានចុះទាបជាងអត្រាកំណើន ១៦,១% នៅត្រីមាសទី៣ ដែលជាអត្រាកំនើនប្រចាំត្រីមាសខ្ពស់បំផុតគិតតាំងពីឆ្នាំ១៩៩៧មក ពីព្រោះនៅពេលនោះ សឹង្ហបូរីទើបស្ទុះឡើងវិញបន្ទាប់ពីការមានកើតជំងឺ SARS ។ ត្រីមាសមានលទ្ធផលល្អទាំងពីរនេះ បានជំរុញឱ្យកំនើនសរុបប្រចាំឆ្នាំ ២០០៣ ឡើងដល់ ១,១% ធៀបនឹងតួលេខប៉ាន់ស្មានត្រឹម ០,៨% របស់ MIT កាលពីខែមករា ។ កំនើន ផសស កាលពីឆ្នាំមុន ត្រូវបានជំរុញយ៉ាងខ្លាំងដោយសារកំណើនតំរូវការពីបរទេសដែលឡើងដល់ ៩,៥% និងដែលនាំឱ្យមានការនាំចេញគ្រឿងអេឡិចត្រូនិច និងផលិតផលគីមី កាន់តែច្រើនថែមទៀត ។

ផសស ថៃ កើន ៧,៨%នៅត្រីមាសទី៤ ២០០៣ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០២ ហើយនេះជាកំនើនលឿនបំផុតក្នុងរយៈ៧ឆ្នាំចុងក្រោយ ។ នៅឆ្នាំ២០០៤ សេដ្ឋកិច្ចថៃរំពឹងថាមានកំណើនពី ៧,៧ ទៅ ៨,១% ធៀបនឹងការព្យាករណ៍ពីមុនត្រឹម ៧,៥% (យោងតាមការិយាល័យគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាល)។ កំនើន ផសស ឆ្នាំ២០០៤ បានទទួលផលចំណេញពីការកែលំអក្នុងសេដ្ឋកិច្ចប្រទេសជាដៃគូពាណិជ្ជកម្មចំបងៗរបស់ថៃ

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

និងពីថវិកាបន្ថែមចំនួន ១៣៥,៩ពាន់លានបាត ។ ប៉ុន្ដែផលប៉ះពាល់អវិជ្ជមាននៃជំងឺផ្ដាសាយបក្សី និងការឡើងថ្លៃប្រាក់បាត បានកាត់បន្ថយចុះវិញនូវការរីកលូតលាស់នេះ ។ លំនឹងខាងក្រៅ និងខាងក្នុង រំពឹងថា នឹងអាចរក្សាបានយ៉ាងល្អ ។ តាមការព្យាករណ៍ សមតុល្យគណនីចរន្តនឹងបន្តមានអតិរេកដល់ទៅ ១,៧% នៃ ផសស គឺទាបជាងឆ្នាំមុនបន្តិចដោយសារការនាំចូលបានកើនឡើង ក្រោយពេលមានការរីកលូតលាស់តំរូវការក្នុងស្រុក ។ អត្រាអតិផរណារំពឹងថា បន្តនៅទាបត្រឹម ២,៤% ។

យោងតាមទិទស្សន៍សេដ្ឋកិច្ចឆ្នាំ២០០៤ សំរាប់អាស៊ីខាងកើត ដែលផ្សព្វផ្សាយដោយវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច (IDE) របស់អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (Jetro), ផសស ហ្វីលីពីន នឹងកើនឡើង ៤,៧%នៅឆ្នាំ២០០៤ ឬ ០,៣% ខ្ពស់ជាងកំនើន ផសស កាលពីឆ្នាំមុន ។ ការព្យាករណ៍របស់ IDE-Jetro គឺទាបជាងការព្យាករណ៍របស់រដ្ឋាភិបាលហ្វីលីពីននូវកំនើន ផសស ពីកំរិតអប្បបរមា ៤,៩% ដល់កំរិតអតិបរមា ៥,៨% ។ ក្នុងចំណោមប្រទេសអាស៊ាន ឥណ្ឌូនេស៊ីត្រូវបានព្យាករណ៍ថា មានកំនើន ផសសទាបបំផុតត្រឹម ៤,៥% ។ IDE បានបញ្ជាក់ថា សេដ្ឋកិច្ចអាស៊ីខាងកើត ក្រៅពីប្រទេសជប៉ុន នឹងកើនឡើងតាមអត្រាថេរ ៦,៧% នៅឆ្នាំនេះ ឬ ០,៨% ខ្ពស់ជាងឆ្នាំមុន ។ នៅឆ្នាំ២០០៤ ប្រទេសអាស៊ានមួយចំនួនគឺ ឥណ្ឌូនេស៊ី ថៃ ម៉ាឡេស៊ី ហ្វីលីពីន និងវៀតណាម, មានអត្រាកំណើនសរុបគ្នា ៥,៦% ឬ ០,៦%ខ្ពស់ជាងឆ្នាំមុន ។

**អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់**

ថ្លៃទំនិញប្រើប្រាស់នៅអាមេរិក កើនយឺតជាងមុនត្រឹម ១,៩%នៅត្រីមាសទី៤ ២០០៣ ធៀបនឹងកំរិត ២,២%កាលពីត្រីមាសមុនក្នុងពេលដែលសេដ្ឋកិច្ចបានរើបយ៉ាងខ្លាំង។ សំរាប់ពេញមួយឆ្នាំ២០០៣ ថ្លៃទំនិញប្រើប្រាស់នៅអាមេរិកកើន ២,៣% ឬ ០,៧% ខ្ពស់ជាងឆ្នាំមុន ។ នៅតំបន់អឺរ៉ូ ថ្លៃទំនិញប្រើប្រាស់មានអត្រាកំណើនយ៉ាងនឹងនត្រឹម ២%នៅឆ្នាំ២០០៣ ធៀបនឹង ២,១%នៅឆ្នាំ២០០២ ។ ថ្លៃថាមពលដែលឡើងខ្ពស់ត្រូវបានប៉ះប៉ូវដោយសារការឡើងថ្លៃប្រាក់អឺរ៉ូ ។

នៅប្រទេសជប៉ុន សំពាធបរិត្តផរណាបានថយចុះនៅត្រីមាសទី៤ ឆ្នាំ២០០៤ ដោយគ្មានការប្រែប្រួលអ្វីក្នុងសន្ទស្សន៍ថ្លៃទេ ប៉ុន្ដែបើគិតសំរាប់ពេញមួយឆ្នាំ, ថ្លៃទំនិញប្រើប្រាស់ធ្លាក់ចុះ ០,៣% ដែលជាតួលេខតូចទេបើធៀបនឹងការធ្លាក់ចុះអស់ជិត ១%នៅឆ្នាំ២០០២ ។

នៅត្រីមាសទី ៤ ឆ្នាំ២០០៣ ប្រាក់ដុល្លារបានចុះថ្លៃយ៉ាងខ្លាំងដល់កំរិតទាបបំផុតក្នុងរយៈ១៨ត្រីមាសចុងក្រោយ ដោយប្ដូរបាន ០,៨៤អឺរ៉ូ/ដុល្លារ ។ វាបន្តចុះថ្លៃទល់នឹងប្រាក់យ៉េនអស់៣ត្រីមាសជាប់គ្នា រហូតដល់កំរិត ១០៩ យ៉េន/ដុល្លារ ។

---

តពីទំព័រទី១១ **សុខដុមនីយកម្មច្បាប់...**

LAMC ។ តើអាណត្តិរបស់ NCSC នឹងត្រូវពន្យាពេលឬយ៉ាងណា ហើយបើមិនពន្យាទេ តើអង្គភាពណានឹងទទួលរ៉ាប់រងជាបន្តនូវភារកិច្ចរបស់ NCSC? តើត្រូវមានការផ្លាស់ប្ដូរ ឬវិសោធនកម្មអ្វីខ្លះក្នុងក្របខ័ណ្ឌច្បាប់/បទប្បញ្ញត្តិដែលមានស្រាប់ ដើម្បីតំរូវទៅតាមជំរើសណាមួយក្នុងចំណោមសេណារីយ៉ូទាំងពីរនេះ?

ជាទីបញ្ចប់ ត្រូវមានការសើរើពិនិត្យជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយនៃប្រព័ន្ធហិរញ្ញវត្ថុ/ថវិកា បើចង់ឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ អាចចាប់ផ្ដើមប្រមូលចំណូលពន្ធបានជាក់ស្ដែង ដូចសេចក្ដីចែងក្នុង LAMC មិនមែនត្រឹមតែកំរៃសេវានោះទេ ។ ត្រូវមានប្រព័ន្ធច្បាស់លាស់មួយថា តើចំណូលប្រភេទណាត្រូវប្រមូលដោយរតនាគារជាតិ ឬខេត្ត ឬឃុំ/សង្កាត់ ដើម្បីជៀសវាងបញ្ហាការប្រមូលពន្ធច្រើនហួស ឬការប្រមូលពន្ធត្រួតគ្នាលើប្រជាពលរដ្ឋ ។

**កំណត់សំគាល់**

១. ក្រោយការប្រកាសឱ្យប្រើ ច្បាប់អាចត្រូវក្រុមប្រឹក្សាធម្មនុញ្ញធ្វើការសើរើពិនិត្យឡើងវិញបានពីធម្មនុញ្ញភាព ប៉ុន្ដែត្រូវមានសំណើពីព្រះមហាក្សត្រ, ប្រធានព្រឹទ្ធសភាឬប្រធានរដ្ឋសភា, នាយករដ្ឋមន្ត្រី ១/៤ នៃសមាជិកព្រឹទ្ធសភា, ១/១០នៃសមាជិករដ្ឋសភា, ឬតុលាការ ។ ក្រុមប្រឹក្សាធម្មនុញ្ញគ្មានសិទ្ធិអំណាចសើរើពិនិត្យច្បាប់ស្ដីពីបញ្ហាដែលមិនទាក់ទិននឹងធម្មនុញ្ញភាពទេ ហើយក៏គ្មានសិទ្ធិអំណាចសើរើពិនិត្យលើឧបករណ៍ច្បាប់ផ្សេងទៀត ដូចជា អនុក្រឹត្យ ឬប្រកាសនោះដែរ ។

២. រដ្ឋធម្មនុញ្ញ មាត្រា ២១

៣. ច្បាប់/បទប្បញ្ញត្តិនានាដែលបានអនុម័តហើយ មានលក្ខណៈសមស្របតាមកំរិតគុណភាពដែលឃើញមានជាធម្មតា ក្នុងការតាក់តែងឯកសារ

**ឯកសារបោះពុម្ពថ្មីៗ**

- ឯកសារពិភាក្សាលេខ ២៨: *ពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា: ការប្រឈម ការគំរាមគំហែង និងឱកាសល្អសំរាប់ជ័រទឹក* (អង់គ្លេស និងខ្មែរ) ដោយ ព្រំ តុលា និង Bruce McKenney (2003); ឯកសារពិភាក្សាលេខ ២៩: *ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (អង់គ្លេស និងខ្មែរ) ដោយ យឹម ជា និង Bruce McKenney (2003); *របាយការណ៍ស្ដីពីការប្រមើលមើលពីលំនាំថ្មីនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា* (អង់គ្លេស និងខ្មែរ) ដោយ អេវ៉ា មីស្លីវិក (២០០៤) និង សៀវភៅបោះពុម្ពលើកទីពីរ: សៀវភៅគំនូរប្ញបនភាគស្ដីពី *ព្រះពុទ្ធជាអ្នកកសាងសន្តិភាព* ។
- ឯកសារដែលនឹងបោះពុម្ពឆាប់ៗនេះគឺ ឯកសារពិភាក្សាលេខ ៣០: *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ករណីសិក្សាប្រៀបធៀបរវាងការបោះឆ្នោតបីលើកនៅកម្ពុជា* និង ឯកសារពិភាក្សាលេខ ៣១: ស្ដីពី *សុខដុមនីយកម្មច្បាប់ជាប់ទាក់ទងនឹងវិមជ្ឈការ* ។

## តារាង១. កំនើន ផសស ពិតនៃដៃគូពាណិជ្ជកម្មជ្រើសរើសពីឆ្នាំ២០០០-២០០៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2000 | 2001 | 2002 | | | 2003 | | | | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.3 | 6.7 | - | - | - | - | - | - | - | 4.2 |
| ឥណ្ឌូនេស៊ី | 4.4 | 3.8 | 3.5 | 3.9 | 3.8 | 3.4 | 3.8 | 3.9 | 4.3 | 3.8 |
| ម៉ាឡេស៊ី | 8.7 | 0.5 | 3.8 | 5.6 | 5.4 | 4.0 | 4.4 | 3.5 | 6.4 | 5.6 |
| សិង្ហបុរី | 9.5 | -2.3 | 3.9 | 3.7 | 3.0 | 1.6 | -4.2 | 1.7 | 3.7 | 2.6 |
| ថៃ | 4.4 | 1.9 | 5.1 | 5.8 | 5.6 | 6.7 | 5.8 | 6.5 | 7.8 | 6.1 |
| វៀតណាម | | 6.0 | - | - | - | - | 6.9 | - | - | 6.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.0 | 7.5 | 8.0 | 8.1 | 8.1 | 9.9 | 6.7 | 9.1 | 9.9 | 8.1 |
| ហុងកុង | 10.6 | 0.3 | 0.5 | 3.3 | 5.0 | 4.5 | -0.5 | 4.0 | - | 5.0 |
| កូរ៉េខាងត្បូង | 9.1 | 3.0 | 6.3 | 5.8 | 6.8 | 3.7 | 1.9 | 2.3 | - | 6.1 |
| តៃវ៉ាន់ | 6.0 | -2.1 | 3.0 | 4.8 | 4.2 | 3.2 | -0.4 | 4.2 | 5.4 | 4.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ | 3.5 | 1.4 | 0.7 | 0.8 | 1.3 | 0.8 | 0.2 | 0.3 | 0.6 | 0.7 |
| ជប៉ុន | 1.6 | -1.3 | -0.7 | 1.3 | 2.8 | 2.6 | 3.0 | 1.8 | 3.6 | 0.5 |
| សហរដ្ឋអាមេរិក | 5.0 | 1.2 | 2.1 | 3.2 | 2.9 | 2.1 | 2.5 | 8.2% | 4.3 | 2.4 |

## តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | | 2003 | | | | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.3 | -0.4 | 3.3 | 3.5 | 3.0 | 1.8 | 1.6 | 0.7 | 0.5 | 3.3 |
| ឥណ្ឌូនេស៊ី | 3.7 | 11.3 | 12.6 | 10.2 | 10.3 | 7.7 | 6.5 | 5.6 | 3.7 | 11.9 |
| ម៉ាឡេស៊ី | 1.5 | 1.4 | 1.9 | 2.1 | 1.9 | 1.3 | 0.9 | 1.0 | 1.1 | 1.9 |
| សិង្ហបុរី | 1.4 | 1.0 | -0.4 | -0.4 | 0.1 | 0.7 | 0.1 | 3.2 | 0.5 | -0.4 |
| ថៃ | 1.6 | 1.8 | 0.2 | 0.3 | 1.4 | 2.0 | 1.7 | 1.8 | 1.5 | 0.6 |
| វៀតណាម | -1.7 | 0.0 | 2.7 | 2.9 | 3.7 | 2.2 | 2.3 | 3.5 | 2.2 | 2.8 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.3 | 1.0 | -0.7 | -0.8 | -0.6 | 0.5 | 0.6 | 0.8 | - | -0.7 |
| ហុងកុង | -3.7 | -1.5 | -3.1 | -3.5 | -2.9 | -2.0 | -.25 | -3.7 | -2.5 | -3.1 |
| កូរ៉េខាងត្បូង | 2.3 | 4.3 | 2.7 | 2.5 | 3.2 | 4.1 | 3.3 | 3.1 | 3.5 | 2.7 |
| តៃវ៉ាន់ | 1.4 | 0.5 | -0.1 | -0.3 | -0.5 | 0.3 | -0.1 | - | - | -0.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ | 2.3 | 2.6 | 2.0 | 2.0 | 2.3 | 2.4 | 2.0 | 2.0 | 1.9 | 2.2 |
| ជប៉ុន | -0.6 | -0.5 | -0.9 | -0.8 | -0.5 | -0.3 | - 0.2 | -0.3 | 0 | -0.9 |
| សហរដ្ឋអាមេរិក | 3.4 | 2.9 | 1.3 | 1.6 | 2.2 | 2.9 | 2.1 | 2.2 | 1.9 | 1.6 |

## តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | | 2003 | | | | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,871 | 3,935 | 3,916 | 3,935 | 3,948 | 3,948 | 4,008 | 4,015 | 3,999 | 3,927 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8,421 | 10,236 | 9,077 | 8,940 | 9,027 | 8,884 | 8,428 | 8482 | 8,484 | 9,280 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.80 | 3.8 | 3.8 | 3.8 | 3.8 | 3.8 | 3.8 | 3.80 |
| សឹង្ហបុរី (ដុល្លារសឹង្ហបុរី) | 1.72 | 1.79 | 1.81 | 1.76 | 1.77 | 1.74 | 1.75 | 1.75 | 1.71 | 1.79 |
| ថៃ (បាត) | 40.1 | 44.4 | 42.78 | 42.09 | 43.4 | 42.7 | 42.2 | 41.5 | 39.8 | 43.0 |
| វៀតណាម (ដុង) | 14,083 | 14,827 | 15,231 | 15,314 | 15,297 | 15,427 | 15,470 | 15,.693 | 16,151 | 15,246 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ុន) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.27 | 8.28 | 8.28 | 8.28 | 8.28 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.79 | 7.75 | 7.80 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,131 | 1,291 | 1,273 | 1,197 | 1,214 | 1,199 | 1,206 | 1,184 | 1,183 | 1,251 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.8 | 34.1 | 33.8 | 33.8 | 34.8 | 34.7 | 35.0 | 34.2 | 34.0 | 34.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ (អឺរ៉ូ) | 1.08 | 1.12 | 1.09 | 1.02 | 1.00 | 0.93 | 0.88 | 0.88 | 0.84 | 1.07 |
| ជប៉ុន (យ៉េន) | 108 | 122 | 127.6 | 119.6 | 123.0 | 118 | 119.1 | 117.7 | 109.1 | 126 |

## តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ ២០០០-២០០៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | | 2003 | | | | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1-Q4 |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 190.1 | 160.1 | 153.0 | 178.7 | 181.2 | 186.3 | 182.1 | 183.0 | 197 | 162.5 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 599.2 | 488.3 | 493.0 | 536 | 565.4 | 550.4 | 552.4 | 552.0 | 545.5 | 518.5 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 720.8 | 602.0 | 754.0 | 863 | 834.1 | 945.5 | 975.8 | 1017.4 | 1261.4 | 768.4 |
| អង្ករ - បាងកក ($/តោន) | 203.7 | 172.6 | 196.6 | 192.6 | 189.6 | 198.3 | 197.5 | 199.6 | 196 | 193.1 |
| សណ្តែកសៀង - សហរដ្ឋអាមេរិក ($/តោន) | 211.3 | 195.6 | 189.8 | 219.3 | 239.0 | 243.3 | 245.7 | 244.3 | 219.7 | 202.3 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.1 | 22.8 | 24.3 | 25.4 | 26.2 | 29.3 | 24.5 | 26.5 | 27 | 24.0 |
| មាស – London ($/troy ounces) | 279.0 | 279.0 | 280.9 | 313.7 | 317.8 | 352.1 | 346.7 | 363.3 | 384.4 | 298.3 |

*ប្រភព: តារាង ១: ទស្សនាវដ្តីThe Economist និងការិយាល័យស្ថិតិជាតិ និងធនាគារកណ្តាលនានា, តារាង ២ និង ៤: មូលនិធិរូបិយវត្ថុអន្តរជាតិ និងទស្សនាវដ្តីThe Economist, តារាង ៣ : មូលនិធិរូបិយវត្ថុអន្តរជាតិ, ទស្សនាវដ្តីThe Economist និងធនាគារជាតិនៃកម្ពុជា*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០០៣ សេដ្ឋកិច្ចកម្ពុជាមាននិន្នាការចំរុះក្នុងមុខសកម្មភាពសំខាន់ៗ បើធៀបនឹងត្រីមាសទី៣ ។ កំណើនក្នុងវិស័យទេសចរណ៍ និងវិស័យសាងសង់ ត្រូវបានកាត់កងវិញដោយសារការថយកំនើនក្នុងវិនិយោគឯកជន និងពាណិជ្ជកម្មក្រៅប្រទេស ។

វិស័យទេសចរណ៍កម្ពុជា បានរីកដុះដាលនៅត្រីមាសទី៤ ២០០៣ ។ ចំនួនភ្ញៀវអន្តរជាតិសរុបដែលចូលមកតាមគ្រប់មធ្យោបាយដឹកជញ្ជូនបានកើន ៤៥,៦% (ដល់ ២៣០.៦០០នាក់) ធៀបនឹងត្រីមាសទី៣ ។ ភ្ញៀវមកដល់តាមយន្តហោះកើន ៥៦,៤% ដល់ ១៥៣.០០០នាក់ ក្នុងនេះកត្តាសំខាន់គឺភ្ញៀវចូលតាមអាកាសយានដ្ឋានសៀមរាបដែលកើនខ្ពស់គួរកត់សំគាល់ដល់ ៧៣.០០០នាក់ ធៀបនឹង ៣១.០០០នាក់ នៅត្រីមាសទី៣ ។ ថ្វីបើក្នុងឆ្នាំមុនៗ ភ្ញៀវកើនឡើងនៅត្រីមាសទី៣ និងទី៤ ទាំងនៅអាកាសយានដ្ឋាននៅភ្នំពេញ និងសៀមរាបក្តី ប៉ុន្តែកំណើនយ៉ាងគំហុកតាមច្រកសៀមរាបអាចបណ្តាលមួយចំណែកដោយសារជើងហោះហើរផ្ទាល់ថ្មីៗ ដូចជាមកពីវៀតណាមជាដើម ។ នៅត្រីមាសទី៤ ២០០៣ ភ្ញៀវមកពីវៀតណាមឡើងដល់ ៣៦.៤៨៤នាក់ គឺស្ទុះពី ១៤.១៤៨នាក់កាលពីត្រីមាសមុន ។

ជាបន្ថែមលើចំនួនភ្ញៀវបរទេសដ៏ច្រើននេះ ទេសចរណ៍ក្នុងស្រុកក៏បង្កើនចំណែករបស់ខ្លួនដែរ ។ នៅត្រីមាសទី៤ ២០០៣ មានប្រជាជនកម្ពុជា ៣៧.៧៨០នាក់ទៅទស្សនាខេត្តសៀមរាប គឺមានកំណើន ៥០,៤%ធៀបនឹងត្រីមាសទី៣ ២០០៣ ឬ កំណើន ១៨,៧% បើធៀបនឹងត្រីមាសទី៤ ២០០២ ។ កំណើនទេសចរណ៍ក្នុងស្រុកប្រហែលជាប់ទាក់ទងនឹងការកែលំអខាងហេដ្ឋារចនាសម្ព័ន្ធ ។ ពីឆ្នាំ១៩៩២-២០០១ អ្នកផ្តល់ជំនួយពហុភាគី និងទ្វេភាគី ព្រមទាំង NGOs ផង បានផ្តល់កំចី និងអំណោយ ១.០៤៩លានដុល្លារដល់វិស័យ "អភិវឌ្ឍន៍ជនបទ" និង "ដឹកជញ្ជូន" ។ តាមពត៌មានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) រាជរដ្ឋាភិបាលកម្ពុជា គ្រោងធ្វើវិនិយោគ ១៦៨,៧លានដុល្លារ ពីឆ្នាំ២០០២-២០០៤ ទៅលើផ្លូវថ្នល់នានា ។ រឿងនេះអាចជួយជំរុញទេសចរណ៍ក្នុងស្រុកមួយកំរិតទៀតក្នុងប៉ុន្មានឆ្នាំខាងមុខ ។

កត្តាចំបងមួយទៀតក្នុងសេដ្ឋកិច្ចកម្ពុជានៅត្រីមាសទី៤ ២០០៣ គឺវិស័យសាងសង់ ។ នាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រក្រុងភ្នំពេញ បានអនុម័តគំរោងសាងសង់ផ្សេងៗមានតំលៃសរុប ៥៤,៧លានដុល្លារនៅត្រីមាសទី៤ ឬ ២៤%ច្រើនជាងត្រីមាសមុន ។ គំរោងសាងសង់អាគារពាណិជ្ជកម្មនៅភ្នំពេញដែលបានទទួលការអនុម័ត បានកើនជាងពីរដងដល់ ៣៥.៦លានដុល្លារ ។ បើគិតជាផ្ទៃក្រឡា គំរោងផ្សេងៗដែលបានអនុម័តមានផ្ទៃសរុប ២៩០.២០៦ម$^{២}$ (ធៀបនឹង ២៥៩.០៥៨ម$^{២}$ នៅត្រីមាសទី៣) ក្នុងនេះអគារពាណិជ្ជកម្មមាន ៦១,៤% ត្រូវជា ១៧៨.១៩៧ម$^{២}$ (ធៀបនឹង ៧៣.៥៣៦ម$^{២}$ នៅត្រីមាសមុន និង ៣០.៩៥៤ម$^{២}$ នៅត្រីមាសទី៤ ២០០២) ។

កំណើនកំចីធនាគារសំរាប់ការសាងសង់ ក៏បង្ហាញពីកំណើនសកម្មភាពក្នុងវិស័យនេះដែរ ។ នៅត្រីមាសទី៤ ២០០៣ ធនាគារពាណិជ្ជផ្តល់ឥណទាន ២០,៨លានដុល្លារសំរាប់សកម្មភាពសាងសង់នៅភ្នំពេញ ឬ ៣,៧%ច្រើនជាងត្រីមាសមុន, ហើយធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០២ វាកើន ៣៦,៦% ។

ការរីកចំរើនក្នុងវិស័យទេសចរណ៍ និងសាងសង់ ត្រូវបានរាំងខ្ទប់ឥទ្ធិពលវិញដោយសារការរួមចុះក្នុងវិនិយោគឯកជន និងពាណិជ្ជកម្មក្រៅប្រទេស ។ នៅត្រីមាសទី៤ ២០០៣ CDC បានអនុម័តគំរោងវិនិយោគឯកជនមានតំលៃសរុប ៦២,១លានដុល្លារ ឬ ៣៤,៧% តិចជាងត្រីមាសទី៣ ដោយវិនិយោគក្នុងវិស័យកាត់ដេរបានធ្លាក់យ៉ាងខ្លាំងចុះដល់ ១៤,៥លានដុល្លារ ធៀបនឹង ៤៣,៣លានដុល្លារនៅត្រីមាសទី៣ ២០០៣ ។ តាមនិន្នាការឆ្នាំមុនៗ ចំនួនគំរោងវិនិយោគអនុម័តដោយ CDC តែងថយចុះនៅត្រីមាសទី៣ និងទី៤ ។

ដូចបានព្យាករណ៍ ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាមានឱនភាព ៤៨,៧លានដុល្លារនៅត្រីមាសទី៤ ២០០៣ គឺផ្ទុយពីត្រីមាសទី៣ ដែលមានអតិរេក ៥៦,១លានដុល្លារ ។ រឿងនេះឆ្លុះបញ្ចាំងពីឥទ្ធិពលគួបគ្នានៃការថយចុះការនាំចេញ និងកំណើនការនាំចូល ។ ការនាំចេញសរុបថយចុះ ៣,៤% ដល់ ៤៧៥,៧លានដុល្លារនៅត្រីមាសទី៤ ធៀបនឹង ៤៩២,៣លានដុល្លារនៅត្រីមាសទី៣ ។ ការនាំចេញសំលៀកបំពាក់ដែលតំណាងឱ្យ ៩៥% នៃការនាំចេញសរុបរបស់កម្ពុជាបានថយចុះ ៥,៦% ប៉ុន្តែនៅមានទំហំ ១៦,៤% ខ្ពស់ជាងការនាំចេញនៅត្រីមាសទី៤ ២០០២ ។ ទិន្នន័យនាំចេញសំលៀកបំពាក់ក្នុងច្រើនឆ្នាំកន្លងមកនេះបង្ហាញថា ការនាំចេញតែងចុះទាបបំផុតនៅត្រីមាសទី១ និងឡើងខ្ពស់បំផុតនៅត្រីមាសទី៣។ យោងតាមនិន្នាការនេះ ការនាំចេញសំលៀកបំពាក់ពីកម្ពុជា រំពឹងថានឹងធ្លាក់ចុះនៅត្រីមាសទី១ ២០០៤ ។

តំលៃនៃការនាំចូលសរុបបានស្ទុះឡើង ១៤% ដល់ ៤៩៧លានដុល្លារនៅត្រីមាសទី៤ ២០០៣ គឺកើនពី ៤៣៦,២លានដុល្លារនៅត្រីមាសទី៣ ។ ក្នុងនេះការនាំចូលបារីមានចំណែកយ៉ាងសំខាន់ដោយកើនឡើង ៤៤,៤% ដល់ ២១,២លានដុល្លារ ។ ម្យ៉ាងទៀត តំលៃនៃការនាំចូលម៉ូតូកើនទ្វេមួយជាពីរដល់ ៨លានដុល្លារ ឯការនាំចូលប្រេងកាត (kerosene) ក៏កើនទ្វេដែរដល់ ៨លានដុល្លារដូចគ្នា ហើយការនាំចូលសាំងកើន ៦០,៧% ដល់ ៩លានដុល្លារ។ តាមពត៌មានពីក្រសួងពាណិជ្ជកម្ម ការនាំចូលសរុបរបស់កម្ពុជាកើន ១៣,៣%នៅ ត្រីមាសទី៤ ២០០៣ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០២ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅកម្ពុជា វិន័យខាងហិរញ្ញវត្ថុហាក់ដូចមានការកែលំអនៅត្រីមាសទី៤ ២០០៣ ។ ធៀបនឹងត្រីមាសទី៣ ចំណាយថវិកាបានថយចុះ ១២% ដល់ ៥៨២ពាន់លានរៀលនៅត្រីមាសទី៤ ២០០៣ ហើយចំណូលថវិកាបានស្ទុះឡើង ២៦,៣% ដល់ ៥០៦ពាន់លានរៀល ។ ដោយមូលហេតុនេះ ឱនភាពសរុបថយចុះដល់ ៧៦,៥ពាន់លានរៀល នៅត្រីមាសទី៤ ២០០៣ ធៀបនឹង ២៦១ពាន់លានរៀលនៅត្រីមាសមុន ។

ការថយចុះចំណាយសាធារណៈនៅត្រីមាសទី៤ ជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការថយចុះយ៉ាងគំហុកនៃចំណាយជាមូលធន (ចុះ ២៧%) ដល់ ២០៥ពាន់លានរៀល គឺចុះពី ២៧៩,៦ពាន់លានរៀលនៅត្រីមាសទី៣ ហើយបើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន វិនិយោគសាធារណៈនេះថយចុះខ្លាំងណាស់អស់ ៤០% ។ សំរាប់ឆ្នាំ២០០៣ ទាំងមូល ចំណាយជាមូលធនអនុវត្តបាន ៩៦,៥%នៃផែនការកំណត់ក្នុងច្បាប់ថវិកា ថ្វីបើមានកង្វះខាតហិរញ្ញវត្ថុក្នុងស្រុកក្តី ពីព្រោះជំនួយពីក្រៅប្រទេសបានលើសពីផែនការ (១០៤%) ។

ការកែលំអក្នុងចំណូលថវិកា បានឆ្លុះបញ្ចាំងពីកំណើនគួរកត់សំគាល់ក្នុងចំណូលចរន្ត (កើន ២៦%) ដល់ ៥០៦ពាន់លានរៀលនៅត្រីមាសទី៤ ធៀបនឹង ៣៩៩ពាន់លានរៀលនៅត្រីមាសទី៣ ។ ចំណូលពន្ធដែលមានចំណែកធំបំផុត (៧០%)ក្នុងចំណូលចរន្ត កើនបាន ២៩% ដល់ ៣៤៩ពាន់លានរៀល ក្នុងនេះចំណូលពន្ធគយមាន ១១៧ពាន់លានរៀល ។ ពីត្រីមាសទី៣ ដល់ត្រីមាសទី៤ ចំណូលមិនមែនពន្ធកើន ២៤,៦% ដល់ ១៥៧ពាន់លានរៀល ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## អតិផរណា និងអត្រាប្ដូរប្រាក់បរទេស

នៅត្រីមាសទី៤ ២០០៣ ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញកើនបន្តិចបន្តួចត្រឹម ០,០៥% បើធៀបនឹងត្រីមាសទី៣ ។ រឿងនេះឆ្លុះបញ្ចាំងពីនិន្នាការប៉ះប៉ូវឱ្យគ្នារវាងថ្លៃសេវា និងទំនិញប្រើប្រាស់ផ្សេងៗ ។ ពីត្រីមាសទី៣ ដល់ ទី៤ ២០០៣ តំលៃដឹកជញ្ជូន និងទូរគមនាគមន៍កើន ១,២% ដែលបង្កជាសំខាន់ដោយកំនើនថ្លៃសាំង ១,៤% ដល់ ២.៤០០រៀល/លីត្រ និងកំនើនថ្លៃម៉ាស៊ូត ១% ដល់ ១.៧០០រៀល/លីត្រ ។ ប៉ុន្ដែកំណើនថ្លៃនេះត្រូវបានប៉ះប៉ូវវិញដោយសារការចុះថ្លៃទំនិញផ្សេងៗទៀត ។ ពីត្រីមាសទី៣ ដល់ ទី៤ ២០០៣ ថ្លៃសំលៀកបំពាក់និងស្បែកជើងថយចុះ ០,៥% ហើយកំរិតថ្លៃក្នុងមុខចំនាយផ្សេងទៀតដូចជា អាហារនិងភេសជ្ជៈ "ផ្ទះ និងផ្គត់ផ្គង់សាធារណៈ" "សម្ភារឹមក្នុងផ្ទះ និងប្រតិបត្តិការក្នុងគ្រួសារ" និង "ថែទាំសុខភាព" ក៏ថយចុះបន្តិចដែរ ។ ផ្អែកលើការប្រៀបធៀបក្នុងរយៈ១២ខែ អត្រាអតិផរណាបន្តថយចុះអស់៥ត្រីមាសជាប់គ្នាដល់កំរិត ០,៥%នៅត្រីមាសទី៤ ២០០៣ គឺចុះពី ០,៨%នៅត្រីមាសទី៣ ។ កំណើនថ្លៃយឺតនេះ បង្កឡើងដោយការធ្លាក់ចុះថ្លៃថែទាំសុខភាព (២,៥%) ដែលកាត់បន្ថយឥទ្ធិពលនៃការឡើងថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ (៥,១%) ។

នៅត្រីមាសទី៤ ២០០៣ ប្រាក់រៀលកម្ពុជាឡើងថ្លៃបន្តិចបន្តួចទល់នឹងដុល្លារអាមេរិកដោយប្ដូរបាន ៣.៩៩៩រៀល/ដុល្លារ ធៀបនឹង ៤.០១៥រៀល/ដុល្លារនៅត្រីមាសមុន ។ រឿងនេះអាចបង្កឡើងជាសំខាន់ដោយការចុះខ្សោយជាទូទៅនៃប្រាក់ដុល្លារក្នុងទីផ្សារពិភពលោក និងការកែលំអគួរកត់សំគាល់ក្នុងវិន័យខាងហិរញ្ញវត្ថុនៅកម្ពុជា នៅត្រីមាសទី៤ ។

ទល់នឹងប្រាក់បាតថៃ ប្រាក់រៀលកម្ពុជាចុះថ្លៃ ៣,៧% ដល់ ១០០,៥រៀល/បាត នៅត្រីមាសទី៤ ធៀបនឹង ៩៦,៩រៀល/បាតនៅត្រីមាសមុន ។ កត្ដាសំខាន់ គឺប្រាក់បាតបានឡើងថ្លៃគួរកត់សំគាល់ដល់ ៤,៩% ទល់នឹងដុល្លារអាមេរិក ។ ប្រាក់រៀលប្រែប្រួលតិចតួចណាស់ទល់នឹងប្រាក់ដុងវៀតណាមដោយប្ដូរបាន ២៤,៨រៀល/១០០ដុង នៅត្រីមាសទី៤ ២០០៣ ធៀបនឹង ២៤,៩រៀល/១០០ដុងនៅត្រីមាសទី៣ ។

## ការវិវត្តន៍រូបិយវត្ថុ

នៅចុងត្រីមាសទី៤ ២០០៣ ការផ្គត់ផ្គង់សាច់ប្រាក់សំរាប់សេដ្ឋកិច្ចកម្ពុជាឡើងដល់ ៣.៣១៩ពាន់លានរៀល ឬ ១០,៤%ខ្ពស់ជាងកាលពីចុងត្រីមាសទី៣ ។ ប្រាក់រៀល និងដុល្លារ តំណាងឱ្យ ២៨% និង ៧២% នៃការផ្គត់ផ្គង់សាច់ប្រាក់ ។ នៅចុងឆ្នាំ២០០៣ រូបិយវត្ថុទូទៅ M2 កើនយ៉ាងច្រើនដល់ទៅ ១៤,៩% បើធៀបនឹងចុងឆ្នាំ២០០២ ។ កត្ដាជំរុញចំបងគឺ កំណើនយ៉ាងខ្លាំងដល់ ២៩,៤% នៃឥណទានក្នុងស្រុក ។ នៅចុងឆ្នាំ២០០៣ ឥណទានដែលវិស័យឯកជននៅជំពាក់ឡើងដល់ ១.៣៤៧ពាន់លានរៀល (ត្រូវជា ៣៣៨,៤លានដុល្លារ) ឬ ២៧,២%ខ្ពស់ជាងកាលពីមួយឆ្នាំមុន ។ ក្នុងពេលជាមួយគ្នា ធនាគារបានផ្ដល់កំចីឱ្យរដ្ឋាភិបាល ៩១ពាន់លានរៀល (២៣លានដុល្លារ) ឬ ១២២%ខ្ពស់ជាងកាលពីមួយឆ្នាំមុន ។ ប៉ុន្ដែប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅនឹងអាជ្ញាធររូបិយវត្ថុ បានកើនគួរកត់សំគាល់ (៧,៤%) ដល់ ១២៨ពាន់លានរៀល (ឬ ៣២លានដុល្លារ) នៅចុងឆ្នាំ២០០៣ ធៀបនឹង ១១៩ពាន់លានរៀល (ឬ ៣០លានដុល្លារ) នៅឆ្នាំ២០០២ ។ រឿងនេះបានជួយកាត់បន្ថយកំណើនរូបិយវត្ថុ និងសំពាធលើកំរិតថ្លៃ បង្កឡើងដោយកំនើនកំចីដែលធនាគារឯកជនផ្ដល់ឱ្យ ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលរបស់ពលករងាយរងគ្រោះ

អង្កេត វបសអ លើពលករងាយរងគ្រោះនៅខែកុម្ភៈ ២០០៤ បានរកឃើញថា ៨ក្រុម ក្នុងចំណោមពលករងាយរងគ្រោះទាំង១០ក្រុម មាន*ប្រាក់ចំនូលចារិក*កើនឡើង បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។ មានតែ២ក្រុមប៉ុណ្ណោះដែលថយចុះប្រាក់ចំណូលចារិក ។

ដោយសារឥទ្ធិពលមួយកំរិតនៃកំណើនសកម្មភាពក្នុងពេលចូលឆ្នាំចិន ប្រាក់ចំណូលអ្នកធាក់ស៊ីក្លូ កើន ៣,៣% ដល់ ៩.៥០០រៀល/ថ្ងៃ នៅខែកុម្ភៈ ២០០៤ បើធៀបនឹងកាលពីមួយឆ្នាំមុន ឯប្រាក់ចំណូលអ្នកលីសែង កើនបាន ១៤% ។ ក្នុងពេលជាមួយគ្នា ប្រាក់ចំណូលអ្នករើសអេតចាយកើន ២៤%ដល់កំរិតខ្ពស់បំផុតក្នុងរយៈ២ឆ្នាំចុងក្រោយ ឯប្រាក់ចំណូលកម្មករសំណង់គ្មានជំនាញកើន ១៧% ។ ចំណូលប្រចាំថ្ងៃរបស់អ្នកបំរើតាមភោជនីយដ្ឋានកើនជាមធ្យម ៦,៥% ក្នុងរយៈ១២ខែដល់ចុងខែកុម្ភៈ ២០០៤ ប៉ុន្ដែក្នុងនេះមានពលករតែ ៤៥% ទេ ដែលរាយការណ៍ថាមានកំណើន រីឯអ្នកឯទៀតប្រាប់ថាប្រាក់ចំណូលរបស់ខ្លួននៅដដែល ឬថយចុះ ។

កម្មករសំណង់មានជំនាញនៅភ្នំពេញដែលជាក្រុមមានចំណូលខ្ពស់ជាងគេរកចំណូលបាន ១០%ខ្ពស់ជាងកាលពីមួយឆ្នាំមុន ប៉ុន្ដែមានកំរិត ១៨%ទាបជាងកាលពីខែវិច្ឆិកា ២០០៣ ។ម្យ៉ាងទៀត ពួកគេរកចំណូលបាន ៤៨%ខ្ពស់ជាងកម្មករសំណង់មានជំនាញនៅខេត្តកំពង់ចាម ។ ជាមធ្យម កម្មករសំណង់មានជំនាញនៅកំពង់ចាមទទួលបាន ៨.០០០រៀល/ថ្ងៃ រីឯកម្មករសំណង់មានជំនាញនៅភ្នំពេញទទួលបាន ១៣.៨០០រៀល/ថ្ងៃ ។ គួរកត់សំគាល់ដែរថា ៨០%នៃកម្មករសំណង់នៅភ្នំពេញធ្វើចំណាកស្រុកមកពីខេត្ត ក្នុងនេះ ៤២% មានដីកសិកម្មតិចជាង ១ហិកតា និង ១៣%គ្មានដីកសិកម្មទេ ។ កម្មករសំណង់នៅភ្នំពេញភាគច្រើន (៧០%) ប្រាប់ថា ឃើញមានសកម្មភាពសាងសង់ច្រើនក្នុងរយៈមួយឆ្នាំកន្លងទៅនេះ ។

ប្រាក់ចំនូលអ្នកស៊ីឈ្នួលធ្វើស្រែកើន ៧% ក្នុងរយៈ១២ខែដល់ចុងខែកុម្ភៈ ២០០៤ ។ ថ្វីបើចំនូលនេះទាប ប៉ុន្ដែវាជាប្រភពចំនូលចំបងសំរាប់ពលករភាគច្រើន (៩២%) នៃក្រុមនេះ បើតាមការឆ្លើយសំភាសន៍។ អ្នកស៊ីឈ្នួលធ្វើស្រែក្មេងៗភាគច្រើនប្រាប់ថា ពួកគេចង់រកការងារធ្វើក្នុងវិស័យកាត់ដេរ ។

ខុសប្លែកពីក្រុមនានាខាងលើ អ្នករត់ម៉ូតូឌុបថយចំនូល ២%នៅខែកុម្ភៈ ២០០៤ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ពួកគេភាគច្រើន (៧៧%) គិតថាការថយចុះបង្កឡើងដោយកំណើនថ្លៃសាំង និងកំនើនចំនួនអ្នករត់ម៉ូតូឌុប ។

ប្រាក់ចំនូលកម្មករកាត់ដេរក៏ថយចុះបន្តិចដែរដល់ ៩.៧០០រៀល/ថ្ងៃ នៅខែកុម្ភៈ ២០០៤ ធៀបនឹងកំរិត ១០.១២៧រៀល/ថ្ងៃដែលបានរាយការណ៍ឡើងកាលពីអង្កេតលើកមុន ។ ជាមធ្យមពួកគេមានចំណូល ៦៣ដុល្លារ/ខែ ដែលមានបូកទាំងប្រាក់ម៉ោងបន្ថែម និងប្រាក់បន្ថែមផ្សេងទៀតផង ។ ក្នុងនេះពលករចំណាយអស់ជាមធ្យម ២៧ដុល្លារ ដើម្បីដោះស្រាយការរស់នៅ ឯប្រាក់នៅសល់គេផ្ញើទៅផ្ទះដើម្បីជួយទ្រទ្រង់គ្រួសារ ។ ពលករ ៤៦% ប្រាប់ថា ពួកខ្លួនចង់ប្ដូរការងារ ដោយសារតែរឿងត្រូវធ្វើការម៉ោងបន្ថែមដែលគេតែងប្រាប់មុនឆាប់ៗពេក ។ អ្នកឆ្លើយសំភាសន៍ជាងពាក់កណ្ដាលប្រាប់ថា ចង់បើកអាជីវកម្មតូចៗ ប៉ុន្ដែគិតថាប្រហែលមិនអាចសន្សំប្រាក់បានគ្រប់គ្រាន់ដើម្បីសំរេចគោលដៅនេះទេ ។

*ដោយបណ្ឌិត កង ច័ន្ទតារាវ័ត្ថ លោកស្រី ប៊ុន ដូរីណា*
*និង កញ្ញា អ៊ូច ច័ន្ទតារានី*

# តាមដានសេដ្ឋកិច្ច ~ អាំងឌីកាទ័រ

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៦-២០០៣

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | 2003 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនគំរោងវិនិយោគ | | | | | | | | | | | |
| សរុប | 300 | 136 | 140 | 96 | 96 | 188 | 11 | 8 | 20 | 14 | 17 | 15 |
| កាត់ដេរ | 144 | 48 | 84 | 44 | 52 | 76 | 5 | 2 | 6 | 7 | 12 | 6 |
| | មូលធនបានចុះបញ្ជី (លានដុល្លារ) | | | | | | | | | | | |
| សរុប | 391.2 | 278 | 416.4 | 246.8 | 102.4 | 129.2 | 12.1 | 20.3 | 41.6 | 10.4 | 4.0 | 15.4 |
| កាត់ដេរ | 156.8 | 34.4 | 91.6 | 55.6 | 25.6 | 60 | 5 | 1 | 5 | 4.1 | 1.0 | 5.8 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| សរុប | 746.8 | 761.6 | 849.2 | 474 | 266.4 | 217.2 | 127.6 | 60.9 | 108.5 | 48.3 | 95.1 | 62.1 |
| កាត់ដេរ | 158.4 | 38.8 | 120.8 | 79.6 | 76.8 | 100 | 5.5 | 1.7 | 6.5 | 10.5 | 43.3 | 14.5 |

*ប្រភព: ក្រុមប្រឹក្សាវិនិយោគកម្ពុជា (១៩៩៥-២០០៣) ។ * ក្នុងនេះមានទាំងគំរោងពង្រីកគំរោងវិនិយោគដែលមានស្រាប់ ។*

## តារាង២. គំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៦-២០០៣

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | 2003 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ភូមិគ្រឹះ | 205 | 179 | 143 | 136 | 111 | 108 | 36 | 40 | 29 | 39 | 25 | 48 |
| ផ្ទះល្វែង | 537 | 528 | 678 | 864 | 520 | 499 | 154 | 123 | 125 | 104 | 148 | 116 |
| ផ្សេងៗ | 116 | 117 | 132 | 74 | 64 | 57 | 22 | 14 | 21 | 23 | 17 | 22 |
| សរុប | 858 | 824 | 953 | 1074 | 695 | 664 | 212 | 177 | 175 | 166 | 190 | 186 |

*ប្រភព: នាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រុងភ្នំពេញ ។*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៦-២០០៣

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | 2003 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 387.1 | 493.4 | 784.4 | 941.1 | 1055.5 | 1267.0 | 451.7 | 412.9 | 331.5 | 408.5 | 492.3 | 475.7 |
| រួមមាន: - សំលៀកបំពាក់ | 78.8 | 227.2 | 378 | 554 | 962.1 | 1201.0 | 431.7 | 385.4 | 314.7 | 389.9 | 475.2 | 448.5 |
| • ទៅសហរដ្ឋអាមេរិក | 0.4 | 107.2 | 74.1 | 486 | 714.1 | 840.9 | 295.2 | 269.2 | 230.6 | 267.8 | 303.2 | 298.2 |
| • ប្រទេសផ្សេងទៀត | 78.4 | 120 | 82 | 68 | 248.0 | 360.1 | 136.5 | 116.2 | 84.1 | 122.1 | 172.0 | 150.3 |
| - កសិកម្ម | - | - | - | - | 90.5 | 66.0 | 20.1 | 27.4 | 16.8 | 18.7 | 17.0 | 27.2 |
| • កៅស៊ូ | - | - | - | - | 29.6 | 25.9 | 9.2 | 9.1 | 6.3 | 6.7 | 10.0 | 12.1 |
| • ឈើ | - | - | - | - | 32.5 | 22.3 | 4.1 | 3.3 | 2.8 | 2.8 | 2.1 | 2.4 |
| • ជលផល | - | - | - | - | 5.4 | 6.0 | 1.0 | 0.5 | 0.8 | 0.7 | 0.6 | 0.7 |
| • ផ្សេងៗ | - | - | - | - | 26.0 | 11.8 | 5.8 | 14.5 | 6.9 | 8.5 | 4.3 | 12.0 |
| ការនាំចូលសរុប | 1114.4 | 1094.5 | 1112.2 | 1237.4 | 1417.7 | 1501.4 | 484.4 | 438.7 | 393.8 | 507.3 | 436.2 | 497 |
| រួមមាន: - សាំង | - | - | - | - | - | - | 5.9 | 7.6 | 10.4 | 8.0 | 5.6 | 9.0 |
| - ម៉ាស៊ូត | - | - | - | - | - | - | 31.3 | 23.3 | 25.0 | 33.4 | 25.1 | 24.4 |
| - សំភារៈសំណង់ | - | - | - | - | - | - | 3.7 | 2.9 | 2.8 | 3.4 | 2.4 | 3.5 |
| - ផ្សេងៗ | - | - | - | - | - | - | 443.5 | 404.9 | 355.6 | 462.5 | 403.1 | 460 |
| ជញ្ជីងពាណិជ្ជកម្ម | -727.3 | -601.2 | -327.8 | -296.3 | -362.2 | -234.0 | -32.7 | -25.8 | -62.3 | -98.8 | 56.1 | -21.3 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 198 | 188 | 66 | 47 | 74 | 24.8 | 27.5 | 33.2 | 26.3 | 34.7 | 10.1 | 16.4 |
| ការនាំចេញសរុប | 2.1 | 27.5 | 58.9 | 12.4 | 19.7 | 20 | 28.0 | 35.3 | 20.7 | 30.0 | 9.0 | 15.2 |
| ការនាំចូលសរុប | 1.2 | -1.8 | 1.6 | 11.3 | 14.5 | 5.9 | 59 | 27 | 22 | 7.8 | -10.0 | 19.6 |

*ប្រភព: ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ទីចាត់ការគយ និងរដ្ឋាករ, រួមទាំង ការលើកលែងពន្ធ ។*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៦-២០០៣

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | 2003 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | អ្នកដំណើរពាន់នាក់ | | | | | | | | | | | |
| ទិដ្ឋាការទេសចរ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 46.9 | 58.7 | 183.7 | 83.8 | 132.0 | 209.1 |
| តាមយន្តហោះ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 46.9 | 58.7 | 124.6 | 44.4 | 76.2 | 131.3 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | - | 59.1 | 39.4 | 55.8 | 77.7 |
| ទិដ្ឋាការជំនួញ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 15.6 | 16.1 | 20.4 | 14.7 | 20.3 | 15.5 |
| តាមយន្តហោះ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 15.6 | 16.1 | 17.2 | 11.2 | 16.3 | 15.5 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | - | 3.2 | 3.5 | 4.0 | - |
| ទិដ្ឋាការរដ្ឋការ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 52.0 | 92.9 | 4.7 | 4.6 | 5.9 | 6.1 |
| តាមយន្តហោះ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 52.0 | 92.9 | 4.0 | 4.0 | 5.1 | 6.1 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | - | 0.7 | 0.6 | 0.8 | - |
| សរុបតាមអាកាស | | | 186.3 | 262.9 | 351.7 | 408.4 | 114.5 | 167.7 | 145.8 | 59.6 | 97.6 | 152.9 |
| សរុបតាមផ្លូវគោក និងទឹក | - | - | 100..2 | 104.8 | 114.7 | 196.5 | 59.3 | 69.6 | 63 | 43.5 | 60.6 | 77.7 |
| សរុបអ្នកដំណើរ | 260.4 | 218.8 | 286.5 | 367.7 | 466.4 | 604.9 | 173.8 | 237.3 | 208.8 | 103.1 | 158.2 | 230.6 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុបអ្នកដំណើរ | 18.5 | -15.9 | 30.9 | 28.3 | 26.8 | 29.7 | 24.7 | 41.3 | -0.9 | -37.4 | -8.9 | -14.2 |

*ប្រភព: ក្រសួងទេសចរណ៍ ។*

## តារាង៥. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្ដូរប្រាក់ និងថ្លៃមាស ឆ្នាំ១៩៩៦-២០០៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | 2003 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | 6.1 | 16.3 | 6.2 | 5.4 | 0.9 | 2.0 | -0.3 | 7.4 | 5.9 | -1.9 | 1.8 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 7.1 | 8.0 | 14.8 | 4.0 | -0.8 | -0.6 | 3.5 | 3.04 | 1.8 | 1.6 | 0.8 | 0.5 |
| - ម្ហូបអាហារ | 7.6 | 6.7 | 14.1 | 7.6 | -3.3 | -2.8 | 2.0 | 2.00 | 3.20 | 2.3 | 1.5 | -0.04 |
| - ថាមពល | 20.7 | 20.0 | 15.1 | 3.5 | 6.6 | -1.1 | 0.9 | 2.25 | 4.75 | 5.2 | 5.1 | 5.1 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 2,666 | 3,029 | 3824 | 3832 | 3,879 | 3,935 | 3,935 | 3,948 | 3948 | 4008 | 4015 | 3999 |
| រៀលក្នុង ១ បាតថៃ | 105 | 98 | 88 | 101 | 96.3 | 88 | 93.5 | 90.9 | 92.4 | 94.9 | 96.9 | 100.5 |
| រៀលក្នុង ១០០ ដុងវៀតណាម | 24.0 | 25.6 | 28.6 | 27.8 | 27.4 | 26.6 | 25.7 | 25.8 | 25.6 | 25.9 | 24.9 | 24.8 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 40.4 | 36.0 | 34.0 | 33.3 | 32.7 | 38.0 | 38.5 | 39.8 | 40.0 | 41.5 | 44.4 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 779 | 883 | 1,065 | 1,105 | 1,329 | 1,521 | 1,550 | 1550 | 1697 | 1683 | 1683 | 1700 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,118 | 1,378 | 1,613 | 1,760 | 2,113 | 2,084 | 2,200 | 2200 | 2433 | 2383 | 2367 | 2400 |

## តារាង៦. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៦-២០០៣ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | 2003 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 881 | 1,177 | 1,726 | 2,019 | 2,589 | 3,080 | 3,693 | 3,737 | 3,741 | 3,594 | 3627 | 4010 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 31 | -114 | -496 | -576 | -759 | -876 | -943 | -849 | -737 | -641 | -621 | -691 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 128 | 54 | 178 | 103 | 3 | -75 | -106 | -119 | -72 | -19 | 18 | -128 |
| ឥណទានចំពោះផ្នែកឯកជន | 435 | 637 | 655 | 763 | 898 | 936 | 971 | 1,059 | 1,125 | 1,224 | 1287 | 1347 |
| រូបិយវត្ថុទូទៅ M2 | 912 | 1,063 | 1,230 | 1,443 | 1,831 | 2204 | 2,751 | 2,888 | 3,004 | 2,953 | 3007 | 3319 |
| រូបិយវត្ថុ M1 | 329 | 385 | 543 | 531 | 540 | 609 | 771 | 813 | 829 | 871 | 886 | 936 |
| រូបិយវត្ថុផ្សេងៗ | 583 | 678 | 687 | 911 | 1,291 | 1,594 | 1,979 | 2,075 | 2,175 | 2,082 | 2120 | 2383 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 40.3 | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 29.5 | 24.1 | 24.6 | 11.5 | 9.3 | 14.9 |
| រូបិយវត្ថុ M1 | 18.3 | 17 | 41 | -2.2 | 1.7 | 12.8 | 35.5 | 33.4 | 22.6 | 16.4 | 14.9 | 15.1 |
| រូបិយវត្ថុផ្សេងៗ | 57.1 | 16.3 | 1.3 | 32.6 | 41.7 | 23.5 | 27.3 | 30.2 | 25.7 | 9.5 | 7.1 | 14.8 |

## តារាង៧. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៦-២០០៣ (ពាន់លានរៀល)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | | 2003 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 748 | 880 | 920 | 1326 | 1528 | 1529 | 457 | 481 | 400 | 379 | 400.5 | 506 |
| ចំណូលចរន្ត | - | - | - | - | - | 1521 | 456 | 481 | 400 | 377 | 399.2 | 506 |
| ចំណូលពន្ធ | 536 | 596 | 676 | 956 | 1096 | 1096 | 323 | 339 | 273 | 287 | 273.1 | 349.1 |
| ពន្ធគយ | 344 | 348 | 376 | 432 | 376 | 376 | 116 | 122 | 92 | 94 | 91.6 | 117.4 |
| ចំណូលមិនមែនពន្ធ | 176 | 272 | 204 | 348 | 424 | 424 | 133 | 142 | 127 | 90 | 126.2 | 156.8 |
| អាជីវកម្មព្រៃឈើ | 28 | 36 | 20 | 36 | 28 | 29 | 9 | 5 | 1 | 1 | 4.5 | 0.5 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 64 | 84 | 88 | 108 | 124 | 122 | 30.7 | 44 | 19 | 18 | 33.5 | 44.3 |
| ចំណូលជាមូលធន | 40 | 12 | 36 | 12 | 8 | 9 | 1 | 0 | 0 | 2 | 1.3 | 0.0 |
| ចំណាយសរុប | 1440 | 1260 | 1296 | 1792 | 2332 | 2332 | 704 | 668 | 660 | 660 | 661.6 | 582.4 |
| ចំណាយជាមូលធន | 628 | 452 | 368 | 624 | 976 | 977 | 303 | 343 | 276 | 271 | 279.6 | 205.1 |
| ចំណាយចរន្ត | 812 | 808 | 980 | 1164 | 1356 | 1355 | 401 | 325 | 384 | 388 | 381.9 | 377.3 |
| អប់រំ និងសុខាភិបាល | 124 | 128 | 132 | 280 | 344 | 343 | 85 | 96 | 36 | 88 | 122.4 | 128.4 |
| ការពារជាតិ និងសន្តិសុខ | 408 | 420 | 448 | 464 | 404 | 405 | 105 | 110 | 70 | 119 | 75.4 | 110.1 |
| ក្រសួងផ្សេងៗទៀត | 284 | 260 | 332 | 412 | 636 | 637 | 212 | 120 | 279 | 182 | 214 | 138.8 |
| ឱនភាពជាទូទៅ | -692 | -380 | -380 | -476 | -804 | -803 | -248 | -187 | -260 | -281 | -261 | -76.5 |
| ហិរញ្ញប្បទានក្រៅប្រទេស | 680 | 444 | 268 | 416 | 768 | 766 | 273 | 287 | 176 | 201 | 230 | 244.8 |
| ហិរញ្ញប្បទានក្នុងស្រុក | 12 | -64 | 112 | 60 | 36 | 37 | -25 | -100 | 84 | 80 | 31 | -168.3 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ពលករងាយរងគ្រោះ ឆ្នាំ១៩៩៧-២០០៣

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1997 | 2001 | 2002 | | 2003 | | | | 2004 | 2003 | | 2004 |
| | មុនកក្កដា | វិច្ឆិកា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 12,250 | 6,262 | 8,900 | 8,878 | 9,200 | 9,572 | 9,380 | 9,817 | 9,500 | 5.4 | 10.58 | 3.26 |
| អ្នកលីសែង | 9,675 | 5,000 | 7,600 | 6,312 | 7,600 | 7,955 | 7,240 | 6,500 | 8,700 | -4.7 | 2.98 | 14.47 |
| អ្នកលក់បន្លែតូចតាច | 7,050 | 5,096 | 6,862 | 7,158 | 7,250 | 6,674 | 6,860 | 6,700 | 7,400 | -0.3 | -6.40 | 2.07 |
| អ្នករើសអេតចាយ | 4,155 | 3,393 | 3,440 | 4,012 | 3,875 | 3,605 | 4,900 | 3,900 | 4,800 | 42.7 | -2.79 | 23.87 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | – | 2,358 | 4,225 | 4,000 | 4,600 | 4,341 | 4,520 | 4,435 | 4,900 | 7.0 | 10.88 | 6.52 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | – | 3,618 | 3,833 | 4,219 | 4,180 | 3,712 | 4,600 | 4,450 | 4,700 | 20.0 | 5.48 | 12.44 |
| កម្មកររោងចក្រកាត់ដេរ | – | 8,968 | 9,800 | 10000 | 10,127 | 9,123 | 10,300 | 10000 | 9,675 | 5.1 | 0.0 | -4.46 |
| អ្នករត់ម៉ូតូឌុប | – | 9,791 | 11,300 | 12,075 | 11,400 | 9372 | 10900 | 10000 | 11,200 | 16.7 | -17.18 | -1.75 |
| កម្មករសំណង់គ្មានជំនាញ | – | 4,841 | 6,525 | 5,850 | 6,162 | 7100 | 7600 | 6200 | 7,200 | -3.5 | 5.98 | 16.85 |
| កម្មករសំណង់មានជំនាញ | – | 9,866 | 12,695 | 13,350 | 12,500 | 12,050 | 12,700 | 16,900 | 13,800 | 0.0 | 26.59 | 10.40 |

*សំគាល់: ចំនួនអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នកម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ *ចំនួនអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្ដល់ឱ្យទេ ។ ប្រភព: តារាង៥: វិបសអ, IMF, NIS ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៦: ធនាគារជាតិនៃកម្ពុជា / តារាង៧: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៨: វិបសអ ។*

# សទ្ទានុក្រម ~ ពាក្យប្រើក្នុងអត្ថបទនេះ

**ទុនសង្គម (Social capital)**
បណ្ដាញខាងសង្គមកិច្ច ទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន ជារឿយៗ គេហៅថា ទុនសង្គម ។ ទុននេះ គេមើលឃើញកាន់តែសំខាន់ឡើង ហើយសំរាប់ការអភិវឌ្ឍន៍ ។ យើងនិយាយពី *ទុនសង្គមចងភ្ជាប់* (ក្នុងក្រុមតូចមួយនៅក្នុងសហគមន៍), *ទុនសង្គមជាស្ពាន* (បណ្ដាញខាងក្រៅសហគមន៍ និងទំនុកចិត្តរវាងក្រុម និងតួអង្គផ្សេងៗនៅក្នុងសហគមន៍ធំ) និង*ទុនសង្គមតភ្ជាប់* (ទិដ្ឋភាពនៃទុនសង្គមដែលជួយឱ្យសហគមន៍នានា មានលទ្ធភាពបានប្រើប្រាស់ធនធាននៅខាងក្រៅសហគមន៍របស់ខ្លួន) ។

**ការក្ដោបក្ដាប់របស់ពួកវណ្ណៈខ្ពស់ (Elite grabbing)**
ពាក្យនេះមានន័យថា អត្ថប្រយោជន៍នៃការអភិវឌ្ឍន៍ដែលសំរាប់គ្រប់ៗគ្នា ត្រូវបាន "ក្ដោបក្ដាប់" ដោយពួកវណ្ណៈខ្ពស់ក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច ឬ នយោបាយ ។

**ការរៀនសូត្រពីអ្នកឋានៈស្មើតាមខ្សែផ្ដេក (Horizontal pear learning)**
នេះជាការរៀនសូត្រក្នុងចំណោមអ្នកមានឋានៈស្មើនៅកំរិតខ្សែផ្ដេក ។ ឧទាហរណ៍ មានការរៀនសូត្រពីអ្នកមានឋានៈស្មើ បើសិនស្មៀនឃុំ/សង្កាត់ជួយជ្រោមជ្រែង និងរៀនសូត្រពីគ្នាទៅវិញទៅមក ។ វាជាការរៀនសូត្រពីអ្នកមានឋានៈស្មើ ពីព្រោះការរៀនសូត្រត្រូវបានចែករំលែកឱ្យគ្នា រវាងអ្នកនៅកំរិតស្មើគ្នាក្នុងជួររដ្ឋាភិបាល ។

---

*តពីទំព័រទី ២០* **ពត៌មានថ្មីៗ...**

ដោយឡែកមួយ ស្ដីពី *ការធ្វើការរួមគ្នាដើម្បីសន្តិភាព និងអភិវឌ្ឍន៍* នៅ-វាលវែង ក៏បានបញ្ចប់ហើយដែរ ។ អ្នកបណ្ដុះបណ្ដាលភាគ-ច្រើនគឺជាមន្ត្រីស្រុក សមាជិកក្រុមប្រឹក្សាឃុំ ព្រះសង្ឃ មន្ត្រីយោធា និងប៉ូលិស ដែលមានការងារ ជាប់ទាក់ទងនឹងការដោះស្រាយទំនាស់នៅតំបន់នោះ ។ សមាជិកក្រុម មសអ បានចូលរួមក្នុងសិក្ខាសាលាពីរថ្ងៃស្ដីពី*ការដោះស្រាយទំនាស់* និងសិក្ខា សាលា-ពីរថ្ងៃទៀតស្ដីពី *ជាតិនិយមនិងអត្តសញ្ញាណ* នៅសណ្ឋាគារសាន់វេ រៀបចំដោយក្រុមការងារដើម្បីដោះស្រាយទំនាស់ ។

**បណ្ណាល័យ**
បណ្ណាល័យ វបសអ មានសៀវភៅជាង ៨.០៥៥ចំណងជើង ស្ដីពីសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សង្គម ។ មានអ្នកប្រើប្រាស់ ៤១៦នាក់ បានចុះឈ្មោះជាសមាជិកបណ្ណាល័យ វបសអ ។ ការណែនាំបង្ហាញពីបណ្ណាល័យដល់និស្សិតបានធ្វើឡើងសំរាប់និស្សិតមកពី វិទ្យាស្ថានជាតិគ្រប់គ្រង, សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សាកលវិទ្យាល័យន័រតុន, សាលាមធ្យមសិក្សាស្ថិតិនិងផែនការ ។ "បញ្ជីចំណងជើងឯកសារជាប់ទាក់ទងនឹងប្រទេសកម្ពុជា" បានបោះពុម្ព និងចែកចាយរួចហើយដល់បណ្ណាល័យភាគច្រើន


## Cambodia Development Review – 2004 Subscription Rates

**Domestic Subscription (Individual)**

q English edition ($14) q Khmer edition (5,000r) Payment by q cash or q local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed ..............................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

q English edition ($60 for five copies) q Khmer edition (20,000r for five copies).......Payment by q cash or q local cheque (please add $2 to cover bank charges). Total payment enclosed ..............................

**International Subscription (Individual)**

q Thailand, Laos, Vietnam q English edition ($25)* q Khmer edition ($15)*
q Asia and Europe q English edition ($30)* q Khmer edition ($20)*
q Americas and Africa q English edition ($35)* q Khmer edition ($25)*

* Subscription includes postage. Payment by q cash (in Phnom Penh) or q cheque (please add $25 to cover bank charges for processing US dollar cheques). At present CDRI can accept payment from overseas only by US-dollar denominated cheque or bankers draft. Total payment enclosed ..............................

Title: q Mr q Ms q Dr qOther ..............................

First name: .................. Last name: .................. Position: ..................

Organisation / Company: ..............................

Address (CCC Box if applicable): ..............................

City / Province: .................. Country:

Telephone: .................. Fax:

e-mail: .................. q Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Please make cheques payable to the Cambodia Development Resource Institute. Do not send cash through the post. Please inform the Publications Section at CDRI if your contact details change.

# ព័ត៌មានថ្មីៗ ពី វបសអ

## ផ្នែកគ្រប់គ្រង

វបសអ បានបញ្ចប់ការពិភាក្សាដោយជោគជ័យជាមួយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) ស្តីពីការបន្តវិភាគទានដ៏សំខាន់របស់ SIDA សំរាប់បន្ទុកចំណាយប្រតិបត្តិការ វបសអ ពីឆ្នាំ២០០៤-២០០៦ និងជាមួយ NOVIB (Oxfarm Netherlands) ចំពោះការគាំទ្រដល់ការងារមជ្ឈមណ្ឌលដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ នៃ វបសអ ពីឆ្នាំ២០០៤-២០០៦ ។ SIDA និងអង្គការ DFID នៃរដ្ឋាភិបាលអង់គ្លេស, បន្តធ្វើជាដៃគូផ្តល់ជំនួយដល់កម្មវិធីស្រាវជ្រាវផ្តោតលើគោលនយោបាយស្តីពីវិមជ្ឈការរបស់ វបសអ ។ វបសអ សូមអរគុណដល់ការជួយឧបត្ថម្ភ និងភាពជាដៃគូរបស់ទីភ្នាក់ងារទាំងពីរ ។

នៅខែមករា នាយក វបសអ បានរួមវិភាគទានដល់សិក្ខាសាលាត្រីភាគីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពី ការលើកកំពស់ជំនួយគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ ដែលប្រារព្ធធ្វើនៅក្រុងបាងកក, ហើយនៅខែកុម្ភៈ លោកនាយកបានរួមវិភាគទានដល់សិក្ខាសាលាជាតិខ្មែរស្តីពី ការបំពេញឡើងវិញនូវមូលនិធិអភិវឌ្ឍន៍អាស៊ី ដែលធ្វើឡើងនៅក្រុងភ្នំពេញដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ។

## ផ្នែកស្រាវជ្រាវ

បច្ចុប្បន្ន កម្មវិធីសេដ្ឋកិច្ចរបស់ វបសអ កំពុងធ្វើការសិក្សា ៤ ដែលជាប់ទាក់ទងនឹងភាពក្រីក្រ, សហគ្រាសធុនតូចនិងមធ្យម, ភាពប្រកួតប្រជែងនៃដំណាំកសិកម្មលក់យកប្រាក់ និងសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន។ ការសិក្សាពីរចុងក្រោយជាកិរិតតំបន់ និងមានការចូលរួមពីវិទ្យាស្ថានដៃគូនៅ ឡាវ វៀណាម និងថៃ ។ ការចុះសិក្សាដល់កន្លែងពីសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន និងសហគ្រាសធុនតូចនិងមធ្យម បានបញ្ចប់ហើយៗកំពុងធ្វើវិភាគទិន្នន័យ ។ ចំពោះការសិក្សាលើដំណាំលក់យកប្រាក់ ការចុះសិក្សាដល់កន្លែងលើដំណាំពីរមុខ (ក្នុងចំណោម ៤មុខ) បានចប់សព្វគ្រប់ហើយ ។ កម្មវិធីបរិស្ថាន និងធនធានធម្មជាតិ (NRE) បានបញ្ចប់ការចុះស្រាវជ្រាវដល់កន្លែងក្នុងខេត្តព្រះវិហារ និងកំពង់ធំ ស្តីពីជីវភាពរស់នៅ និងបញ្ហាគ្រប់គ្រងសំរាប់ព្រៃឈើមានតំលៃខ្ពស់ ។ លោក យឹម ជា អ្នកស្រាវជ្រាវក្នុង NRE ត្រូវធ្វើដំណើរទៅឈៀងម៉ៃ (ប្រទេសថៃ) នៅខែមេសាដើម្បីចូលរួមក្នុងវគ្គសិក្សារយៈពេល ១ខែខាងសេដ្ឋកិច្ចបរិស្ថានដែលឧបត្ថម្ភដោយកម្មវិធីបរិស្ថាន និងសេដ្ឋកិច្ចសំរាប់អាស៊ីអគ្នេយ៍ ។ កម្មវិធីស្រាវជ្រាវផ្តោតលើគោលនយោបាយស្តីពីវិមជ្ឈការ (PORDEC) បានបង្ហើយការសិក្សាស្តីពីការតាក់តែងរចនាវិមជ្ឈការ ហើយនឹងបោះពុម្ពផ្សាយនៅខែមេសា ។ លទ្ធផលរកឃើញ បានផ្សព្វផ្សាយក្នុងសិក្ខាសាលាមួយនាថ្ងៃ ២៩ មេសា នៅក្រុងភ្នំពេញ ។ សិក្ខាសាលាផ្សព្វផ្សាយក៏បានធ្វើឡើងក្នុង ៤ខេត្តផងដែរ ។ PORDEC សព្វថ្ងៃកំពុងធ្វើការសិក្សាពីប្រភពចំណូលផ្ទាល់របស់អាជ្ញាធរមូលដ្ឋាន ក្នុងកិច្ចសហការគ្នាមួយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ UNICEF និង វបសអ ។ ទន្ទឹមនឹងនេះ ក្រុម PORDEC បានចាប់ផ្តើមជាការសាកល្បងនូវការសិក្សាមួយស្តីពីគណនេយ្យភាព និងការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន ។

## មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍

ក្រុមមជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (មសអ) បន្តធ្វើការបណ្តុះបណ្តាល ដែលជាការងារជាអាទិភាពសំរាប់ការអភិវឌ្ឍន៍ទុនសង្គម ។ ម៉ូឌុលទី១ នៃ*ការបណ្តុះបណ្តាលដើម្បីសន្តិភាព* បានចប់សព្វគ្រប់ហើយ ។ សិក្ខាកាមគឺជាអ្នកសំរបសំរួលមកពី សាលាក្រុងភ្នំពេញ និង អង្គការមិនមែនរដ្ឋាភិបាលនានា ។ ក្រុម មសអ ក៏បានទៅធ្វើការវាយតំលៃពីតំរូវការបណ្តុះបណ្តាលពីរលើកនៅតំបន់ផ្សះផ្សារស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ ការបណ្តុះបណ្តាល

*តទៅទំព័រទី ១៩*

ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ក៏មានផ្សាយជាភាសាអង់គ្លេសដែរ ៗ
***Cambodia Development Review*** **is also available in English.**

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី៨ លេខ២ ខែមេសា-មិថុនា ឆ្នាំ២០០៤

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*
បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង/មួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ ***អត្ថបទតាមដានសេដ្ឋកិច្ច*** ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹង ត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ: ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh
website: http://www.cdri.org.kh

គ្រឹះស្ថានផ្សាយ: វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
គ្រប់គ្រងកែសំរួល: អែម សូវ៉ានី
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា / អ្នកបកប្រែ: យូ សិទ្ធីរិទ្ធ
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: អេង នេត្រា

**រក្សាសិទ្ធិ ២០០៤** វិទ្យាស្ថានបណ្តុះបណ្តាលនិង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560-7615**

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។